គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា

COMMITTEE FOR FREE AND FAIR ELECTIONS IN CAMBODIA

# របាយការណ៍

# ការផ្តល់អំណាចនយោបាយដល់ស្ត្រី និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧






## ខែតុលា ឆ្នាំ២០១៧

# របាយការណ៍

## ការផ្តល់អំណាចនយោបាយដល់ស្ត្រី
## និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
## អាណត្តិទី៤ ឆ្នាំ២០១៧




## ខែតុលា ឆ្នាំ២០១៧

# មាតិកា


បុព្វកថា ..... i

ពាក្យកាត់ ..... iii

I – សេចក្តីផ្តើម ..... 1

II – ការចូលរួមនយោបាយរបស់ស្ត្រីក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១៧ ..... 4

១ – ការជ្រើសរើសបេក្ខជនស្ត្រី និងការចុះបញ្ជីបេក្ខជនគណបក្សនយោបាយ ..... 5

- តារាងទី១ : ចំនួនបេក្ខជនស្ត្រីឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី១ ដល់អាណត្តិទី៤ ..... 8
- តារាងទី២ : ចំនួនបេក្ខជនស្ត្រីឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ទាំង១២គណបក្ស ..... 8
- តារាងទី៣៖ ចំនួនបេក្ខជនស្ត្រីឈរឈ្មោះល.រទី១ ដល់ទី៣ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤ ឆ្នាំ២០១៧ ..... 10

២ – ស្ត្រីជាប់ឆ្នោត ..... 12

- រូបភាពក្រាហ្វិក៤ : ភាគរយស្ត្រីជាប់ឆ្នោត អាណត្តិទី៤ ឆ្នាំ២០១៧ ..... 12
- តារាងទី៥ : ចំនួនស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ឆ្នាំ២០១៧ ..... 13
- រូបភាពក្រាហ្វិក៦: តួនាទីស្ត្រីជាប់ឆ្នោត អាណត្តិទី៤ ឆ្នាំ២០១៧ ..... 15
- រូបភាពក្រាហ្វិក៧: ប្រៀបធៀបតួនាទីស្ត្រីជាប់ឆ្នោត នៃគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ អាណត្តិទី៤ ឆ្នាំ២០១៧ ..... 15

- *រូបភាពក្រាហ្វិក៨: មេឃុំ ចៅសង្កាត់ជាស្ត្រីតាមវ័យ និងតំបន់ អាណត្តិទី៤ ឆ្នាំ២០១៧* ..... 16
- *រូបភាពក្រាហ្វិក៩ : ស្ត្រីជាមេឃុំ ចៅសង្កាត់ចាស់ និងថ្មី អាណត្តិទី៤ ឆ្នាំ២០១៧* ..... 17
- *រូបភាពក្រាហ្វិក១០ : ប្រៀបធៀបស្ត្រីជាប់ឆ្នោត និងមេឃុំ ចៅសង្កាត់ ជាស្ត្រី អាណត្តិទី៤ ឆ្នាំ២០១៧* ..... 18
- **ករណីសិក្សា : ភាពលេចធ្លោរបស់ស្ត្រីក្នុងការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ សង្កាត់** ..... 21
- **ករណីសិក្សាទី១ :** ..... 21
- **ករណីសិក្សាទី២ :** ..... 24

៣– **កម្មវិធីនយោបាយថ្នាក់ជាតិរបស់គណបក្ស អំពី បញ្ហាស្ត្រី និងកុមារ** ..... 26
- **តារាងទី១១** : *កម្មវិធីនយោបាយថ្នាក់ជាតិរបស់គណបក្ស ដើម្បីដោះស្រាយ បញ្ហាស្ត្រី និងកុមារ* ..... 26
- **តារាងទី១២** : *កម្មវិធីនយោបាយរបស់គណបក្សតាមឃុំ សង្កាត់នីមួយៗ ដែលបានសន្យាដោយបេក្ខជនស្ត្រី ដើម្បីដោះស្រាយបញ្ហាស្ត្រី និងកុមារ* ..... 30

៤– **សមាជិកស្ត្រីរបស់ គ.ជ.ប គធ/ខប គឃ/សប មន្ត្រីការិយាល័យ បោះឆ្នោត និងរាប់សន្លឹកឆ្នោត និង ស្ត្រីក្រុមចុះឈ្មោះបោះឆ្នោត** ..... 32
- *រូបភាពក្រាហ្វិក១៣: តួនាទីស្ត្រីជាមន្ត្រីការិយាល័យបោះឆ្នោត និង រាប់សន្លឹកឆ្នោត* ..... 33

៥– **អ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយជាស្ត្រី** ..... 34
- *អ្នកសង្កេតការណ៍ជាតិជាស្ត្រី* ..... 34
- *អ្នកសង្កេតការណ៍អន្តរជាតិជាស្ត្រី* ..... 35
- *ភ្នាក់ងារគណបក្សនយោបាយជាស្ត្រី* ..... 35

៦ – អ្នកបោះឆ្នោតស្ត្រី ........ 36
- ស្ត្រីក្នុងដំណើរការចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៦ ........ 36
- មតិស្ត្រីដែលបានចុះឈ្មោះបោះឆ្នោត ........ 36
- មតិស្ត្រីដែលមិនបានចុះឈ្មោះបោះឆ្នោត ........ 37
- ថ្ងៃបោះឆ្នោត ........ 38

III – សេចក្តីសន្និដ្ឋាន និងសង្ខេប ........ 41
IV – អនុសាសន៍ ........ 42
ឧបសម្ព័ន្ធ

# បុព្វកថា

**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា ហៅកាត់ថា "ខុមហ្វ្រែល"** ធ្វើការដើម្បីលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងការចូលរួមរបស់ប្រជាពលរដ្ឋតាមគោលការណ៍កសាងសមត្ថភាពរបស់បណ្តាញទូទាំងប្រទេស និងសហប្រតិបត្តិការជាមួយអង្គការជាសមាជិក និងជាដៃគូ ។ ប្រជាធិបតេយ្យមិនមែនត្រឹមតែការបោះឆ្នោតប៉ុណ្ណោះទេ ក៏ប៉ុន្តែជាការបោះឆ្នោតដោយសេរី និងយុត្តិធម៌ជាលក្ខខណ្ឌចាំបាច់នៃលទ្ធិប្រជាធិបតេយ្យ ។ ខុមហ្វ្រែលក៏ជាសមាជិកនៃក្រុមស្ត្រីដើម្បីទាំងអស់គ្នាដែលធ្វើការរួមគ្នាដើម្បីលើកស្ទួយដល់ការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ និងការដឹកនាំទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋាន ក្នុងការជំរុញឲ្យមានការផ្លាស់ប្តូរជាវិជ្ជមានចំពោះការចូលរួមរបស់ស្ត្រីតាមបែបប្រជាធិបតេយ្យ តាមរយៈការអភិវឌ្ឍន៍សមត្ថភាពស្ត្រី ការតស៊ូមតិ និងបញ្ចុះបញ្ចូលអ្នកដឹកនាំគណបក្សនយោបាយ និងរដ្ឋាភិបាលក្នុងការបង្កើតគោលនយោបាយ និងច្បាប់ដើម្បីបង្កើនចំនួនតំណាងស្ត្រីនយោបាយនៅគ្រប់លំដាប់ថ្នាក់ ។

របាយការណ៍ ស្តីពី *"ការផ្តល់អំណាចនយោបាយដល់ស្ត្រី និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧"* គឺជាទំរង់នៃការវិភាគទៅលើទិន្នន័យ និងមតិយោបល់របស់ស្ត្រីកម្ពុជាចូលរួមក្នុងកិច្ចការនយោបាយ ជាពិសេសក្នុងដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ កន្លងទៅនេះ ។

របាយការណ៍នេះ បង្ហាញការវាយតម្លៃលើការផ្តល់អំណាចនយោបាយដល់ស្ត្រី និងការបោះឆ្នោតអំពីចំនួនបេក្ខជនស្ត្រី ស្ត្រីជាប់ឆ្នោត គោលនយោបាយរបស់គណបក្សក្នុងការលើកស្ទួយស្ត្រីចូលរួមក្នុងវិស័យនយោបាយ កម្មវិធីនយោបាយរបស់គណបក្សអំពីបញ្ហាស្ត្រី និងកុមារ ការប្រឈមរបស់ស្ត្រី ទាំងអ្នកបោះឆ្នោត និងបេក្ខជន មតិស្ត្រីនៅក្នុងកិច្ចការបោះឆ្នោត និងសកម្មភាពនានាដែលទាក់ទងទៅនឹងការលើកស្ទួយស្ត្រីឲ្យចូលរួមក្នុងវិស័យនយោបាយជាដើម ។ ម្យ៉ាងទៀត របាយការណ៍នេះក៏ផ្តល់នូវលទ្ធផលនៃការស្ទង់មតិរហ័សនៅតំបន់គោលដៅរបស់ខុមហ្វ្រែលបន្ទាប់ពីថ្ងៃបោះឆ្នោតទៅលើ*"ស្ត្រីដែល បានទៅបោះឆ្នោត ឬមានទឹកខ្មៅនៅម្រាមដៃ និងស្ត្រីដែលមិនបានទៅបោះឆ្នោត ឬមិនមានទឹកខ្មៅ នៅម្រាមដៃ"* និងករណីសិក្សាចំនួន២ ។ របាយការណ៍នេះក៏បានបង្ហាញផងដែរ អំពី របាយការណ៍សង្កេតការណ៍ស្ត្រីរបស់ខុមហ្វ្រែលតាមរយៈការដាក់ពង្រាយអ្នកសង្កេតការណ៍ស្ត្រីចំនួន ១២២នាក់ នៅក្នុងខេត្តគោលដៅចំនួន៥ ដើម្បីតាមដាន និងឃ្លាំមើលការចូលរួមរបស់ស្ត្រីក្នុងកិច្ចការនយោបាយ និងការបោះឆ្នោតជ្រើសរើសក្រុម

ប្រឹក្សាឃុំ សង្កាត់។ ជាចុងក្រោយ របាយការណ៍នេះមានអនុសាសន៍សំខាន់ៗក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងការផ្ដល់អំណាចនយោបាយដល់ស្ត្រីនៅក្នុងប្រទេសកម្ពុជា ។

**ខុមហ្វ្រែល**សង្ឃឹមថា របាយការណ៍នេះជាឯកសារដ៏សំខាន់ និងមានប្រយោជន៍សម្រាប់អ្នកអនុវត្តន៍សកម្មភាព ជាពិសេសមន្ត្រីរដ្ឋាភិបាល សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ គណបក្សនយោបាយ បុគ្គលិកសមាគម អង្គការមិនមែនរដ្ឋាភិបាល តំណាងរបស់ដៃគូអភិវឌ្ឍន៍ និងអ្នកស្រាវជ្រាវ ដើម្បីជួយលើកស្ទួយស្ត្រីចូលរួមកាន់តែច្រើនក្នុងវិស័យនយោបាយ និងថ្នាក់សម្រេចចិត្ត ។

សូមថ្លែងអំណរគុណជាពិសេសចំពោះក្រុមការងាររបស់ខុមហ្វ្រែល ដូចជា **លោកស្រី ស៊ឹនកេត សិរីលក្ខណ៍** ដែលជាអ្នកសរសេររបាយការណ៍នេះ ។ លោកស្រីក៏ជាអ្នកដឹកនាំក្រុមការងារ ដូចជា**កញ្ញា ជូ សុភ័ក្រ កញ្ញា អ៊ឹម ស៊ីវត្ថា** និង**អ្នកសង្កេតការណ៍ស្ត្រី** ដែលបានខិតខំអនុវត្តតាមផែនការសកម្មភាពដើម្បីប្រមូលទិន្នន័យ បកប្រែពីភាសាខ្មែរទៅអង់គ្លេស និងរចនារបាយការណ៍នេះ ដោយមានការគាំទ្រពីក្រុមការងាររបស់ខុមហ្វ្រែល និងលេខាធិការខេត្តខុមហ្វ្រែល ។ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ **លោក គល់ បញ្ញា** និង**លោក គឹម ឈន** ផងដែរដែលបានផ្ដល់មតិគាំទ្រធ្វើឲ្យរបាយការណ៍នេះកាន់តែមានភាពល្អប្រសើរថែមទៀត ។ ខ្ញុំសូមអរគុណចំពោះ**លោក ខេវីន នូអេន** (Kevin Nauen) ដែលបានជួយកែសម្រួលភាសាអង់គ្លេសក្នុងរបាយការណ៍នេះ ។

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧

**នាយកប្រតិបត្តិខុមហ្វ្រែល**

**គល់ បញ្ញា**

# ពាក្យកាត់ (ACRONYMS)

| | |
|---|---|
| BSDP | Beehive Social Democratic Party |
| CEC | Commune Election Commission |
| CEDAW | Convention on the Elimination of All Forms of Discrimination against Women |
| CIPDP | Cambodian Indigenous People's Democracy Party |
| CNP | Cambodian Nationality Party |
| CNRP | Cambodian National Rescue Party |
| CMDGs | Cambodian Millennium Development Goals |
| COMFREL | Committee for Free and Fair Elections in Cambodia |
| CPP | Cambodian People's Party |
| CPWP | Committee to Promote Women in Politics |
| CSO | Cooperation Committee for Cambodia |
| CYP | Cambodian Youth Party |
| DPA | Development and Partnership in Action |
| FUNCINPEC/FCP | National United Front for an Independent, Neutral, Peaceful and Cooperative Cambodia |
| GADC | Gender and Development for Cambodia |
| GDP | Grassroots Democracy Party |
| HRP | Human Rights Party |
| KNUP | Khmer National United Party |
| KPP | Khmer Power Party |
| LDP | League for Democracy Party |
| NA | National Assembly |
| NEC | National Election Committee |
| NGOs | Non-Governmental Organization |
| NICFEC | Neutral and Impartial Committee for Free and Fair Election in Cambodia |
| PADEK | Partnership for Development in Kampuchea |
| PSO | Polling Station Official |
| PSC | Polling Station Commission |
| PEC | Provincial Election Commission |
| RDP | Republican Democracy Party |
| RFA | Radio Free Asia |
| RGC | Royal Government of Cambodia |
| SDGs | Sustainable Development Goals |
| SILAKA | SILAKA |
| VOA | Voice of America |
| WMC | Women Media Center |

# I. សេចក្តីផ្តើម

បទពិសោធន៍ និងការស្រាវជ្រាវរបស់បានរកឃើញថា ភាពចំរុះនៃផ្នែកយេនឌ័រផ្តល់នូវលទ្ធផលល្អប្រសើរជាងមុននៅក្នុងការធ្វើសេចក្តីសម្រេចចិត្តផ្នែកនយោបាយ ហើយតួនាទីរបស់ស្ត្រីក្នុងដំណើរការនយោបាយទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានធ្វើឲ្យលទ្ធផលក្នុងប្រទេសមានភាពប្រសើរឡើងកាន់តែខ្លាំងថែមទៀត។ សិទ្ធិរបស់ស្ត្រីក្នុងការបញ្ចេញសំលេងស្មើគ្នា និងការចូលរួមក្នុងឆាកនយោបាយមានមូលដ្ឋានរឹងមាំនៃការប្តេជ្ញាចិត្តរបស់អន្តរជាតិ *ពីអនុសញ្ញានៃការលុបបំបាត់រាល់ទម្រង់នៃរើសអើងលើស្ត្រី (CEDAW) ឆ្ពោះទៅកាន់វេទិកាក្រុងប៉េងកាំងដើម្បីសកម្មភាព (Beijing Platform for Action) គោលដៅអភិវឌ្ឍន៍ សហស្សវត្សរ៍ (Millennium Develoment Goals) និងថ្មីៗនេះគឺគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (Sustainable Development Goals)* ។ ប៉ុន្តែស្ត្រីនៅតែបន្តមានតំណាងតិចតួចនៅគ្រប់ផ្នែកនៃជីវិតនយោបាយ ដូចជាស្ត្រីនៅក្នុងគណបក្សនយោបាយ ស្ត្រីក្នុងដំណើរការបង្កើតច្បាប់ ស្ត្រីជាបេក្ខជនឈរឈ្មោះបោះឆ្នោត និងតំណាងស្ត្រីជាប់ឆ្នោត ។ល។ និង។ល។

ជាក់ស្តែង កម្ពុជានៅបន្តបញ្ហាវិសមភាពនៃតំណាង និងការអនុវត្តសិទ្ធិរវាងបុរស និងស្ត្រីនៅក្នុងវិស័យនយោបាយ ។ ផ្នែកចំបងនៃបញ្ហានេះ គឺដោយសារខ្វះនូវគោលនយោបាយជាក់លាក់ជាលាយលក្ខណ៍អក្សរដែលជាវិធានការពិសេសបណ្តោះអាសន្ន និងមាត្រាមួយចំនួននៃច្បាប់ជាពិសេសច្បាប់បោះឆ្នោតដើម្បីគាំទ្រ និងផ្តល់ឱកាសឲ្យស្ត្រី-បុរសចូលរួមស្មើគ្នាលើតួនាទីសម្រេចចិត្តក្នុងវិស័យសាធារណៈ និងវិស័យនយោបាយស្របតាមអនុសញ្ញាអន្តរជាតិ *«ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ(ស៊ី-ដវ/CEDAW)» និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG)* ដែលកម្ពុជាបានទទួលយក។ ផ្នែកខ្លះទៀតនៃបញ្ហានេះកើតឡើងដោយសារនៅតែបន្តការរើសអើង និងខ្វះការលើកទឹកចិត្ត គឺជាបច្ច័យដែលក្លាយជាឧបសគ្គសម្រាប់ស្ត្រីក្នុងការទទួលបាននូវសមភាព និងផលចំណេញពីការចូលរួមក្នុងវិស័យនយោបាយ ។ អនុសញ្ញាស៊ី-ដវ **មាត្រា៣ចែងថាៈ *«ក្នុងគ្រប់វិស័យ ជាពិសេស វិស័យនយោបាយ សង្គមកិច្ច សេដ្ឋកិច្ច និងវប្បធម៌រដ្ឋត្រូវចាត់វិធានការសមស្របទាំងអស់ រួមមាន ការធ្វើច្បាប់ផងដើម្បីធានាការអភិវឌ្ឍន៍ និងការរីកចំរើនពេញលេញរបស់ស្ត្រី ដើម្បីធានាឲ្យស្ត្រីប្រើប្រាស់ និងអាស្រ័យផលសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានដោយសមភាពជាមួយបុរស»*** ។

កម្ពុជាបានអនុវត្តនយោបាយវិមជ្ឈការតាមរយៈការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលគាំទ្រដោយច្បាប់ស្តីពី *«ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់»* និងច្បាប់ស្តីពី *"ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់"* សម្រាប់

អនុវត្តប្រចាំថ្ងៃរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំង ១៦២១ឃុំ សង្កាត់(ឆ្នាំ២០០២-២០០៧) ១៦៣៣ឃុំ សង្កាត់ (ឆ្នាំ២០១២-២០១៦) និង១៦៤៦ឃុំ សង្កាត់ ឆ្នាំ២០១៧ ។ ចាប់តាំងពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី១ ឆ្នាំ២០០២ រហូតមកដល់អាណត្តិទី៣ ឆ្នាំ២០១២ ចំនួនស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់មានការកើនឡើងជាបន្តបន្ទាប់ ហើយស្ត្រីក៏បានចូលរួមក្នុងកិច្ចការនយោបាយ ការបោះឆ្នោតយ៉ាងសកម្មសស្រាក់ស្រាំទាំងសម្លេង និងសកម្មភាពផងដែរ។ ផ្ទុយទៅវិញ ចំនួនស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់ អាណតិទី៤ ឆ្នាំ២០១៧នេះបែរជាមានការថយចុះទៅវិញ ។ គណបក្សពីរដែលមានប្រជាប្រិយភាពខ្លាំង គឺ គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិនៅតែបន្តកង្វះភាពអើពើរបស់អ្នកដឹកនាំគណបក្ស ចំពោះការឈរឈ្មោះជាបេក្ខជនរបស់ស្ត្រីក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤នេះ ។

យោងតាមលទ្ធផលផ្លូវការនៃការចុះបញ្ជីរបស់គណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) កាលពីថ្ងៃ១៨ ខែមេសា ឆ្នាំ២០១៧ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤នេះ មានបេក្ខជនស្រី-ប្រុសប្រកួតប្រជែងសរុបចំនួន ៩៤ ៥៩៥ (បេក្ខជនពេញសិទ្ធិ) ក្នុងនោះបេក្ខជនស្ត្រីមានចំនួន**២៥ ៧៨៨នាក់ (២៧,២៦%)** មកពីគណបក្សនយោបាយចំនួន**១២** និងមានតែគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិប៉ុណ្ណោះដែលបានរៀបចំបញ្ជីបេក្ខជនឈរឈ្មោះនៅទូទាំងប្រទេស ១៦៤៦ឃុំ សង្កាត់ ប៉ុន្តែបានដាក់បេក្ខជនស្ត្រីមានភាគរយតិចជាងគេ ។ តួលេខនេះមាន ការ**កើនតិចតួច ១,៦២%** ធៀបនឹង ឆ្នាំ២០១២ មានចំនួន ២៥,៦៤% ។ ចំណែក បេក្ខជនស្ត្រីឈរឈ្មោះនៅ **លេខរៀងទី១** សរុប ចំនួន ៨៨១នាក់ (៧,៨៩%)នៃបេក្ខជនលេខរៀងទី១ ប្រុស-ស្រីសរុប ៦ ០៩២នាក់ និងលេខរៀងចាប់ពី**ទី១ ដល់ទី៣** មានចំនួន **២ ៧៣៨នាក់ (១៤,៩៨%)** គឺ**កើន ៤១៦នាក់** ធៀបនឹងអាណត្តិទី២ ឆ្នាំ២០០៧មានចំនួនតែ ២ ៣២២នាក់ ប៉ុណ្ណោះ ។ គណបក្សដែលមានអាសនៈនៅក្នុងសភា និងមានប្រជាប្រិយភាពខ្លាំង បានខិតខំដាក់បេក្ខជនស្ត្រីឈរឈ្មោះនៅ**លេខរៀងទី១** ច្រើនជាងមុនគួរឲ្យកត់សម្គាល់ ដូចជា គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ។

ចំនួនស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤នេះ មានការ **ថយចុះបន្តិច ១,០២% (៩៨នាក់)** ពី ១៧,៧៨% (២ ០៣៨នាក់) ឆ្នាំ២០១២ មកត្រឹម **១៦,៧៦% (១ ៩៤០នាក់)** ឆ្នាំ២០១៧ នៃចំនួនអ្នកជាប់ឆ្នោតស្រី-ប្រុសសរុប ១១ ៥៧២នាក់ ។ ប៉ុន្តែមានការ**កើនឡើង**ចំនួន**មេឃុំ ចៅសង្កាត់ស្ត្រី ១,៩៦% (៣៣នាក់)** ពី ៥,៨១% (៩៥នាក់) ឆ្នាំ២០១២ ទៅ **៧,៧៧% (១២៨នាក់)**ឆ្នាំ២០១៧។ គណបក្សពីរ គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិបានទទួលសម្លេងឆ្នោតគាំទ្រពីអ្នកបោះឆ្នោត និងមានស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សា ឃុំ សង្កាត់ ។

របាយការណ៍ខាងក្រោមនេះ គឺបានពីអ្នកសង្កេតការណ៍បោះឆ្នោតស្ត្រីខុមហ្វ្រែល និងទិន្នន័យផ្សេងៗ ។ របាយការណ៍នេះគឺផ្តោតទៅលើបញ្ហា ឬការប្រឈម ដំណោះស្រាយ ឬវិធានការ និងចំនួន ទាក់ទងនឹងការជ្រើសរើសស្ត្រីឈរឈ្មោះជាបេក្ខជន ការចុះបញ្ជីបេក្ខជនស្ត្រី កម្មវិធីនយោបាយរបស់គណបក្សទាក់ទងនឹងបញ្ហាស្ត្រី និងកុមារ ស្ត្រីជាប់ឆ្នោត ស្ត្រីជាមន្ត្រីរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ស្ត្រីជាអ្នកសង្កេតការណ៍ និងអ្នកបោះឆ្នោតស្ត្រី ។

# II. ការចូលរួមនយោបាយរបស់ស្ត្រីក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១៧

ការចូលរួមនយោបាយរបស់ស្ត្រីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧កន្លងមក ត្រូវបានរកឃើញថា នៅតែមានភាពប្រឈមរាប់ចាប់ពីការទទួលបានឱកាសក្នុងការឈរឈ្មោះជាបេក្ខជន ការចូលរួមបោះឆ្នោត និងឱកាសឈានទៅមុខក្នុងជីវិតនយោបាយរបស់ស្ត្រីជាប់ឆ្នោត ។

ចាប់ពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី១ ឆ្នាំ២០០២ រហូតមកដល់អាណត្តិទី៣ ឆ្នាំ២០១២ ចំនួនស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់មានការកើនឡើងជាបន្តបន្ទាប់ ហើយស្ត្រីក៏បានចូលរួមក្នុងការបោះឆ្នោតយ៉ាងសស្រាក់សស្រាំ និងចូលរួមក្នុងកិច្ចការនយោបាយយ៉ាងសកម្ម រួមទាំងយុវជនផងដែរ ។ ផ្ទុយទៅវិញ ចំនួនស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤នេះបែរជាធ្លាក់ចុះទៅវិញ ។ ការធ្លាក់ចុះចំនួនស្ត្រីជាប់ឆ្នោតនេះគឺដោយសារៈ *(១)ខ្វះនូវគោលនយោបាយជាក់លាក់ជាលាយលក្ខណ៍អក្សរដែលជាវិធានការពិសេសបណ្តោះអាសន្ន និងមាត្រាមួយចំនួននៃច្បាប់បោះឆ្នោតដើម្បីគាំទ្រ និងផ្តល់ឱកាសឲ្យស្ត្រី-បុរសចូលរួមស្មើគ្នាក្នុងវិស័យនយោបាយ ។ (២)បន្តការរើសអើងប្រឆាំងនឹងស្ត្រីក្នុងដំណើរការបោះឆ្នោតជ្រើសរើសបេក្ខជននៅក្នុងគណបក្ស ។ (៣)គណបក្សដែលមានសក្តានុពល និងមានប្រជាប្រិយភាពខ្លាំង ដូចជា គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិបានដាក់បេក្ខជនស្ត្រីឈរឈ្មោះតិចជាងគេ និងប្រហាក់ប្រហែលអាណត្តិទី៣ ខណៈដែលគណបក្ស១០ផ្សេងទៀតបានដាក់បេក្ខជនស្ត្រីឈរឈ្មោះច្រើនគួរឲ្យកត់សម្គាល់ ។ (៤)នាយករដ្ឋមន្ត្រីកម្ពុជាបានត្រឹមតែអំពាវនាវជាពាក្យសំដីដល់គណបក្សនយោបាយទាំងអស់ឲ្យដាក់ស្ត្រីឈរឈ្មោះនៅលេខរៀងខាងលើ (ពីលេខរៀងទី១ដល់ទី៣) ខណៈដែលមិនមាននិន្នាការជម្រុញឲ្យធ្វើវិសោធនកម្មលើមាត្រាខ្លះនៃច្បាប់បោះឆ្នោតស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលការអំពាវនាវបែបនេះមិនមាន ប្រសិទ្ធភាពអ្វីទាំងអស់ ។ (៥)ក្រសួងកិច្ចការនារីបានបង្កើតក្រុមការងារបច្ចេកទេសស្តីពីយេនឌ័រ និងបានប្តេជ្ញាចិត្តជម្រុញឲ្យមានការកើនចំនួនតំណាងស្ត្រីនៅថ្នាក់សម្រេចចិត្ត និងចូលរួមក្នុងកិច្ចការនយោបាយ ។ ផ្ទុយទៅវិញ ក្នុងអំឡុងពេលដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១៧នេះ ពុំឃើញមានសកម្មភាពលេចធ្លោណាមួយចូលរួមជម្រុញដើម្បីបង្កលទ្ធភាពឲ្យស្ត្រីបានចូលរួមឈរឈ្មោះជាបេក្ខជនឲ្យច្រើន ដូចអ្វីដែលធ្លាប់បានប្តេជ្ញាចិត្តឡើយ ។*

ចំណុចទាំងអម្បាលមាណខាងលើ ជាការប្រឈម និងឧបសគ្គដ៏ធំសម្រាប់ស្ត្រីដែលមានបំណងចូលរួមក្នុងកិច្ចការនយោបាយ ជាពិសេសបេក្ខនារីដែលមានបំណងឈរឈ្មោះដើម្បីឲ្យគេបោះឆ្នោត និងសកម្មជនស្ត្រីគណបក្សនយោបាយ ។ ទោះបីជាយ៉ាងណាដោយ យើងឃើញមានការកើនឡើងខ្លះដែរនូវចំនួនមេឃុំ ចៅសង្កាត់ស្ត្រីសម្រាប់អាណត្តិទី៤ ឆ្នាំ២០១៧ នេះ ។

## ១- ការជ្រើសរើសបេក្ខជនស្ត្រី និងការចុះបញ្ជីបេក្ខជនគណបក្សនយោបាយ

គណបក្សនយោបាយសំខាន់ៗដែលមានអាសនៈនៅក្នុងសភា និងក្រុមប្រឹក្សាឃុំ សង្កាត់បានលើកឡើងនូវបញ្ហាស្រដៀងគ្នាទាក់ទងនឹងការតែងតាំងបេក្ខជន ។ ពួកគេបានលើកឡើងថា ការដាក់បញ្ជីបេក្ខជនឈរឈ្មោះ និងលំដាប់លេខរៀងទី១ គឺផ្អែកលើសមត្ថភាព ប្រជាប្រិយភាព ឆន្ទៈមុះមុត លទ្ធភាព និងមានប្រវត្តិនយោបាយយូរ ។ គណបក្សខ្លះ ជាពិសេសគណបក្សប្រឆាំងនៅតែលើកហេតុផលថា ពិបាករកស្ត្រីឈរឈ្មោះជាបេក្ខជន ប៉ុន្តែការលើកឡើងនេះត្រូវបានក្រុមឯកទេសការងារស្ត្រីរកឃើញថា វាគ្រាន់តែជាលេសតែប៉ុណ្ណោះ ។ រីឯគណបក្សប្រជាជនកម្ពុជា បញ្ជាក់ថា ការដាក់ចំនួនស្ត្រីឈរឈ្មោះជាបេក្ខជនដោយ ផ្អែកលើប្រជាប្រិយភាព និងសមត្ថភាពរបស់ស្ត្រី ។ គណបក្សខ្លះបានលើកឡើងថា ការដាក់ស្ត្រីឈរឈ្មោះនៅលំដាប់លេខរៀងទី១ និងឆ្លាស់គ្នាគឺជារឿងលំបាកសម្រាប់គណបក្សដោយពុំទាន់មើលឃើញពីសមត្ថភាពរបស់ស្ត្រី ខណៈដែលអ្នកសារព័ត៌មាន និងផ្នត់គំនិតសង្គមមួយចំនួននៅតែចោទជាសំណួរដដែល និងដាក់ភាពសង្ស័យ*អំពី «សមត្ថភាព និងសារៈសំខាន់នៃការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ និងជាអ្នកដឹកនាំ»* ។ ការត្អូញត្អែរលក្ខណៈវិនិច្ឆ័យ និងការចោទជាសំណួរដដែលៗទាំងនេះ ជាឧបសគ្គមួយយ៉ាងធំសម្រាប់បេក្ខនារីដែលមានបំណងឈរឈ្មោះដើម្បីឲ្យគេបោះឆ្នោតឲ្យ និងចូលរួមក្នុងជីវិតនយោបាយ ។

ប្រតិកម្មនឹងការលើកឡើងខាងលើនេះ ក្រុមការងារស្ត្រីដើម្បីទាំងអស់គ្នានៃអង្គការសង្គមស៊ីវិល បានធ្វើការពន្យល់នៅក្នុងសន្និសីទសារព័ត៌មាន ស្តីពី លទ្ធផលស្រាវជ្រាវលើបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ កាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ថា ៖

*«គួរឈប់លើកសំណួរ អំពីសមត្ថភាពរបស់ស្ត្រី ហើយសក្តានុពលរបស់ស្ត្រីធ្វើការបានអ្វីខ្លះ? ពីព្រោះសំណួរនេះជាសំណួររើសអើងស្ត្រីបំផុតដែលជាសកម្មភាពបង្អាក់ដល់ការចូលរួមរបស់ស្ត្រីក្នុងឆាកនយោបាយ។ យើងគួរតែបង្កើត និងអនុវត្តវិធានការណ៍ពិសេសមួយចំនួនដើម្បីផ្តល់ឱកាស និងលើកទឹកចិត្តស្ត្រីចូលរួមឲ្យបានច្រើន ជាជាងសួរតែអំពីសមត្ថភាព និងសក្តានុពលរបស់ស្ត្រី»* ថ្លែងដោយ**លោកស្រី សឺនគេត សិរីលក្ខណ៍** អ្នកសម្របសម្រួលកម្មវិធីអប់រំ និងយេនឌ័រនៃអង្គការខុមហ្វ្រែល និងជាសមាជិកក្រុមស្ត្រីដើម្បីទាំងអស់គ្នា ។

ទាក់ទងនឹងសក្តានុពល **លោកស្រី សឺនកេត សិរីលក្ខណ៍** បានបញ្ជាក់ថា៖ *«ថ្មីៗហ្នឹងយើងបានរកឃើញថា មេឃុំ-ចៅសង្កាត់ស្ត្រីធ្វើការពិតជាមានប្រសិទ្ធភាព ហើយយកចិត្តទុកដាក់ខ្លាំងទៅលើបញ្ហាស្ត្រី និងកុមារ ។ មានការឲ្យតម្លៃខ្លាំងមែនទែនទាំងប្រជាពលរដ្ឋក្តី រដ្ឋាភិបាលក្តី និងសង្គមស៊ីវិលក្តី ប៉ុន្តែចំនួននេះយើងឃើញថា* ***កើនតែវាតិចតួច*** *ដែលយើងគិតថាមិនទាន់ពេញចិត្តនូវអ្វីដែលបានទទួលនៅក្នុងប្រទេសកម្ពុជាទេ»*។ ផ្សាយដោយ VOD ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៧

*«ខ្ញុំជឿជាក់ថា ស្ត្រីណាក៏ដោយក៏មានសក្តានុពលរបស់គាត់ដែរ ប៉ុន្តែសក្តានុពលនេះពេលខ្លះត្រូវបានគេកប់ចោល ។ យើងមិនបន្ទោសទៅលើបុរសថាគ្មានសមត្ថភាពទេ លោកមានហើយទើបឈរឈ្មោះជាក្រុមប្រឹក្សា ឃុំ សង្កាត់បាន ក៏ប៉ុន្តែមើលទៅលើក្រុមប្រឹក្សាឃុំ សង្កាត់ ជាង ១ ៦០០ ឃុំ សង្កាត់ហ្នឹង ថាតើប្រសិទ្ធភាពនៃកិច្ចការងាររបស់មេឃុំ ចៅសង្កាត់បុរសទាំងអស់ឆ្លើយតបនឹងបញ្ហាស្ត្រី និងប្រជាពលរដ្ឋបានកម្រិតណា ?»* ថ្លែងដោយ **កញ្ញា សេខ រាសី** អ្នកសម្របសម្រួលកម្មវិធីលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ និងជាសមាជិកក្រុមស្ត្រីដើម្បីទាំងអស់គ្នា ។

**លោកស្រី ធីដា ឃឹះ** បានបញ្ជាក់បន្ថែមថា *« មានហេតុផលមួយចំនួនទៀតដែលមេដឹកនាំគណបក្សនយោបាយពិបាកដាក់បេក្ខជនស្ត្រីនោះ គឺផលប្រយោជន៍បុគ្គល និងតំបន់ដែលមានទំនាស់សង្គម ។ ជាគោលការណ៍ មេដឹកនាំគណបក្សនយោបាយមានបំណងចង់ដាក់បេក្ខជនស្ត្រីឲ្យបានច្រើននៅតាមឃុំ សង្កាត់មួយចំនួន ក៏ប៉ុន្តែការណ៍នេះមិនអាចធ្វើទៅបាន ដោយហេតុបុគ្គលកំពុងកាន់តួនាទីដែលជាបុរសនោះមិនព្រមចុះចេញ ។»* ផ្សាយដោយវិទ្យុសម្លេងសហរដ្ឋអាមេរិក (VOA) ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧

ក្រុមការងារស្ត្រីមានការបារម្ភផងដែរថា ចំនួនស្ត្រីតិចតួចនេះនឹងកើតមានបន្តទៀតនៅក្នុងការឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០១៨ ។ ហើយចំនួនតិចតួចនេះ នឹងរុញច្រានឲ្យរដ្ឋាភិបាលបរាជ័យម្តងទៀតចំពោះគោលដៅជំរុញឲ្យស្ត្រី និងបុរសមានចំនួនស្មើគ្នានៅក្នុងជួរអ្នកដឹកនាំ និងធ្វើសេចក្តីសម្រេច ពីព្រោះជារឿងមួយសំខាន់ បើអត់មានស្ត្រីចូលរួម គឺវាបាត់សំឡេងស្ត្រីបាត់ព័ត៌មានពីសង្គម។ វាធ្វើឲ្យការសម្រេចចិត្ត និងការអភិវឌ្ឍរបស់យើងអត់សូវមានប្រសិទ្ធភាព ។ ដូច្នេះ គួរចាប់ផ្តើមគិតគូរពីរឿងហ្នឹង។

យើងដឹងហើយថា ស្ត្រីបានធ្វើកិច្ចការច្រើនក្នុងរយៈពេលចុងក្រោយនេះ សកម្មមែនទែននៅថ្នាក់មូលដ្ឋាន ហើយប្រជាពលរដ្ឋលោកបានស្គាល់ និងឲ្យតម្លៃសកម្មភាពការងាររបស់ស្ត្រីនៅមូលដ្ឋាន ប៉ុន្តែគួរឲ្យសោកស្តាយ ស្ត្រីទាំងនោះមិនត្រូវបានលើកតម្កើងដាក់ឲ្យឈរឈ្មោះជាបេក្ខជននៅលេខរៀងខាងលើដើម្បីមានឱកាសក្លាយជាអ្នកដឹកនាំនៅតាមមូលដ្ឋាន ។ ជាក់ស្តែង បេក្ខជនស្ត្រីបានប្រាប់ឲ្យដឹងថា បន្ទាប់ពីនៅក្នុងបក្សបោះឆ្នោតឲ្យស្ត្រីនោះឈរឈ្មោះនៅលេខរៀងទី៥ហើយ ស្អែកឡើងលេខរៀងទី៥របស់គាត់ត្រូវបានគេដកចេញហើយដាក់ជំនួសដោយបុរស ។ បេក្ខជនស្ត្រីផ្សេងទៀតក៏បានផ្តល់ព័ត៌មានដែរថា ខ្លួន(ស្ត្រី)បាន

ការបោះឆ្នោតគាំទ្រឈរឈ្មោះជាបេក្ខជននៅលេខរៀងទី៤ដែលអាចមានលទ្ធភាពជាប់ឆ្នោត ខណៈដែលបុរសដែលអត់បានឈរឈ្មោះនៅលេខរៀងខាងលើក៏ប្រកាសដើរចេញពីគណបក្ស ដូច្នេះស្ត្រីនោះត្រូវសម្រេចចិត្តដកខ្លួនចេញលះបង់លេខរៀងទី៤របស់ខ្លួនឲ្យទៅបុរសនោះ ហើយសុខចិត្តទៅឈរឈ្មោះនៅលេខរៀងទី៦វិញ ដោយសារតែស្ត្រីនោះបារម្ភអំពីអនាគតគណបក្សរបស់ខ្លួន ប្រសិនបើមានការបែកបាក់គ្នា។ ជាលទ្ធផល ស្ត្រីទាំងនោះមិនបានជាប់ឆ្នោត ។ ករណីនេះកើតឡើង*នៅឃុំប្រធាតុ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ*។

បេក្ខជនស្ត្រីឈរឈ្មោះនៅលេខរៀងទី៣ នៅសង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ មកពីគណបក្សសង្គ្រោះជាតិ **កញ្ញា យ៉េម ខណ្ឌណៃត** ថ្លែងថា *«ស្ត្រីជាពិសេសស្ត្រីវ័យក្មេងដូចកញ្ញា ត្រូវតែស៊ូមតិនៅក្នុងជួរបក្សជាច្រើនលើក ទើបអាចមានការយល់ព្រមក្នុងចំណោមអ្នកដឹកនាំក្នុងបក្ស ។ ពេលខ្លះបុរសកន្លែងដែលគាត់ធ្លាប់អង្គុយ គាត់អត់ចង់ឲ្យយើងអ្នកថ្មីទៅអង្គុយទេ។ អញ្ចឹងបើយើងអត់ធ្វើការតវ៉ាមតិ យើងអត់បានបង្ហាញពីសកម្មភាពយើង យើងអត់បង្ហាញពីសមត្ថភាពយើង គឺយើងមិនអាចមានឱកាសឈរជាបេក្ខជនបានទេ គឺយើងត្រូវការបង្ហាញសមត្ថភាព ចំណេះដឹង និងពីផលលំបាកនៃស្ត្រីបានគាត់ឲ្យយើងឈរ»។* ផ្សាយដោយ វិទ្យុអាស៊ីសេរី (RFA) ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧

ទោះបីជាយ៉ាងនេះក៏ដោយ នៅឃុំ សង្កាត់ខ្លះក៏បានផ្តល់ឱកាសឲ្យស្ត្រីបានឈរឈ្មោះនៅលេខរៀងខាងលើដោយមិនចាំចាច់ប្រកួតប្រជែងដូចជា ទុកលេខរៀងទី៣ ឬទី៥ឲ្យស្ត្រី ។ *(ការផ្សាយរបស់ មណ្ឌលព័ត៌មានស្ត្រីកម្ពុជា ខែមេសា ឆ្នាំ២០១៧ caller Prey Veng)* ។

មុនការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤ និងមុនការចុះបញ្ជីគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា បានបន្តអំពាវនាវជាពាក្យសំដីស្នើទៅគណបក្សនយោបាយដាក់បេក្ខភាពស្ត្រីឈរឈ្មោះបោះឆ្នោតនៅលេខរៀងខាងលើ ឲ្យបានជាប់ឆ្នោត។ ជាមួយគ្នានេះដែរ ក្រុមអង្គការសង្គមស៊ីវិលដែលបានធ្វើការងារសកម្មអំពីស្ត្រីមានឈ្មោះថា "គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ និងក្រុមស្ត្រីដើម្បីទាំងអស់គ្នា" មានដូចជា សីលការ(SILAKA) ខុមហ្វ្រែល(COMFREL) និកហ្វិច(NICFEC) អង្គការយេនឌ័រ និងអភិវឌ្ឍដើម្បីកម្ពុជា (GADC) មណ្ឌលព័ត៌មានស្ត្រីកម្ពុជា(WMC) ប៉ាឌិក(PADEK) ឌីភីអេ(DPA) និងអង្គការ-សមាគម អង្គការដៃគូអភិវឌ្ឍន៍មួយចំនួនទៀត បានស្នើធ្វើវិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ **ជំពូកទី៤ មាត្រា៣៧ថ្មី** ***«បញ្ជីបេក្ខជនឈរ ឈ្មោះតាមមណ្ឌលនីមួយៗ ត្រូវមានបេក្ខជនស្ត្រី និងបេក្ខជនបុរសឆ្លាស់គ្នាតាមលំដាប់លេខរៀងពីលើដល់ក្រោម»*** និងច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ **ជំពូកទី៧ មាត្រា៤៩ថ្មី** ***«បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ត្រូវមានឈ្មោះបេក្ខជនតាមលំដាប់លេខរៀង និងឆ្លាស់គ្នារវាងស្ត្រី និងបុរសពីលើដល់ក្រោម»*** ក្នុងបំណងធានាថា

បេក្ខភាពស្ត្រីត្រូវបានឈរឈ្មោះក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ដោយដាក់ឆ្លាស់គ្នារវាងស្ត្រី និងបុរសតាមលំដាប់លេខរៀងពីលើដល់ក្រោម ដែលជាវិធានការសមស្រប និងមានប្រសិទ្ធភាពបំផុតក្នុងការធ្វើឲ្យមានសមភាពយេនឌ័រពិតប្រាកដ ។

ជាមួយគ្នានេះដែរ សមាជិកនៃគណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ ដូចជា អង្គការសីលការ(SILAKA) សហការជាមួយអង្គការសមាជិកមួយចំនួន មានខុមហ្វ្រែលបានផ្តល់វគ្គបណ្តុះបណ្តាលដល់សកម្មជនគណបក្សដែលមានអាសនៈនៅក្នុងសភា គឺ គណបក្សប្រជាជនកម្ពុជា (CPP) និងគណបក្សសង្គ្រោះជាតិ (CNRP) ក្នុងគោលបំណងអភិវឌ្ឍន៍សមត្ថភាពរបស់ស្ត្រី និងបង្កើនភាពអង់អាចក្លាហានចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតឃុំ-សង្កាត់ អាណត្តិទី៤នេះ ។

**តារាងទី១៖ ចំនួនបេក្ខជនស្ត្រីឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ពីអាណត្តិទី១ ដល់អាណត្តិទី៤**

| ឆ្នាំ | ២០០២ | ២០០៧ | ២០១២ | ២០១៧ |
|---|---|---|---|---|
| ចំនួនគណបក្ស | ៨ | ១២ | ១០ | ១២ |
| បេក្ខជនស្ត្រី | ១២ ៣៧៥ | ២១ ៨៤០ | ២៨ ៩៨១ | ២៥ ៧៨៨ |
| ពេញសិទ្ធិ | ១៦,២៨% | ២១,៣៦% | ២៥,៦៤% | ២៧,២៦% |

**តារាងទី២៖ ចំនួនបេក្ខជនស្ត្រីឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ ទាំង១២គណបក្ស**

| ល.រ | គណបក្ស | បេក្ខជនឈរឈ្មោះពេញសិទ្ធិ | | | បេក្ខជនឈរឈ្មោះបម្រុង | | | ចំនួន ឃុំ សង្កាត់ |
|---|---|---|---|---|---|---|---|---|
| | | បេក្ខជន សរុប (ស្រី-ប្រុស) | ស្ត្រី | | បេក្ខជន សរុប (ស្រី-ប្រុស) | ស្ត្រី | | |
| | | | ចំនួន | % | | ចំនួន | % | |
| ១ | ប្រជាជនកម្ពុជា | ២៧ ១១៤ | ៦ ០១៧ | ២២,១៩% | ១៥ ៥៤២ | ៣ ៣៧៣ | ២១,៧០% | ១ ៦៤៦ |
| ២ | សង្គ្រោះជាតិ | ២៥ ៩៨៧ | ៤ ០៩១ | ១៦,០៥% | ១៣ ៩១៥ | ២ ៤៤៤ | ១៧,៥៦% | ១ ៦៩៦ |
| ៣ | ហ៊្វុនស៊ិនប៉ិច | ១២ ៧៦២ | ៤ ៨៥៨ | ៣៨,០៦% | ៦ ៥៥៨ | ៣ ១៨៦ | ៤៨,៥៨% | ៨៤៦ |
| ៤ | សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ១២ ៦៧៤ | ៤ ២៣៣ | ៣៣,៣៩% | ៦ ៣៨៤ | ២ ៨៩៣ | ៤៥,៣១% | ៨៤៤ |
| ៥ | ខ្មែររួបរួមជាតិ | ១០ ៩១៧ | ៤ ១៨០ | ៤០,១២% | ៥ ៣៤៨ | ២ ៥៦៥ | ៤៧,៩៦% | ៧១៣ |
| ៦ | សំបុកឃ្មុំសង្គមប្រជាធិ | ៣ ៩៩១ | ១ ៥២៩ | ៣៨,៣១% | ២ ០៨៣ | ១ ០២៦ | ៤៩,២៥% | ២៥០ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | បតេយ្យ | | | | | | | |
| ៧ | សញ្ជាតិកម្ពុជា | ៧៩៦ | ៤២០ | ៥២,៧៦% | ៤០៦ | ២៤៩ | ៦១,៣៣% | ៥២ |
| ៨ | ប្រជាធិបតេយ្យមូលដ្ឋាន | ៤១១ | ១០៩ | ២៦,៥២% | ២២៤ | ៦៦ | ២៩,៤៦% | ២៧ |
| ៩ | យុវជនកម្ពុជា | ៣៣៨ | ១៦១ | ៤៧,៦៣% | ១៦៩ | ៩១ | ៥៣,៨៤% | ១៩ |
| ១០ | ជនជាតិដើមប្រជាធិបតេយ្យកម្ពុជា | ១៨០ | ៣៨ | ២១,១១% | ៩១ | ២០ | ២១,៩៧% | ១៧ |
| ១១ | អំណាចខ្មែរ | ២១៨ | ៦៨ | ៣១,១៩% | ១១០ | ៤៣ | ៣៩,០៩% | ១៦ |
| ១២ | សាធារណរដ្ឋប្រជាធិបតេយ្យ | ២០៧ | ៨៤ | ៤០,៥៧% | ១០៥ | ៥៥ | ៥២,៣៨% | ១៤ |
| សរុប | | ៩៤ ៥៩៥ | **២៥ ៧៨៨** | **២៧,២៦%** | **៥០ ៩៣៥** | **១៦ ០១១** | **៣១,៤៣%** | |

យោងតាមលទ្ធផលផ្លូវការនៃការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយរបស់គ.ជ.ប កាលពីថ្ងៃ១៨ ខែមេសា ឆ្នាំ២០១៧សម្រាប់ឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤នេះ មានបេក្ខជនស្រី-ប្រុសប្រកួតប្រជែងសរុបចំនួន ៩៤ ៥៩៥ (បេក្ខជនពេញសិទ្ធិ) ក្នុងនោះបេក្ខជនស្ត្រីមានចំនួន **២៥ ៧៨៨នាក់ (២៧,២៦%)** ខណៈដែលបេក្ខជនស្ត្រីឈរឈ្មោះបំរុងមានភាគរយច្រើនជាង គឺ **៣១,៤៣%** មកពីគណបក្សនយោបាយចំនួន**១២** និងមានតែគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិប៉ុណ្ណោះដែលបានរៀបចំបញ្ជីបេក្ខជនឈរឈ្មោះនៅទូទាំងប្រទេស ១៦៤៦ឃុំ សង្កាត់។ តួលេខនេះ មានការកើនតិចតួច **១,៦២%** ធៀបនឹងឆ្នាំ២០១២ មានចំនួន ២៥,៦៤% ។

គួរកត់សម្គាល់ថា សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤ ឆ្នាំ២០១៧នេះ គណបក្សកាន់អំណាច (គណបក្សប្រជាជនកម្ពុជា) និងគណបក្សប្រឆាំង (គណបក្សសង្គ្រោះជាតិ) បានដាក់បេក្ខជនស្ត្រីឈរឈ្មោះភាគរយតិចជាងគេដែលសុទ្ធសឹងជាគណបក្សមានប្រជាប្រិយភាពខ្លាំង ។ ជាក់ស្តែង គណបក្សសង្គ្រោះជាតិមានបេក្ខជនស្ត្រីចំនួនតែ **១៦,០៥%** និងគណបក្សប្រជាជនកម្ពុជា មានបេក្ខជនស្ត្រីចំនួន **២២,១៩%** គឺប្រហាក់ប្រហែលអាណត្តិទី៣ ឆ្នាំ២០១២ ចំនួន២២,៤៦% ។ ចំណែកឯ គណបក្សដែលពុំសូវមានប្រជាប្រិយភាពបានខិតខំដាក់បេក្ខជនស្ត្រីឈរឈ្មោះច្រើនដូចជា គណបក្សសញ្ជាតិកម្ពុជាចំនួន **៥២,៧៦%** គណបក្សយុវជនកម្ពុជាចំនួន**៤៧,៦៣%** គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យចំនួន **៤០,៥៧%** គណបក្សខ្មែររួបរួមជាតិចំនួន**៤០,១២%** គណបក្សសំបុកឃ្មុំប្រជាធិបតេយ្យចំនួន**៣៨,៣១%** គណបក្សហ្វ៊ុនស៊ិនប៉ិចចំនួន**៣៨,០៦%** គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ចំនួន**៣៣,៤០%** និង គណបក្សអំណាចខ្មែរចំនួន**៣១,១៩%**។

ខេត្ត រាជធានីដែលមានភាគរយបេក្ខជនស្ត្រីច្រើនជាងគេ ដូចជា **រាជធានីភ្នំពេញចំនួន៣២,៧៩% ខេត្តប៉ៃលិនចំនួន៣១,៥៣% ខេត្តកែបចំនួន៣០,៨០% ខេត្តបាត់ដំបងចំនួន៣០,៦២%** និង**ខេត្តត្បូងឃ្មុំ** ចំនួន**៣០,៣៩%** ។ *(សូមមើលឧបសម្ព័ន្ធ ១ស្តីពី ចំនួនបេក្ខជនស្ត្រីឈរឈ្មោះតាមខេត្ត)*

**តារាងទី៣៖ ចំនួនបេក្ខជនស្ត្រីឈរឈ្មោះពីលេខរៀងទី១ ដល់ ទី៣ សម្រាប់ការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧**

| ល.រ | គណបក្សនយោបាយ | បេក្ខជនស្ត្រីឈរឈ្មោះពេញសិទ្ធិ | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | #សរុប | % | ល.រទី១ | % | ល.រទី២ | % | ល.រទី៣ | % |
| ១ | ប្រជាជនកម្ពុជា | ៦០១៧ | ២២,១៩% | ១៣១ | ៧,៩៦% | ២៨៩ | ១៧,៥៦% | ៤៧១ | ២៨,៦១% |
| ២ | សង្គ្រោះជាតិ | ៤០៩១ | ១៦,០៥% | ១០៣ | ៦,២៥% | ១៥១ | ៩,១៧% | ២៤៥ | ១៤,៨៨% |
| ៣ | ហ្វ៊ុនស៊ិនប៉ិច | ៤៨៥៨ | ៣៨,០៦% | ៦៥ | ៧,៦៨% | ១៤០ | ១៦,៥៤% | ២១៤ | ២៥,២៩ |
| ៤ | សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ៤២៣៣ | ៣៣,៤០% | ៥៧ | ៦,៧៥% | ៩៨ | ១១,៦១% | ១៤១ | ១៦,៧០% |
| ៥ | ខ្មែររួបរួមជាតិ | ៤១៨០ | ៤០,១២% | ៨៣ | ១១,៦៤% | ១៤៥ | ២០,៣៤% | ១៩១ | ២៦,៧៩% |
| ៦ | សំបុកឃ្មុំសង្គមប្រជាធិបតេយ្យ | ១៥២៩ | ៣៨,៣១% | ២៣ | ៩,២០% | ៣៧ | ១៤,៨០% | ៥៥ | ២២% |
| ៧ | សញ្ញាតិកម្ពុជា | ៤២០ | ៥២,៧៦% | ៧ | ១២,៩៦% | ១៦ | ២៩,៦៣% | ១៩ | ៣៥,១៨% |
| ៨ | ប្រជាធិបតេយ្យមូលដ្ឋាន | ១០៩ | ២៦,៥២% | ២ | ៧,៤១% | ៧ | ២៥,៩៣% | ៦ | ២២,២២% |
| ៩ | យុវជនកម្ពុជា | ១៦១ | ៤៧,៦៣ | ២ | ១០,៥៣% | ៦ | ៣១,៥៨% | ៩ | ៤៧,៣៧% |
| ១០ | ជនជាតិដើមប្រជាធិបតេយ្យកម្ពុជា | ៣៨ | ២១,១១% | ៤ | ២៣,៥៣% | ១ | ៥,៨៨% | ៤ | ២៣,៥៣% |
| ១១ | អំណាចខ្មែរ | ៦៨ | ៣១,១៩% | ២ | ១២,៥០% | ៤ | ២៥% | ៣ | ១៨,៧៥% |
| ១២ | សាធារណរដ្ឋប្រជាធិបតេយ្យ | ៨៤ | ៤០,៥៧% | ២ | ១៤,២៨% | ៣ | ២១,៤៣% | ២ | ១៤,២៨% |
| **សរុប** | **១២ គណបក្ស** | **២៥ ៧៨៨** | **២៧,២៦%** | **៤៨១** | **៧,៨៩%** | **៨៩៧** | **១៤,៧២%** | **១៣៦០** | **២២,៣២%** |

បើទោះបី ចំនួនស្ត្រីឈរឈ្មោះអាណត្តិទី៤នេះនៅតែមានចំនួនតិចតួច ប៉ុន្តែបេក្ខជនស្ត្រីឈរឈ្មោះនៅ**លេខរៀងទី១**មានចំនួនច្រើនជាងមុនគួរឲ្យកត់សម្គាល់ ជាពិសេសគណបក្សដែលមានអាសនៈនៅក្នុងសភា និងមានប្រជាប្រិយភាពខ្លាំង ដូចជា គណបក្សប្រជាជនកម្ពុជាបានខិតខំដាក់បេក្ខជនស្ត្រីឈរឈ្មោះនៅលេខរៀងទី១ចំនួន**១៣១នាក់ (៧,៩៦%)** គឺ**កើនចំនួន ៣៨នាក់** ធៀបនឹងឆ្នាំ២០១២មានចំនួនតែ ៩៣នាក់

(៥,៦៩%) ខណៈដែលគណបក្សសង្គ្រោះជាតិមានចំនួន **១០៣នាក់ (៦,២៥%)** គឺ **កើនប្រមាណ ១៥នាក់** (ដោយគិតជាមធ្យមភាគរវាងគណបក្សសម រង្ស៊ី និងគណបក្សសិទ្ធិមនុស្សឆ្នាំ២០១២មានចំនួនតែ៨៧នាក់)។ បេក្ខជនស្ត្រីឈរឈ្មោះនៅលេខរៀងទី១ក៏ត្រូវបានបង្កើនដោយគណបក្សផ្សេងៗទៀតផងដែរ ។

គួរបញ្ជាក់ផងដែរ បេក្ខជនស្ត្រីឈរឈ្មោះនៅ**លេខរៀងទី១**មានសរុបចំនួន**៤៨១នាក់ (៧,៨៩%)**នៃបេក្ខជនលេខរៀងទី១ប្រុស-ស្រីសរុប ៦ ០៩២នាក់ គឺមានភាគរយ**កើនបន្តិច ១,១៧%** ធៀបនឹងឆ្នាំ២០១២ មានចំនួន ៦,៧២% ។ ចំណែកឯបេក្ខជនស្ត្រីឈរឈ្មោះនៅលំដាប់លេខរៀងចាប់ពី**ទី១ ដល់ទី៣**មានចំនួន **២ ៧៣៨នាក់ (១៤,៩៨%)**នៃគណបក្សទាំង១២ គឺ **កើន៤១៦នាក់** ធៀបនឹងអាណត្តិទី២ឆ្នាំ២០០៧ មានចំនួនតែ២៣២២នាក់ ប៉ុណ្ណោះ ។ រីឯ បេក្ខជនស្ត្រីឈរឈ្មោះនៅលំដាប់លេខរៀងចាប់ពី**ទី១ ដល់ទី៥** មានចំនួនច្រើនបង្គួរ **៨ ៨៥៦នាក់ (២៩,០៧%)**[1] ។

ថ្វីបើចំនួនបេក្ខជនស្ត្រីឈរឈ្មោះមានការកើនឡើងពីអាណត្តិមួយទៅអាណត្តិមួយក៏ដោយ ក៏តួលេខនេះនៅតែជាចំនួនតិចតួច ខណៈដែលបេក្ខជនបុរសនៅតែមានចំនួនច្រើនលើសលុបដដែល ។ នេះបង្ហាញឲ្យឃើញថា កម្ពុជានៅតែបន្តបញ្ហាអតុល្យភាពនៃការអនុវត្តសិទ្ធិ និងអំណាចនយោបាយរវាងបុរស និងស្ត្រី ។ បើទោះបីកម្ពុជាទទួលយកនូវវិធានការពិសេសដូចជា អនុសញ្ញាអន្តរជាតិស៊ីដ-ដរ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងផែនការអភិវឌ្ឍជាតិដើម្បីលើកកម្ពស់ និងផ្តល់ឱកាសឲ្យស្ត្រីចូលរួមសកម្ម និងស្មើភាពរវាងស្ត្រី-បុរសទាំងបរិមាណ និងសិទ្ធិអំណាចក៏ដោយ។

យោងតាមរបាយការណ៍វាយតម្លៃរបស់ខុមហ្វ្រែល ស្តីពី «ការចូលរួមនយោបាយរបស់ស្ត្រីក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១៧» ស្ត្រីនៅតែ**ភ័យខ្លាច**ក្នុងការភ្ជាប់ខ្លួនជាមួយនឹងកិច្ចការនយោបាយ និងការបោះឆ្នោត ។ ពួកគេមានការភ័យខ្លាចចម្បងៗចំនួន៣៖ ***ខ្លាចទី១៖*** *ខ្វះនូវគោលនយោបាយជាក់លាក់ជាលាយលក្ខណ៍អក្សរដែលជាវិធានការពិសេសបណ្តោះអាសន្ន និងមាត្រាមួយចំនួននៃច្បាប់បោះឆ្នោត ដើម្បីគាំទ្រ និងផ្តល់ឱកាសឲ្យស្ត្រី-បុរសចូលរួមស្មើគ្នាក្នុងវិស័យនយោបាយ ជាពិសេសការឈរឈ្មោះជាបេក្ខជន ។* ***ខ្លាចទី២៖*** *បន្តការរើសអើងប្រឆាំងនឹងស្ត្រីក្នុងដំណើរការបោះឆ្នោតជ្រើសរើសបេក្ខជននៅក្នុងគណបក្សនយោបាយ និង**ខ្លាចទី៣៖** បរិយាកាសនយោបាយក្នុងអំឡុងពេលដំណើរការនៃការបោះឆ្នោតម្តងៗឃើញមានការគំរាមកំហែង និងបញ្ហាជាច្រើនទៀតដែលធ្វើឲ្យមានឥទ្ធិពលអវិជ្ជមានដល់ស្ត្រី និងធ្វើឲ្យពួកគេរារែកក្នុងការចូលរួមក្នុងវិស័យនយោបាយ។*

[1] គដបបានសហការយ៉ាងជិតស្និទ្ធជាមួយក្រុមការងារស្ត្រីរបស់អង្គការសង្គមស៊ីវិលក្នុងការផ្តល់នូវតួលេខស្ត្រីថ្មីៗជាបន្តបន្ទាប់

មានបេក្ខជនស្រ្តី និងគណបក្សនយោបាយមួយចំនួនបានឲ្យអ្នកសង្កេតការណ៍ដឹងថា ការរើសអើងប្រឆាំងនឹងបេក្ខជនស្រ្តីដែលពួកគេជួបប្រទះ គឺក្នុងពេលដំណើរការតែងតាំងបេក្ខជន និងការបោះឆ្នោតជ្រើសរើសបេក្ខជននៅក្នុងគណបក្ស ។ កត្តាផ្សេងទៀតត្រូវបានរកឃើញថា ការជ្រើសរើសបេក្ខជនស្រ្តីនៅជួរលើនៃបញ្ជីបេក្ខជនឈរឈ្មោះ គឺប្រឆាំងទៅនឹងបេក្ខភាពបុរស ។ គណបក្សខ្លះបានវិនិច្ឆ័យទុកជាមុនថា ការដាក់បេក្ខភាពមេឃុំ ចៅសង្កាត់ជាស្រ្តី គឺពុំសូវទាក់ទាញអ្នកបោះឆ្នោត ព្រោះអាចមិនមែនជាទម្លាប់ជម្រើសរបស់ប្រជាពលរដ្ឋខ្មែរទេ ។ គណបក្សនយោបាយខ្លះ ដូចជា គណបក្សសង្គ្រោះជាតិបានលើកឡើងអំពីការជ្រើសរើសបេក្ខជន ឬ បេក្ខនារីសម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយតាមគោលការណ៍ប្រជាធិបតេយ្យផ្ទៃក្នុងដែលសមាជិកគណបក្សតាមមណ្ឌលឃុំ សង្កាត់នីមួយៗជាអ្នកបោះឆ្នោតទុកចិត្តបេក្ខភាពទាំងនោះសម្រាប់បញ្ជីបេក្ខភាពនៃគណបក្សរបស់ខ្លួន ប៉ុន្តែក៏មានការអន្តរាគមន៍ពីរចនាសម្ព័ន្ធគណបក្សថ្នាក់លើទាក់ទងនឹងការដាក់បេក្ខជនស្រ្តីនៅលេខរៀងទី១ ផងដែរ ។ ចំណែកឯ គណបក្សប្រជាជនកម្ពុជាក៏មិនខុសពីគណបក្សសង្គ្រោះជាតិដែរ បានផ្តល់ការសម្រេចចិត្តក្នុងការជ្រើសរើសបេក្ខភាពទៅគណបក្សថ្នាក់មូលដ្ឋានតាមរយៈការបោះឆ្នោតជ្រើសរើសជាមុន ប៉ុន្តែមានការអន្តរាគមន៍ពីរចនាសម្ព័ន្ធគណបក្សថ្នាក់លើផងដែរ។ ការប្រើប្រាស់គោលការណ៍ប្រជាធិបតេយ្យផ្ទៃក្នុងគណបក្ស ក៏បានបង្កើតការប្រឈមមួយសម្រាប់បេក្ខភាពនារីដែលសមាជិកបក្សមិនបានទុកចិត្តបោះឆ្នោតជូនបេក្ខនារី ។

## ២- ស្រ្តីជាប់ឆ្នោត

### ក្រាហ្វិកទី៤៖ ភាគរយស្រ្តីជាប់ឆ្នោត អាណត្តិទី៤ ឆ្នាំ២០១៧



ក្រាហ្វិកទី៩បង្ហាញថា ភាគរយស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ មានចំនួន **១៦,៧៦%** ស្មើនឹង**១ ៩៤០នាក់** ខណៈដែលបុរសជាប់ឆ្នោតមានចំនួនច្រើនបំផុត **៨៣,២៤%** ស្មើនឹង **៩ ៦៣២នាក់** ។ ចំនួននេះបង្ហាញឲ្យឃើញថា ភាគរយស្ត្រីជាប់ឆ្នោតមានតិចតួច ចំណែកឯបុរសមានច្រើនលើសលុប ដែលបញ្ជាក់ឲ្យឃើញពីការមិនសូវគិតគូរអំពីការលើកស្ទួយស្ត្រីចូលរួមក្នុងវិស័យនយោបាយ និងថ្នាក់សម្រេចចិត្ត ដែលជាហេតុធ្វើឲ្យមានគំលាតយេនឌ័រយ៉ាងធំ ។

**តារាងទី៥៖ ចំនួនស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧**

| គណបក្ស | ស្ត្រីជាប់ឆ្នោត អាណត្តិទី៤ | | | | | | | | | | អាសនៈទទួលបាន |
|---|---|---|---|---|---|---|---|---|---|---|---|
| | ចំនួនសរុប | % | មេឃុំ ចៅសង្កាត់ | | ជំទប់ទី១ ចៅសង្កាត់រងទី១ | | ជំទប់ទី២ ចៅសង្កាត់រងទី២ | | សមាជិក | | |
| | | | # | % | # | % | # | % | # | % | |
| ប្រជាជនកម្ពុជា | ១ ៣៨៧ | ២១,៣៣% | ៩២ | ៧,៩៦% | ១៩២ | ១៦,៨៥% | ៤៨ | ៩,៤១% | ១ ០៥៥ | ២៨,៥៣% | ៦ ៥០៣ |
| សង្គ្រោះជាតិ | ៥៥៣ | ១១,០៤% | ៣៦ | ៧,៣៦% | ៤២ | ៨,៣៥% | ៦៧ | ៦,១៦% | ៤០៨ | ១៣,៩៣% | ៥ ០០៧ |
| ហ៊្វុនស៊ិនប៉ិច | | | | | | | | | | | ២៨ |
| សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | | | | | | | | | | | ៤ |
| ខ្មែររួបរួមជាតិ | | | | | | | | | | | ២៤ |
| សំបុកឃ្មុំសង្គមប្រជាធិបតេយ្យ | | | | | | | | | | | ១ |
| សញ្ជាតិកម្ពុជា | | | | | | | | | | | |
| ប្រជាធិបតេយ្យមូលដ្ឋាន | | | | | | | | | | | ៥ |
| យុវជនកម្ពុជា | | | | | | | | | | | |
| ជនជាតិដើមប្រជាធិបតេយ្យកម្ពុជា | | | | | | | | | | | |
| អំណាចខ្មែរ | | | | | | | | | | | |
| សាធារណរដ្ឋប្រជាធិបតេយ្យ | | | | | | | | | | | |
| **សរុបរួម** | ១ ៩៤០ | ១៦,៧៦% | ១២៨ | ៧,៧៧% | ២៣៤ | ១៤,២២% | ១១៥ | ៧% | ១ ៤៦៣ | ២២,០៥% | ១១ ៥៧២ |

យោងតាមលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ដោយគជបកាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៧ បានបង្ហាញថា ចំនួនស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់ មានការ **ថយចុះបន្តិច ១,០២% (៩៨នាក់)** ពី ១៧,៧៨% (២ ០៣៨នាក់) ឆ្នាំ២០១២ (ជាប់ឆ្នោតភ្លាម) មកត្រឹម

១៦,៧៦% (១ ៩៤០នាក់) ឆ្នាំ២០១៧នៃចំនួនអ្នកជាប់ឆ្នោតស្រី-ប្រុសសរុប ១១ ៥៧២នាក់ និង**ថយចុះ ១,១៣% ឬ ១១១នាក់** បើធៀបនឹងចុងអាណត្តិទី៣ចំនួនស្ត្រី២០៥១នាក់ (១៧,៨៩%) ។ ប៉ុន្តែមានការ**កើនឡើង**ចំនួន**មេឃុំ ចៅសង្កាត់ស្ត្រី ១,៩៦% (៣៣នាក់)** ពី ៥,៨១% (៩៥នាក់) ឆ្នាំ២០១២ (ជាប់ឆ្នោតភ្លាម) ទៅ **៧,៧៧% (១២៨នាក់)** ឆ្នាំ២០១៧ និង**កើន** ចំនួនតែ**១,១៦% ឬ ២០នាក់** បើធៀបនឹងចុងអាណត្តិទី៣ មេឃុំស្ត្រីចំនួន ១០៨នាក់ (៦,៦១%) ។

គណបក្សពីរ គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិទទួលបានសម្លេងឆ្នោតគាំទ្រពីអ្នកបោះឆ្នោត និងមានស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សា ឃុំ សង្កាត់ គឺ គណបក្សប្រជាជនកម្ពុជា មានស្ត្រីចំនួន **១ ៣៨៧នាក់ (២១,៣៣%)** ក្នុងនោះមេឃុំ ចៅសង្កាត់ស្ត្រីចំនួន**៩២នាក់ (៧,៩៦%)** ខណៈដែលគណបក្សសង្គ្រោះជាតិមានស្ត្រីចំនួន **៥៥៣នាក់ (១១,០៤%)** និង **៣៦នាក់ (៧,៣៦%)**ជាមេឃុំ ចៅសង្កាត់ស្ត្រី ។

តួលេខនេះបង្ហាញថា កម្ពុជានឹងអាចប្រឈមក្នុងការធ្វើឲ្យបានសម្រេចតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព(SDG) ដែលបានកំណត់នៅឆ្នាំ២០៣០ ថា ***«ធ្វើឲ្យសម្រេចសមភាពយេនឌ័រ និងផ្តល់អំណាចដល់ស្ត្រី និងកុមារីទាំងអស់ក្នុងលោក»*** នៅគ្រប់ថ្នាក់សម្រេចចិត្ត។ ដូច្នេះ រាជរដ្ឋាភិបាលកម្ពុជា ត្រូវបង្កើត និងអនុវត្តវិធានការពិសេសជាក់លាក់មួយចំនួនចាប់តាំងពីពេលនេះតទៅ ដើម្បីបង្កើនចំនួនស្ត្រីជាអ្នកដឹកនាំ ជៀសវាងការបរាជ័យដូចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (CMDG) ។ ក្រៅពីខិតខំប្រឹងប្រែងបង្កើនចំនួនស្ត្រី ការយកចិត្តទុកដាក់ទៅលើគុណភាពនៃការចូលរួមរបស់ស្ត្រីកាន់តែជារឿងសំខាន់ គឺត្រូវធ្វើយ៉ាងណាឲ្យស្ត្រីមានសម្លេងក្នុងការសម្រេចចិត្ត និងផ្តល់តួនាទី សិទ្ធិអំណាចឲ្យបានពេញលេញក្នុងពេលបំពេញការងារដោយគ្មានការរើសអើងពីសំណាក់បុរសដែលជាសហការី និងអ្នកដឹកនាំ ។

ខេត្ត រាជធានីដែលមានភាគរយស្ត្រីជាប់ឆ្នោតច្រើនជាងគេ ដូចជា **ខេត្តប៉ៃលិនចំនួន២៨,៨៥% ខេត្តឧត្តរមានជ័យចំនួន២៣,៦៨% រាជធានីភ្នំពេញចំនួន២៣,០២% ខេត្តកែបចំនួន២២,៥៨% ខេត្តស្ទឹងត្រែងចំនួន២១,៥៩% ខេត្តក្រចេះចំនួន២១,០២%** និង**ខេត្តកោះកុងចំនួន២០,៣៦%** ។ *(សូមមើលឧបសម្ព័ន្ធ២ ស្តីពី ចំនួនស្ត្រីជាប់ឆ្នោតតាមរាជធានី-ខេត្ត)*

ឃុំ សង្កាត់ដែល**គ្មានស្ត្រី**ជាប់ឆ្នោតជាក្រុមប្រឹក្សា អាណត្តិទី៤នេះ មានចំនួន **៣៤៤ឃុំ សង្កាត់** ក្នុងស្រុក ខណ្ឌចំនួន១៩៦ នៅទូទាំង២៥រាជធានី ខេត្ត ។ ខេត្ត រាជធានីដែល**មិនមានស្ត្រី**ជាក្រុមប្រឹក្សាឃុំ សង្កាត់ ច្រើនជាងគេ គឺ៖ **ខេត្តព្រះសីហនុ**ចំនួន៣៩,៤៨% **ខេត្តកំពង់ចាម**ចំនួន៣៣,០៣% **ខេត្តកំពង់ឆ្នាំង**ចំនួន២៨,៥៧% **ខេត្តតាកែវ**ចំនួន២៨% **ខេត្តសៀមរាប និងខេត្តត្បូងឃ្មុំ**ចំនួន២៥% **ខេត្តព្រៃវែង**ចំនួន២៣,២៨% និង**ខេត្តកណ្តាល**ចំនួន២២,៨៣% ។ *(ព័ត៌មានលម្អិតសូមមើលឧបសម្ព័ន្ធ៣)*

## ក្រាហ្វិកទី៦៖ តួនាទីរបស់ស្ត្រីជាប់ឆ្នោត អាណត្តិទី៤ ឆ្នាំ២០១៧




មេឃុំ ចៅសង្កាត់ស្ត្រីសរុបចំនួន **១២៨នាក់ (៧,៧៧%) កើន ១,៩៦% (៣៣នាក់)** ធៀបនឹងឆ្នាំ២០១២ មានចំនួនតែ ៥,៨១% (៩៥នាក់) ។ ស្ត្រីជាជំទប់ទី១/ចៅសង្កាត់រងទី១សរុបចំនួន**២៣៤នាក់ (១៤,២២%) កើន**ចំនួន**២,៦៥% (៤៥នាក់)** ធៀបនឹងឆ្នាំ២០១២មានចំនួនតែ ១៨៩នាក់ (១១,៥៧%) ។ ស្ត្រីជាជំទប់ទី២/ចៅសង្កាត់រងទី២សរុបចំនួន **១១៥នាក់ (៧%) ថយចុះ ៣,០៤% (៤៩នាក់)** ធៀបនឹងឆ្នាំ២០១២ មានចំនួន១៦៤នាក់ (១០,០៤%) ។ ស្ត្រីជាសមាជិកសរុបចំនួន **១ ៤៦៣នាក់ (២២,០៥%) ថយចុះ ២,១៨% (១២៧នាក់)** ធៀបនឹងឆ្នាំ២០១២ មានចំនួន ១ ៥៩០នាក់ (២៤,២៣%) ។

## ក្រាហ្វិកទី៧៖ ប្រៀបធៀបតួនាទីរបស់ស្ត្រីជាប់ឆ្នោតនៃគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ អាណត្តិទី៤ ឆ្នាំ២០១៧



មេឃុំ ចៅសង្កាត់ស្ត្រីរបស់គណបក្សប្រជាជនកម្ពុជាសរុបចំនួន **៩២នាក់ (៧,៩៦%) ច្រើនជាង** គណបក្សសង្គ្រោះជាតិដែលមានចំនួនសរុបតែ **៣៦នាក់ (៧,៣៦%)** ។ ស្ត្រីជាជំទប់ទី១/ចៅសង្កាត់រងទី១ របស់គណបក្សប្រជាជនកម្ពុជាសរុប ចំនួន**១៩២នាក់ (១៦,៨៥%)** ខណៈដែលគណបក្សសង្គ្រោះជាតិសរុប ចំនួន **៤២នាក់ (៨,៣៥%)** គឺ**តិចជាង**គណបក្សប្រជាជនកម្ពុជា**២ដង**។ ស្ត្រីជាជំទប់ទី២/ចៅសង្កាត់រងទី២ របស់គណបក្សប្រជាជនកម្ពុជាមានភាគរយសរុប **៩,៤១% (៨៨នាក់) ច្រើនជាង**គណបក្សសង្គ្រោះជាតិ ដែលមានភាគរយសរុប **៦,១៦% (៦៧នាក់)** ។ ដោយឡែក ស្ត្រីជាសមាជិករបស់គណបក្សប្រជាជនកម្ពុជា សរុបចំនួន **១ ០៥៥នាក់ (២៨,៥៣%) ច្រើនលើសលុបជាង**គណបក្សសង្គ្រោះជាតិដែលមានចំនួន សរុបតែ **៨០៨នាក់ (១៣,៩៣នាក់)** ប៉ុណ្ណោះ ។

## ក្រាហ្វិកទី៨៖ មេឃុំ ចៅសង្កាត់ស្ត្រីតាមវ័យ និងតាមតំបន់ អាណត្តិទី៤ ឆ្នាំ២០១៧




ក្រាហ្វិកទី៨បង្ហាញថា ក្នុងចំណោមមេឃុំ ចៅសង្កាត់ស្ត្រី១២៨នាក់ មានស្ត្រីមេឃុំ ចៅសង្កាត់ថ្មី **ចំនួន ៥១នាក់ ស្មើនឹង៣៩,៨១%**នៃមេឃុំ ចៅសង្កាត់ស្ត្រីសរុប [ *ស្ត្រីវ័យក្មេងមានចំនួន៨នាក់(៦,២៥%) និងស្ត្រីវ័យចំណាស់មានចំនួន៤៣នាក់(៣៣,៥៩%)* ] ។ មេឃុំស្ត្រីនៅ**ឃុំដាច់ស្រយោលមានចំនួន៩នាក់ (៧,០៣%)** ។ មេឃុំស្ត្រីជា**ជនជាតិដើមភាគតិចមានចំនួន២នាក់ (១,៥៦%)** និងមេឃុំ ចៅសង្កាត់ចាស់ជាស្ត្រីវ័យចំណាស់ មានចំនួន **២៥នាក់ (១៩,៥៣%)** ។

គួរកត់សម្គាល់ថា ខេត្តដែលមានស្ត្រីមេឃុំ ចៅសង្កាត់ច្រើនជាងគេ ដូចជា **ខេត្តកណ្តាល**ចំនួន ១៤នាក់ **រាជធានីភ្នំពេញ**ចំនួន១៣នាក់ **ខេត្តបាត់ដំបង**ចំនួន១២នាក់ និង**ខេត្តសៀមរាប**ចំនួន៨នាក់ ។ បើទោះបីចំនួនស្ត្រីមេឃុំ ចៅសង្កាត់ អាណត្តិទី៤នេះមានការកើនឡើងក៏ដោយ ប៉ុន្តែជាចំនួនតិចតួចបំផុត ធៀបនឹងចំនួនមេឃុំ ចៅសង្កាត់សរុប១ ៦៤៦ឃុំ សង្កាត់។ យោងតាមការសិក្សាស្រាវជ្រាវរបស់អង្គការសង្គមស៊ីវិលរកឃើញថា តួនាទីស្ត្រីជាមេឃុំ/ចៅសង្កាត់ធ្វើការមានសិទ្ធិអំណាចពេញលេញ និងធ្វើការមានប្រសិទ្ធភាពជាងស្ត្រីដែលមានតួនាទីជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។

### ក្រាហ្វិកទី៩៖ ស្ត្រីមេឃុំ ចៅសង្កាត់ចាស់ និងថ្មី អាណត្តិទី៤ ឆ្នាំ២០១៧




ក្រាហ្វិកទី៩នេះបង្ហាញឲ្យឃើញថា **ស្ត្រីមេឃុំ ចៅសង្កាត់ថ្មី** (ស្ត្រីដែលទើបតែបានជាប់ឆ្នោតតួនាទីជាមេឃុំ ចៅសង្កាត់លើកដំបូង)មានចំនួនច្រើនលើសលុប **៨៩នាក់** ស្មើនឹង **៦៩,៥៣%** ខណៈដែល**ស្ត្រីមេឃុំ ចៅសង្កាត់ចាស់** (ស្ត្រីដែលធ្លាប់បានតួនាទីជាមេឃុំ ចៅសង្កាត់តាំងពីអាណត្តិមុនៗ) មានចំនួនតែ **៣៩នាក់** ស្មើនឹង **៣០,៤៦%** ប៉ុណ្ណោះ ។ តួលេខនេះបញ្ជាក់ថា ស្ត្រីបានទទួលឱកាសជាអ្នកដឹកនាំនៅថ្នាក់មូលដ្ឋានកាន់តែច្រើនជាងមុន និងបានចាប់យកបទពិសោធន៍នៃការដឹកនាំនៅក្នុងជីវិតនយោបាយរបស់ខ្លួន។

## ក្រាហ្វិកទី១០ ៖ ប្រៀបធៀប ស្ត្រីជាប់ឆ្នោត និងមេឃុំ ចៅសង្កាត់ស្ត្រី ឆ្នាំ២០១២ និង ឆ្នាំ២០១៧




បើប្រៀបធៀបស្ត្រីជាប់ឆ្នោតអាណត្តិទី៣ និងអាណត្តិទី៤ យើងឃើញថា **ចំនួនស្ត្រីជាប់ឆ្នោត**មានការ**ថយចុះ**នៅអាណត្តិទី៤ ឆ្នាំ២០១៧នេះ **ពី ១៧,៧៨% (២ ០៣៨នាក់)** អាណត្តិទី៣ ឆ្នាំ២០១២ មកត្រឹម **១៦,៧៦% (១ ៩៤០នាក់)** អាណត្តិទី៤ ឆ្នាំ២០១៧ ខណៈដែលស្ត្រីបានទទួលតួនាទីជា**មេឃុំ ចៅសង្កាត់** មានការ **កើនឡើង** ពី **៥,៨១% (៩៥នាក់)** ឆ្នាំ២០១២ ទៅ **៧,៧៧% (១២៨នាក់)** ឆ្នាំ២០១៧។

ក្រុមអង្គការសង្គមស៊ីវិលដែលធ្វើការក្នុងការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ ខកចិត្តព្រោះចំនួនស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់មានការថយចុះ ។

**កញ្ញា សេង រាសី** អ្នកសម្របសម្រួលកម្មវិធីលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ និងជាសមាជិកក្រុមស្ត្រីដើម្បីទាំងអស់គ្នា ថ្លែងក្នុងសន្និសីទសារព័ត៌មាននៅរសៀលថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧ ថា *« ការថយចុះចំនួនស្ត្រីនេះនឹងធ្វើឲ្យមានផលប៉ះពាល់ចំនួន បី ធំៗ រួមមាន ៖ (១)ផលប៉ះពាល់ទៅលើគោលដៅរបស់រដ្ឋាភិបាល ។ (២)ប៉ះពាល់ទឹកចិត្តស្ត្រីដែលមានបំណងចូលរួមក្នុងវិស័យនយោបាយ និង(៣)ប៉ះពាល់ដល់ការដោះស្រាយបញ្ហាស្ត្រី និងកុមារ »* ។

ក្រុមអង្គការសង្គមស៊ីវិលបានលើកឡើងថា *«ការធ្លាក់ចុះនៃចំនួនស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់ ដោយសារគណបក្សទាំងពីរដែលដណ្តើមបានអាសនៈឃុំ សង្កាត់ច្រើនបំផុតបានដាក់បេក្ខជនស្ត្រី*

*ភាគរយតិចជាងគេក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ គឺ គណបក្សប្រជាជនកម្ពុជា និង គណបក្សសង្គ្រោះជាតិ »។*

**លោក សុខ ឥសាន្ត** អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជាបានពន្យល់ថា *«ការដាក់បេក្ខភាពស្ត្រី គឺធ្វើតាមគោលការណ៍របស់បក្ស ហើយស្ត្រីត្រូវជ្រើសរើសដោយផ្អែកលើសមត្ថភាពរបស់ពួកគេ»* ។ ផ្សាយដោយ មណ្ឌលព័ត៌មានស្ត្រីកម្ពុជា (WMC) ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧

**លោកស្រី មូរ សុខហួរ** អនុប្រធានគណបក្សសង្គ្រោះជាតិ សារភាពថា *« គណបក្សសង្គ្រោះជាតិពិបាករកស្ត្រីឲ្យបានច្រើនមកឈរឈ្មោះ ។ ប៉ុន្តែលោកស្រីគិតថា វាជាសញ្ញាវិជ្ជមានមួយនៅពេលដែលស្ត្រីបក្សប្រឆាំងបានជាប់ឆ្នោតច្រើនក្នុងការបោះឆ្នោតមូលដ្ឋានលើកនេះ »* ។ ផ្សាយដោយមណ្ឌលព័ត៌មានស្ត្រីកម្ពុជា (WMC) ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧

ចំពោះបញ្ហាថយចុះចំនួនស្ត្រីជាក្រុមប្រឹក្សាឃុំ សង្កាត់នេះ **លោក ថេ ឈុនហាក់** អគ្គនាយករងនៃអគ្គនាយកដ្ឋានសមភាពយេនឌ័រ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចនៃក្រសួងកិច្ចការនារី លើកឡើងថា *«ក្រសួងបានទទួលស្គាល់ថា ចំនួនស្ត្រីអាចនឹងថយចុះបែបនេះតាំងពីបានឃើញបញ្ជីឈ្មោះបេក្ខជនឈរឈ្មោះបោះឆ្នោតមកដែរហើយក្រសួងនឹងយកបទពិសោធនេះរួមនឹងបទពិសោធក្នុងការបោះឆ្នោតជាតិឆ្នាំ២០១៣ ដើម្បីរៀបចំផែនការត្រៀមសម្រាប់ការបោះឆ្នោតជាតិឆ្នាំ២០១៨ខាងមុខ »* ។ ផ្សាយដោយវិទ្យុអាស៊ីសេរី (RFA) ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៧

អនុប្រធានគណបក្សសង្គ្រោះជាតិ **លោកជំទាវ មូរ សុខហួរ** បានលើកឡើងថា *« ការអនុម័តគោលនយោបាយជាលាយលក្ខណ៍អក្សរគឺមានការលំបាក ពីព្រោះសហការីរបស់ខ្ញុំ ជាពិសេស បុរសដែលមានវ័យចំណាស់ៗមិនមានឆន្ទៈចុះចេញពីតំណែងសម្រាប់បេក្ខជនវ័យក្មេងទេ»* ។ ផ្សាយដោយភ្នំពេញប៉ុស្តិ៍ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧

អ្នកសម្របសម្រួលកម្មវិធីអប់រំ និងយេនឌ័រនៃអង្គការខុមហ្វ្រែល និងជាសមាជិកក្រុមស្ត្រីដើម្បីទាំងអស់គ្នា **លោកស្រី សឹនគេត ស៊ីរីលក្ខណ៍** បានមានប្រសាសន៍ថា *« ចំណុចសំខាន់ពីរដែលត្រូវយកចិត្តទុកដាក់គឺ ការធ្វើវិសោធនកម្មច្បាប់បោះឆ្នោត និងត្រូវបង្កើតគោលនយោបាយសមភាពយេនឌ័រនៅក្នុងគណបក្សនីមួយៗ ៖ គិតគូរធ្វើម៉េចឲ្យមាននៅក្នុងច្បាប់បោះឆ្នោតកំណត់ឲ្យច្បាស់ក្នុងការដាក់ស្ត្រីឈរឈ្មោះ*

*ទាល់តែមានការដាក់ ឆ្លាស់គ្នារវាងស្ត្រី-បុរសនៅក្នុងបញ្ជីឈ្មោះបោះឆ្នោតរបស់គណបក្សពីលើដល់ក្រោម ទើបចំនួនស្ត្រីអាចមានការកើនឡើង »* ។ ផ្សាយដោយវិទ្យុអាស៊ីសេរី (RFA) ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៧

មិនខុសពីអាណត្តិទី៣ទេ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤នេះ យើងឃើញមានការភ្ញាក់ផ្អើល ល្បីល្បាញ និងគាំទ្រយ៉ាងខ្លាំងដល់បេក្ខជនស្ត្រីជាប់ឆ្នោតជាមេឃុំស្ត្រីវ័យក្មេង។ **កញ្ញា ស៊ិន ចាន់ពៅរ៉ូហ្សិត** ជាបេក្ខភាពស្ត្រីមកពីគណបក្សសង្គ្រោះជាតិ ហើយបានជាប់ឆ្នោតជា **មេឃុំថ្មីស្ត្រីវ័យក្មេង** នៅ**សង្កាត់អូចារ ខេត្តបាត់ដំបង។** កញ្ញាត្រូវទទួលបានការគាំទ្រ និងកោតសរសើរមិនដាច់ពីមាត់ពីគ្រប់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ ជាពិសេសបងប្អូនប្រជាពលរដ្ឋកម្ពុជា ។ ជាក់ស្តែង កញ្ញាបានទទួលការកោតសរសើរ និងគាំទ្រនៅក្នុងប្រព័ន្ធផ្សព្វផ្សាយសង្គមហ្វេសប៊ុកក្នុងកម្មវិធីម្ចាស់ឆ្នោតរបស់មណ្ឌលព័ត៌មានស្ត្រីកម្ពុជា FM 102 ប្រធានបទ «មនុស្សជំនាន់ថ្មី» ។

អ្នកដែលបញ្ចេញយោបល់តាមរយៈខមមិនទាំងស្រី ទាំងប្រុសក្នុងកិច្ចពិភាក្សាមានចំនួនសរុប ***២៣៥ ខមមិន។*** នៅក្នុងនោះមានមតិគាំទ្រ និងសសើរកញ្ញាមានចំនួន ***១១៦ ខមមិន*** ស្មើនឹង (៤៩.៣៦%) និង ***១១៩*** បានសួរជាសំណួរ ។ ក្នុងមតិទាំងនោះមានដូចជាការលើកសរសើរ គាំទ្រ លើកទឹកចិត្តនឹងសម្តីរបស់កញ្ញាស៊ិន ចាន់ពៅរ៉ូហ្សិតដែលបានបកស្រាយ និងពេញចិត្តលើផែនការដែលត្រូវធ្វើបន្ទាប់ពីឡើងកាន់តំណែង។ យើងកត់សម្គាល់ឃើញថា ចៅសង្កាត់ជាប់ថ្មីរូបនេះមានឥទ្ធិពលយ៉ាងខ្លាំងទៅកាន់ម្ចាស់ឆ្នោត កញ្ញាស្វាហាប់ ហ៊ានប្រឈមបញ្ហា និងពុះពារឧបសគ្គដែលកើតមានមកលើរូបកញ្ញា។

ខាងក្រោមនេះគឺជាមតិរបស់អ្នកគាំទ្រតាមរយៈប្រពន្ធ័ផ្សព្វផ្សាយសង្គមហ្វេសប៊ុកៈ

១. **លោក អ៊ីន ឌេត** បានបញ្ចេញយោបល់ថា *«ខ្ញុំសូមកោតសរសើរ កញ្ញា ស៊ិន ចាន់ពៅរ៉ូហ្សិត មេឃុំថ្មីអូចារ នូវភាពក្លាហាន តស៊ូ មិនលក់ឧត្តមគតិ ។ សូមឲ្យប្រជាពលរដ្ឋខ្មែរគ្រប់រូប មេត្តាជួយលើកទឹកចិត្ត ផ្តល់កម្លាំងចិត្ត ការពារសុវត្ថិភាពគាត់ ដើម្បីភាពល្អប្រសើរ និងអភិវឌ្ឍន៍ភូមិឃុំបានល្អ»* ។

២. **លោក បាន វីដា** បានបញ្ចេញយោបល់ថា *«រ៉ូហ្សិត មានវោហាស័ព្ទល្អណាស់និយាយមិនជាន់ពាក្យ បកស្រាយចំសំណួរ ការលើកដាក់សម្លេងបានល្អ សមជាថ្នាក់ដឹកនាំណាស់សូមសរសើរ !!»*

៣. **លោក គង់គា កែវមុនីរតនា** បានបញ្ចេញមតិថា *«គាំទ្រស្ត្រីវ័យក្មេងចូលរួមអភិវឌ្ឍន៍ជាតិ និងនយោបាយ»*

៤. **លោកស្រី សេង ហៀង** បានបញ្ចេញយោបល់ថា *«បុគ្គលដែលមានឆន្ទៈ រឹងមាំ និងចង់ជួយសង្គមជាតិពិតប្រាកដ ដូចក្មួយ រ៉ូហ្សិតមិនរួញរានឹងឧបសគ្គឡើយ»*

៥. **កញ្ញា លីហ្សា គង់** បានបញ្ចេញមតិថា *«ខ្ញុំពេញចិត្តកញ្ញារ៉ូហ្សិតខ្លាំងណាស់ ខ្ញុំនិងបន្តការតាមដានកញ្ញាជានិច្ច»*

យោងតាមយោបល់ប្រជាពលរដ្ឋភាគច្រើន បានបង្ហាញអំពីការគាំទ្រ និងសរសើរដល់ការចូលរួមរបស់ស្ត្រីក្នុងការដឹកនាំ។ ទាំងនេះបង្ហាញឲ្យឃើញថា ប្រជាពលរដ្ឋ និងសង្គមទាំងមូលគឺមានការផ្លាស់ប្តូរផ្នត់គំនិតមកជាវិជ្ជមានឲ្យតម្លៃចំពោះស្ត្រីក្នុងការចូលរួមក្នុងការងារសង្គម និងនយោបាយ ប្រយោជន៍ចូលរួមអភិវឌ្ឍន៍សង្គមលើគ្រប់វិស័យដោយមានសក្តានុពល និងភាពរីកចម្រើន។

## *ករណីសិក្សា : ភាពលេចធ្លោរបស់ស្ត្រីក្នុងការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ សង្កាត់*

## ករណីសិក្សាទី១

*« មូលហេតុដែលកញ្ញា* **ស្វាយ ចន្ធា** *ប្រឡូកចូលក្នុងវិស័យនយោបាយ ដោយសារតែកញ្ញាចង់ជួយអភិវឌ្ឍន៍ក្នុងសង្កាត់ឲ្យមានការរីកចំរើន ចង់បានការងារពិតប្រាកដមួយ ហើយកញ្ញាចង់ជួយសង្គមដោយផ្ទាល់ និងលើកកម្ពស់តម្លៃស្ត្រី ព្រមទាំងជួយសម្រួលជីវភាពគ្រួសារប្រចាំថ្ងៃរបស់គាត់ផងដែរ »។*

*«មូលហេតុដែលកញ្ញាបានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ គឺដោយសារគណបក្សឃើញកញ្ញាប្រឹងប្រែងយកចិត្តទុកដាក់ធ្វើការ មានឆន្ទៈខ្ពស់ សកម្មក្នុងការងារ និងចូលរួមសកម្មភាពក្នុងសង្គមបានច្រើន។ល។ ជាងនេះទៅទៀត កញ្ញាទទួលបានការគាំទ្រពីសំណាក់ក្រុមគ្រួសារ និងអ្នកជិតខាង ព្រោះថាពួកគេចង់ឲ្យកញ្ញាចូលរួមក្នុងការងារភូមិ ឃុំក្នុងគោលបំណងជំរុញឲ្យស្ត្រីចូលរួមក្នុងការអភិវឌ្ឍន៍ភូមិ ឃុំរបស់ពួកគាត់ ជាពិសេសជួយជនងាយរងគ្រោះ ដូចជាស្ត្រីមេម៉ាយ ចាស់ជរា កុមារកំព្រា និងជនពិការជាដើម» ។*

**កញ្ញា ស្វាយ ចន្ធា** ជាបេក្ខជនលេខរៀងទី៤មកពីគណបក្សប្រជាជនកម្ពុជា និងបានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាសង្កាត់បារាយណ៍ ក្រុងដូនកែវ ខេត្តតាកែវ ក្នុងអាណត្តិទី៤នេះ (ឆ្នាំ២០១៧ ដល់ឆ្នាំ២០២២) ដែលមានសមាជិកក្រុមប្រឹក្សាសង្កាត់សរុប ៩នាក់ ក្នុងនោះស្ត្រី១នាក់ (១១,១១%) មានពីរគណបក្សនយោបាយ ៖

| | | |
|---|---|---|
| ១. ប្រធានក្រុមប្រឹក្សាសង្កាត់ (ចៅសង្កាត់) | គណបក្សប្រជាជនកម្ពុជា | (ប្រុស) |
| ២. សមាជិកក្រុមប្រឹក្សាសង្កាត់ (ចៅសង្កាត់រងទី១) | គណបក្សប្រជាជនកម្ពុជា | (ប្រុស) |
| ៣. សមាជិកក្រុមប្រឹក្សាសង្កាត់ (ចៅសង្កាត់រងទី២) | គណបក្សសង្គ្រោះជាតិ | (ប្រុស) |
| ៤. សមាជិកក្រុមប្រឹក្សាសង្កាត់ | គណបក្សប្រជាជនកម្ពុជា | (ស្រី) |

| | | |
|---|---|---|
| ៥. សមាជិកក្រុមប្រឹក្សាសង្កាត់ | គណបក្សប្រជាជនកម្ពុជា | (ប្រុស) |
| ៦. សមាជិកក្រុមប្រឹក្សាសង្កាត់ | គណបក្សប្រជាជនកម្ពុជា | (ប្រុស) |
| ៧. សមាជិកក្រុមប្រឹក្សាសង្កាត់ | គណបក្សប្រជាជនកម្ពុជា | (ប្រុស) |
| ៨. សមាជិកក្រុមប្រឹក្សាសង្កាត់ | គណបក្សសង្គ្រោះជាតិ | (ប្រុស) |
| ៩. សមាជិកក្រុមប្រឹក្សាសង្កាត់ | គណបក្សសង្គ្រោះជាតិ | (ប្រុស) |

នៅក្នុងសង្កាត់បារាយណ៍នេះ មាន ១៤ភូមិ មាន ២ ៧៣៧គ្រួសារ ។ បច្ចុប្បន្ន កញ្ញា **ស្វាយ ចន្ធា** មានអាយុ៣៦ឆ្នាំ នៅលីវ ជាកូនកំព្រាម្តាយរស់នៅជាមួយឪពុកដែល មានមុខរបរជា កសិករ នៅភូមិក្រចាប់ សង្កាត់បារាយណ៍ ក្រុងដូនកែវ ខេត្តតាកែវ ។

កញ្ញាមានប្រវត្តិ បទពិសោធន៍ការងារ និងកំរិតវប្បធម៌ ដូចតទៅ៖

| | |
|---|---|
| - ឆ្នាំ១៩៩៨ ដល់ឆ្នាំ១៩៩៩ | បញ្ចប់ការសិក្សាត្រឹមថ្នាក់ទី១០ ដោយសារទឹកលិចផ្លូវនិងមិនសូវចង់ទៅរៀន |
| - ឆ្នាំ២០០០ | ចូលរៀនកាត់ដេរ និងកុំព្យូទ័រនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត |
| - ឆ្នាំ២០១០ | ធ្វើការជាមន្ត្រីកិច្ចសន្យា ដែលទទួលបន្ទុកកិច្ចការនារី និងកុមារ នៅសង្កាត់បារាយណ៍ ។ |
| - ឆ្នាំ២០១២ | សមាជិកក្រុមប្រឹក្សាសង្កាត់បារាយណ៍ |
| - ឆ្នាំ២០១៧ | បេក្ខជនឈរឈ្មោះលេខរៀងទី៤និងជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាសង្កាត់ |

- កញ្ញាបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលផ្សេងៗ ដូចជា វគ្គស្ត្រី និងកុមារ និងវគ្គវិមជ្ឈការ ជាដើម ។

**កញ្ញា ស្វាយ ចិន្តា** បានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាសង្កាត់មកពីគណបក្សប្រជាជនកម្ពុជា ចំនួន **២អាណត្តិ** (អាណត្តិទី៣ និងអាណត្តិទី៤) ដែលជាអ្នកទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ ។

*« មូលហេតុដែលកញ្ញាប្រឡូកចូលក្នុងវិស័យនយោបាយ ដោយសារតែកញ្ញាចង់ជួយអភិវឌ្ឍន៍ក្នុងសង្កាត់ឲ្យមានការរីកចំរើន ចង់បានការងារពិតប្រាកដមួយ ហើយកញ្ញាចង់ជួយសង្គមដោយផ្ទាល់ និងលើកកម្ពស់តម្លៃស្ត្រី ព្រមទាំងជួយសម្រួលជីវភាពគ្រួសារប្រចាំថ្ងៃរបស់គាត់ផងដែរ »*។ កញ្ញាបានបន្ថែមទៀតថា *« ការងារស្ត្រី និងកុមារពិតជាមានសារៈសំខាន់ខ្លះណាស់សំរាប់ឃុំ សង្កាត់ គឺស្ត្រីត្រូវតែដឹកនាំទាំងក្នុងសង្កាត់ និងក្នុងគ្រួសារ ត្រូវតែឲ្យមានសម្លេងស្ត្រីក្នុងគ្រួសារ និងក្នុងសង្គម»*។ ជាងនេះទៅទៀត ស្ត្រីត្រូវតែមានតួនាទីសំខាន់ក្នុងការអប់រំកូនក្នុងផ្ទះ ពីព្រោះកូនមានពេលនៅជាមួយម្តាយច្រើនជាងឪពុក។ ជាពិសេស កុមារត្រូវការទទួលចំណេះដឹង រៀនសូត្រ លូតលាស់ដើម្បីអភិវឌ្ឍន៍ទាំងក្នុងគ្រួសារ និងសង្គមទាំងមូល។ ដូច្នេះហើយ ការងារស្ត្រី និងកុមារពិតជាមានសារៈសំខាន់ដែលយើងទាំងអស់គ្នាត្រូវតែយកចិត្តទុកដាក់។ ជាក់ស្តែង បញ្ហាប្រឈមបានកើតមានឡើងនៅក្នុងសង្កាត់ ដូចជាកុមារបោះបង់ការរៀនសូត្រទៅធ្វើការរោងចក្រដែលធ្វើឲ្យប៉ះពាល់ដល់ការសិក្សា។ លើសពីនេះ គ្រួសារមួយចំនួនបានចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេស

ដូច្នេះ ពួកគាត់បាត់បង់ឱកាសក្នុងការផ្តល់ពេលវេលាគ្រប់គ្រាន់សំរាប់កូនៗ និងដើម្បីឲ្យកូនៗទទួលបានការអប់រំនៅសាលារៀនផងដែរ។ ជាពិសេស កុមារតូចៗបាត់បង់ក្នុងការទទួលបានការព្យាបាល និងការចាក់វ៉ាក់សាំងការពារជំងឺផ្សេងៗ ព្រមទាំងបាត់បង់ឱកាសជាច្រើន ។ កញ្ញាបន្តលើកឡើងថា បច្ចុប្បន្នការងារស្ត្រី និងកុមារនៅក្នុងសង្កាត់មានភាពមមាញឹកច្រើន ដូចជាការពិនិត្យផ្ទៃពោះ សំរាលកូន និងទទួលសេវាពន្យាកំណើតជាដើម។

មូលហេតុដែលកញ្ញាបានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ (បេក្ខនារីឈរឈ្មោះនៅលេខរៀងទី៨)នៅអាណត្តិទី៣ និងបានឈរឈ្មោះនៅលេខរៀងទី៤ អាណត្តិទី៤នេះ *«គឺដោយសារគណបក្សឃើញកញ្ញាប្រឹងប្រែងយកចិត្តទុកដាក់ធ្វើការ មានឆន្ទៈខ្ពស់ សកម្មក្នុងការងារ និងចូលរួមសកម្មភាពក្នុងសង្គមបានច្រើន ។ល។ ជាងនេះទៅទៀត កញ្ញាទទួលបានការគាំទ្រពីសំណាក់ក្រុមគ្រួសារ និងអ្នកជិតខាង ព្រោះថា ពួកគេចង់ឲ្យកញ្ញាចូលរួមក្នុងការងារភូមិ-ឃុំក្នុងគោលបំណងជំរុញឲ្យស្ត្រីចូលរួមក្នុងការអភិវឌ្ឍន៍ភូមិ-ឃុំរបស់ពួកគាត់ ជាពិសេស ជួយជនងាយរងគ្រោះដូចជា ស្ត្រីមេម៉ាយ ចាស់ជរា កុមារកំព្រា និងជនពិការជាដើម»* ។ ជាងនេះទៅទៀត កញ្ញាបានរកឃើញថា មិនមានប្រតិកម្ម ឬទទួលបានមតិរិះគន់អ្វីគួរឲ្យកត់សម្គាល់ពីសំណាក់បុរសៗនៅក្នុងសង្កាត់របស់គាត់ទេ ។

វិធីសាស្ត្រដែលកញ្ញាបានប្រើប្រាស់ដើម្បីទាក់ទាញការគាំទ្រពីប្រជាពលរដ្ឋក្នុងសង្កាត់ពេលឃោសនាបោះឆ្នោត គឺកញ្ញាបានចូលរួមជួយប្រជាពលរដ្ឋដោយផ្ទាល់ និងចូលរួមរាល់សកម្មភាពនៅក្នុងភូមិ សង្កាត់របស់គាត់។

ឆន្ទៈបន្តរបស់កញ្ញា គឺចង់ក្លាយជាជំទប់ទី១ ឬជំទប់ទី២នៅអាណត្តិក្រោយៗ និងចង់បន្តការងារលើកិច្ចការស្ត្រី និងកុមារទៀត។ កញ្ចប់ថវិការបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ (គកនក) សរុបចំនួន៦ ១២០ ០០០រៀល ក្នុងនោះ ៣ ៩៩៦ ០០០រៀលសម្រាប់សេវាសង្គម និង២ ១២៤ ០០០រៀលសម្រាប់កិច្ចប្រជុំគកនក ថវិកាភាគច្រើនយកទៅផ្សព្វផ្សាយនៅតាមភូមិ សង្កាត់ និងតាមផ្ទះ។ ទោះជាយ៉ាងណាក៏ដោយ កញ្ញានៅតែមានបញ្ហាប្រឈមក្នុងពេលអនុវត្តការងារ ដោយសារតែប្រជាពលរដ្ឋមិនសូវយកចិត្តទុកដាក់ក្នុងការចូលរួមជាមួយសង្កាត់ ។

វិធានការដោះស្រាយបញ្ហាស្ត្រី និងកុមារនៅក្នុងសង្កាត់របស់ខ្លួន កញ្ញា **ស្វាយ ចិន្តា**បានសន្យាបន្ថែមក្នុងអំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១៧ ថា៖ *«នឹងជួយប្រជាពលរដ្ឋឲ្យមានការរីកចម្រើន ជាពិសេសក្នុងវិស័យស្ត្រី និងកុមារ»* ។

កញ្ញា **ស្វាយចិន្តា**បានសំណូមពរថា *«សូមផ្តល់វគ្គបណ្តុះបណ្តាលបន្ថែមទៀតដល់ស្ត្រីដើម្បីឲ្យមានការយល់ដឹងកាន់តែទូលំទូលាយ ជាពិសេស សូមរាជរដ្ឋាភិបាលជួយជំរុញ បង្កើត និងអនុវត្តយន្តការលើកទឹកចិត្ត និងដោះស្រាយរាល់បញ្ហារបស់ស្ត្រីដែលជាសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់»* ។

# ករណីសិក្សាទី២

*«មូលហេតុដែលជម្រុញឲ្យខ្ញុំចូលប្រឡូកការងារក្នុងវិស័យនយោបាយ ដោយសារតែខ្ញុំមានការគាំទ្រ និងលើកទឹកចិត្តពីក្រុមគ្រួសារ ។ មូលហេតុចំបងនោះគឺ ខ្ញុំចង់បានបទពិសោធន៍ការងារ ចង់ជួយកិច្ចការក្នុងសង្គមជាតិ និងធ្វើការឲ្យមានតម្លាភាព ក្នុងគោលបំណងធ្វើឲ្យប្រទេសជាតិមានការ អភិវឌ្ឍន៍ទៅមុខជាលំដាប់ ជាពិសេសការដោះស្រាយបញ្ហាស្ត្រី និងកុមារនៅថ្នាក់មូលដ្ឋាន»។*

លោកស្រី **ឈាន់ ចាន់ធូ** ជាសមាជិកគណបក្សសង្គ្រោះជាតិ និងបានជាប់ឆ្នោតជាចៅសង្កាត់រងទី២ នៃក្រុមប្រឹក្សាសង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ ក្នុងអាណត្តិទី៤នេះ (ឆ្នាំ២០១៧ ដល់ឆ្នាំ២០២២) ដែលមានសមាជិកក្រុមប្រឹក្សាសង្កាត់សរុប ៩នាក់ ក្នុងនោះស្ត្រី៣នាក់ (៣៣,៣៣%) មានពីរគណបក្សនយោបាយ ៖

| | | |
|---|---|---|
| ១. ប្រធានក្រុមប្រឹក្សាសង្កាត់ (ចៅសង្កាត់) | គណបក្សប្រជាជនកម្ពុជា | (ប្រុស) |
| ២. សមាជិកក្រុមប្រឹក្សាសង្កាត់ (ចៅសង្កាត់រងទី១) | គណបក្សប្រជាជនកម្ពុជា | (ប្រុស) |
| ៣. សមាជិកក្រុមប្រឹក្សាសង្កាត់ (ចៅសង្កាត់រងទី២) | គណបក្សសង្គ្រោះជាតិ | (ស្រី) |
| ៤. សមាជិកក្រុមប្រឹក្សាសង្កាត់ | គណបក្សប្រជាជនកម្ពុជា | (ស្រី) |
| ៥. សមាជិកក្រុមប្រឹក្សាសង្កាត់ | គណបក្សប្រជាជនកម្ពុជា | (ប្រុស) |
| ៦. សមាជិកក្រុមប្រឹក្សាសង្កាត់ | គណបក្សប្រជាជនកម្ពុជា | (ស្រី) |
| ៧. សមាជិកក្រុមប្រឹក្សាសង្កាត់ | គណបក្សសង្គ្រោះជាតិ | (ប្រុស) |
| ៨. សមាជិកក្រុមប្រឹក្សាសង្កាត់ | គណបក្សសង្គ្រោះជាតិ | (ប្រុស) |
| ៩. សមាជិកក្រុមប្រឹក្សាសង្កាត់ | គណបក្សសង្គ្រោះជាតិ | (ប្រុស) |

នៅសង្កាត់កំពង់ប្រណាកនេះ មាន១០ភូមិ ២៥០៩គ្រួសារដែលមានប្រជាពលរដ្ឋសរុប ៩៥៨៣នាក់ ក្នុងនោះ ស្ត្រី ៥០១៣នាក់ ។

បច្ចុប្បន្ន លោកស្រី **ឈាន់ ចាន់ធូ** មានអាយុ ៤២ឆ្នាំ មានស្វាមីឈ្មោះសឹម សុផាន់រិទ្ធ (ហៅសុខ) និងមានកូនស្រីចំនួន ៥នាក់ រស់នៅភូមិទំនប់ សង្កាត់ កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ ។ លោកស្រី មានប្រវត្តិ បទពិសោធន៍ការងារ និងកំរិតវប្បធម៌ ដូចតទៅ៖

- បញ្ចប់ការសិក្សាត្រឹមថ្នាក់ទី៨
- ឆ្នាំ២០០៨ សមាជិកអចិន្ត្រៃយ៍របស់គណបក្សសម រង្ស៊ី និងចូលរួមសង្កេតការណ៍បោះឆ្នោតថ្នាក់ជាតិ

- ឆ្នាំ២០១២ បេក្ខជនឈរឈ្មោះនៅលំដាប់លេខរៀងទី៤នៃគណបក្សសម រង្ស៊ីនៅក្នុងសង្កាត់កំពង់ប្រណាក ។
- ឆ្នាំ២០១៤ ចៅសង្កាត់រងទី២ ទទួលបន្ទុកការងារសង្គមកិច្ច និងសណ្តាប់ធ្នាប់សាធារណៈជំនួស
  ឆ្នាំ២០១៥ លោក **ទិត្យ យស់** ជាចៅសង្កាត់រងទី២របស់គណបក្សសង្គ្រោះជាតិដែលបានទទួលមរណភាព ។
- ឆ្នាំ២០១៧ បេក្ខជនឈរឈ្មោះ នៅលំដាប់លេខរៀងទី១ និងជាប់ឆ្នោតជាចៅសង្កាត់រងទី២ ។

លោកស្រី **ឈាន់ ចាន់ធូ** ជាប់ឆ្នោតជាចៅសង្កាត់រងទី២នៃសង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហាររបស់គណបក្សសង្គ្រោះជាតិបានចំនួន២អាណត្តិ(អាណត្តិទី៣ និងអាណត្តិទី៤) ដោយទទួលបន្ទុកការងារសង្គមកិច្ច និងសណ្តាប់ធ្នាប់សាធារណៈទាំងពីរអាណត្តិព្រមៗគ្នា ។

មូលហេតុដែលជម្រុញឲ្យលោកស្រីចូលប្រឡូកការងារក្នុងវិស័យនយោបាយ ដោយសារតែលោកស្រីស្រីមានការគាំទ្រ និងលើកទឹកចិត្តពីក្រុមគ្រួសារ ។ មូលហេតុចំបងនោះគឺ លោកស្រីចង់បានបទពិសោធន៍ការងារ ចង់ជួយកិច្ចការក្នុងសង្គមជាតិ និងធ្វើការឲ្យមានតម្លាភាព ក្នុងគោលបំណងធ្វើឲ្យប្រទេសជាតិមានការអភិវឌ្ឍន៍ទៅមុខជាលំដាប់ ជាពិសេស ការដោះស្រាយបញ្ហាស្ត្រី និងកុមារនៅថ្នាក់មូលដ្ឋាន ។ លោកស្រីបន្តទៀតថា បញ្ហាស្ត្រី និងកុមារពិតជាមានសារៈសំខាន់ ពីព្រោះបញ្ហាប្រឈមរបស់ស្ត្រីកើតមានច្រើនដូចជាការរំលោភបំពាន ការរំលោភសេពសន្ថវៈ អំពើហិង្សា ។ល។ ដូច្នេះ យើងត្រូវតែយកចិត្តទុកដាក់ថែទាំជួយពួកគាត់ និងប្រជាពលរដ្ឋទាំងអស់ក្នុងសង្កាត់ ។

ការណ៍ដែលលោកស្រីបានជាប់ឆ្នោតជាចៅសង្កាត់រងទី២បានដល់ទៅ២អាណត្តិ (អាណត្តិទី៣ ឆ្នាំ២០១២ និងអាណត្តិទី៤ ឆ្នាំ២០១៧) គឺដោយសារតែលោកស្រីបានសកម្មគ្រប់សកម្មភាពនៅក្នុងភូមិ និងសង្កាត់ ដែលជាមូលហេតុធ្វើឲ្យប្រជាពលរដ្ឋបោះឆ្នោតគាំទ្រលោកស្រី និងជឿជាក់លើរូបគាត់ក្នុងការបម្រើប្រជាពលរដ្ឋនៅក្នុងសង្កាត់ ។

ចំណែកឯសកម្មភាពមមាញឹកជាមួយបញ្ហាស្ត្រី និងកុមារនៅក្នុងសង្កាត់ គឺផ្តោតទៅលើការចុះផ្សព្វផ្សាយអំពីអនាម័យ ជម្រុញស្ត្រីទៅពិនិត្យសុខភាព២ដងក្នុង១ឆ្នាំ ពេលដែលស្ត្រីសម្រាលកូនត្រូវនាំទៅមន្ទីរពេទ្យ និងអំពើហឹង្សា ដោយប្រើប្រាស់កញ្ចប់ថវិកាដែលជាមូលនិធិរបស់សង្កាត់មានចំនួន២លានរៀលក្នុងមួយឆ្នាំសម្រាប់ផ្សព្វផ្សាយ ។ ចំណែកកុមារមានអង្គការ (BFD) ជួយឧបត្ថម្ភ និងអង្គការ (VVSIOM) ជួយតាមក្រុមគោលដៅទៅលើកុមារ ។

លោកស្រី **ឈាន់ ចាន់ធូ**បានសំណូមពរដូចតទៅ ៖

- សូមរាជរដ្ឋាភិបាលជួយជម្រុញគ្រូបង្ហាត់កុមារឲ្យអស់ពីចិត្តពីថ្លើម ដើម្បីឲ្យផ្នែកសិក្សាចំណេះទូទៅមានភាពកាន់តែប្រសើរឡើង ។

- សុំបន្ថែមប្រាក់ឧបត្ថម្ភមូលនិធិឃុំ សង្កាត់ ដើម្បីបង្កលទ្ធភាពធ្វើសកម្មភាពផ្សព្វផ្សាយអប់រំដល់ប្រជាពលរដ្ឋឲ្យបានច្រើនដង។

## ៣- កម្មវិធីនយោបាយថ្នាក់ជាតិរបស់គណបក្ស អំពី បញ្ហាស្ត្រី និងកុមារ

ក្នុងដំណើរការយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១៧ ចាប់ពីថ្ងៃទី២០ ខែឧសភា ដល់ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៧ (១៤ថ្ងៃ) គណបក្សនយោបាយទាំង១២បានធ្វើសកម្មភាពឃោសនា ដើម្បីបង្ហាញដល់អ្នកបោះឆ្នោតនូវកម្មវិធីនយោបាយរបស់ខ្លួនក្នុងការដឹកនាំ និងអភិវឌ្ឍឃុំ សង្កាត់ ក្នុងនោះក៏បានបង្ហាញនូវកម្មវិធីនយោបាយទាក់ទងនឹងបញ្ហាស្ត្រី និងកុមារ ដើម្បីដោះស្រាយក្នុងអាណត្តិទី៤នេះផងដែរ។

កម្មវិធីនយោបាយ និងការសន្យាសំខាន់ខាងក្រោមនេះ បានដកស្រង់ចេញពីកម្មវិធីគុម្ពលរបស់មណ្ឌលព័ត៌មានស្ត្រីកម្ពុជា FM 102 និងវេទិកាអ្នកស្តាប់វិទ្យុអាស៊ីសេរីដែលបានផ្សព្វផ្សាយក្នុងអំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោត និងបានដកស្រង់ចេញពីរបាយការណ៍សង្កេតការណ៍របស់ខុមហ្វ្រែលស្តីពី «ការចូលរួមនយោបាយរបស់ស្ត្រីក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧» ព្រមទាំងដកស្រង់ព័ត៌មានពីបេក្ខជនស្ត្រីក្នុងតំបន់គោលដៅរបស់ខុមហ្វ្រែលចំនួន៥ខេត្ត គឺ ខេត្តកំពង់ធំ ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តតាកែវ និងខេត្តព្រះវិហារ។

**តារាងទី១១ ៖ កម្មវិធីនយោបាយថ្នាក់ជាតិរបស់គណបក្សដើម្បីដោះស្រាយបញ្ហាស្ត្រី និងកុមារ**

| ល.រ | កម្មវិធីនយោបាយរបស់គណបក្ស | ឈ្មោះគណបក្សនយោបាយ |
|---|---|---|
| ១ | **ផ្តល់ជូនប្រជាជនដោយឥតគិតថ្លៃ**នូវសេវាចុះបញ្ជីកំណើត ចុះបញ្ជីអាពាហ៍ពិពាហ៍ បញ្ជីមរណភាព សៀវភៅគ្រួសារ សៀវភៅស្នាក់នៅ និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។ | **គណបក្សប្រជាជនកម្ពុជា** |
| ២ | **ប្រជាជនគ្រប់រូបទទួលបានសេវាពិនិត្យ និងព្យាបាលជំងឺ**កាន់តែល្អប្រសើរតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យរបស់រដ្ឋ ។ ប្រជាជនក្រីក្រ និងអ្នកខ្វះលទ្ធភាពទទួលបានសេវាពិនិត្យ និងព្យាបាលជំងឺដោយឥតបង់ថ្លៃនៅតាមមណ្ឌលសុខភាព និងតាមមន្ទីរពេទ្យរបស់រដ្ឋ ។ | |
| ៣ | **ឃុំ-សង្កាត់ នីមួយៗមានអនុវិទ្យាល័យមួយយ៉ាងតិច** ។ ក្រុង ស្រុក ខណ្ឌនីមួយៗមានវិទ្យាល័យមួយយ៉ាងតិច និងមានសាលាបឋមសិក្សាច្រើនពង្រាយតាមភូមិ ដើម្បីឲ្យកុមារ និងយុវជនបានរៀនសូត្រគ្រប់គ្នា។ | |
| ៤ | **ទប់ស្កាត់ការជួញដូរ**គ្រឿងញៀន ល្បែងស៊ីសង ចោរកម្ម និងការ | **គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ**? |

| | | |
|---|---|---|
| | ជួញដូរផ្លូវភេទទៅលើស្ត្រី ។ | |
| ៥ | **បង្កើតមូលនិធិជូនដល់ជនដែលងាយរងគ្រោះ** ដូចជា ចាស់ជរា ស្ត្រីមានផ្ទៃពោះ។ | |
| ៦ | **ពង្រឹងប្រសិទ្ធភាព និងលើកកម្ពស់ការងារនគរបាល**ដើម្បីឃុំ-សង្កាត់ប្រកបដោយសុវត្ថិភាព គ្មានគ្រឿងញៀន និងគ្មានអំពើហឹង្សា។ | |
| ៧ | **បង្កើតទីផ្សារការងារ**ជូនប្រជាពលរដ្ឋ ដូចជាសេវាសាធារណៈមិនរើសអើង មិនពុករលួយ ដូចជា ការធ្វើអត្តសញ្ញាប័ណ្ណសញ្ជាតិខ្មែរ សំបុត្រកំណើត សៀវភៅគ្រួសារ សៀវភៅស្នាក់នៅ ឬឯកសារផ្សេងទៀតជូនប្រជាពលរដ្ឋ។ | |
| ៨ | **វិមជ្ឈការអំណាច**សេវាសាធារណៈ គឺនឹងទទួលបានថវិកា ៥០ ម៉ឺនដុល្លារអាមេរិកក្នុងការអភិវឌ្ឍន៍ឃុំ សង្កាត់នីមួយៗ ប្រសិនបើគណបក្សសង្រ្គោះជាតិឈ្នះឆ្នោតឆ្នាំ២០១៨ គណបក្សសង្គ្រោះជាតិ នឹងទម្លាក់ថវិកាមកឃុំ សង្កាត់ដើម្បីរៀបចំបែងចែកអភិវឌ្ឍ ឃុំ សង្កាត់ ជាពិសេសជួយគាំពារខ្លាំងទៅលើស្ត្រី និងកុមារ ( យើងនឹងបែងចែកថវិកា១៦,៥% នៃថវិកាជាតិទាំងមូល)។ | |
| ៩ | **លើកតម្កើងការគោរពសិទ្ធិ**សេរីភាពប្រជារាស្ត្រ និងសមភាពយេនឌ័រដែលជាគោលការណ៍គ្រឹះនៃលទ្ធិប្រជាធិបតេយ្យ។ | **គណបក្សហ៊្វុនស៊ិនប៉ិច** |
| ១០ | **ខិតខំស្វែងរកការងារ**ជូនប្រជារាស្ត្រ ជាពិសេសស្ត្រីនៅក្នុងមូលដ្ឋាន។ | |
| ១១ | **បង្កលក្ខណៈងាយស្រួលក្នុងការសិក្សា និងកីឡា**ជូនយុវជន យុវនារីក្នុងមូលដ្ឋាន ដើម្បីកាយសម្បទារឹងមាំ និងប្រាជ្ញាភ្លឺថ្លា។ | |
| ១២ | **ផ្តល់ជូននូវសុខសុវត្ថិភាពល្អនៅក្នុងមូលដ្ឋាន** ។ មិនឲ្យមានចោរលួចចោរប្លន់ ជួញដូរ សេពគ្រឿងញៀន ល្បែងស៊ីសង បទល្មើសនេសាទ ក្រុមបងតូចបងធំនៅក្នុងមូលដ្ឋានឡើយ ។ | |
| ១៣ | - **ជំរុញគ្រូពេទ្យឲ្យយកចិត្តទុកដាក់**ពិនិត្យ និងព្យាបាលជំងឺជូនប្រជារាស្ត្រនៅមណ្ឌលសុខភាព ពិសេសចាស់ជរា មាតា ទារក និងទទួលសង្គ្រោះបន្ទាន់ដោយគ្មានការរើសអើង ព្រមទាំងរៀបចំឲ្យមានរថយន្ត ឬមធ្យោបាយសមស្របអាចដឹកជញ្ជូនអ្នកជំងឺសង្គ្រោះបន្ទាន់ទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យ ។ ជាពិសេស មិនឲ្យអ្នកជំងឺស្លាប់ដោយខ្វះប្រាក់សម្រាប់ព្យាបាលឡើយ។ | |

| | | |
|---|---|---|
| | - **ខិតខំរៀបចំក្រុមគ្រូពេទ្យស្ម័គ្រចិត្ត** និងរៀបចំកម្មវិធីចុះពិនិត្យជំងឺជូនដល់ប្រជារាស្ត្រ នៅតាមបណ្តាមូលដ្ឋានឃុំ-សង្កាត់ និងមណ្ឌលសុខភាពនានា ។ | |
| ១៤ | **លើកស្ទួយការអភិវឌ្ឍន៍ស្ត្រី និងកុមារ** ឲ្យបានរីកចំរើនគ្រប់វិស័យនូវតំរូវការនៃប្រជាពលរដ្ឋចង់បាន ។ | **គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ** |
| ១៥ | **លុបបំបាត់ការជួញដូរស្ត្រី និងកុមារ** ។ លុបបំបាត់គ្រឿងញៀនដែលជះឥទ្ធិពលដ៏ធំមកលើកូនខ្មែរគ្រប់រូប ។ | |
| ១៦ | **បណ្តុះបណ្តាលចំណេះដឹង និងចំណេះធ្វើ**ដល់កុមារ យុវជន យុវតី ដោយផ្តល់នូវអាហារូបករណ៍ ទំនាក់ទំនងអង្គការក្រៅប្រទេសដើម្បីជួយដល់កុមារ ។ | |
| ១៧ | **ជួយលើកតំកើងស្ត្រីឲ្យមានគំនិតច្នៃប្រឌិត**តាមតំបន់នីមួយៗ ដោយតម្បាញតាមផ្ទះ ផ្តល់ជំនួយសម្រាប់កុមារ ជនពិការ ក្មេងកំព្រា ។ | |
| ១៨ | បង្កើតមន្ទីរពេទ្យតាមភូមិ ដើម្បីពិនិត្យជូនប្រជាពលរដ្ឋដោយមិនគិតតម្លៃ។ | |
| ១៩ | **ត្រូវធ្វើឲ្យបាននូវផលិតកម្ម និងបសុព្យាបាល**ឲ្យបានប្រសើរ ដើម្បីកាត់បន្ថយនូវជំងឺប្រជាពលរដ្ឋ ដោយពិនិត្យផ្នែកឡាបូឲ្យបានច្បាស់លាស់រាល់ទំនិញណាដែលនាំចូលពីប្រទេសជិតខាង ព្រោះវាជាផលប៉ះពាល់យ៉ាងខ្លាំងដល់ប្រជាពលរដ្ឋ មុននឹងដាក់លក់នៅតាមទីផ្សារនានា ។ | |
| ២០ | **បញ្ឈប់ពលកម្មកុមារបម្រើតាមផ្ទះ** ។ រដ្ឋាភិបាលសាធារណរដ្ឋប្រជាធិបតេយ្យបានបង្កើតយន្តការពិសេសៗ និងផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិជាច្រើន មានទាំងអនុសញ្ញា ស្តីពីសិទ្ធិកុមារ ពិធីសាបន្ថែម ស្តីពីការចូលរួមរបស់កុមារ។ ជាពិសេសអនុសញ្ញាលេខ ១៨២ ស្តីពីការហាមប្រាម និងការលុបបំបាត់ពលកម្មកុមារនៅតាមផ្ទះ ។ | |
| ២១ | **បង្ក្រាប ទប់ស្កាត់** អំពើចោរកម្ម ក្មេងទំនើង អំពើអសីលធម៌ ហឹង្សាក្នុងគ្រួសារ ការចរាចរផលិត និងសេពគ្រឿងញៀនដោយពង្រឹងការអនុវត្តតាមយន្តការ និងច្បាប់ដែលមានស្រាប់ ដើម្បីឲ្យមានសន្តិសុខសណ្តាប់ធ្នាប់ក្នុងភូមិ ឃុំ សង្កាត់ កាន់តែប្រសើរ ផុតពីការភ័យខ្លាច។ | **គណបក្សខ្មែររួបរួមជាតិ** |
| ២២ | **បញ្ឈប់ការប្រើប្រាស់គ្រឿងញៀន** អំពើហឹង្សា និងការពារសុវត្ថិភាពប្រជាពលរដ្ឋទាំងប្រុស ទាំងស្រី ។ | **គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា** |

| | | |
|---|---|---|
| ២៣ | **ផ្តល់សេវាសាធារណៈ**ឲ្យទាន់ពេលវេលា និងមិនគិតកម្រៃពីប្រជាពលរដ្ឋឡើយ ។ | |
| ២៤ | **ដោះស្រាយបញ្ហាដីធ្លី**ដោយយុត្តិធម៌ | |
| ២៥ | **បង្កើតសាលារៀនបច្ចេកទេសនៅក្នុងមូលដ្ឋានឃុំ** សង្កាត់ដើម្បីផ្តល់ឱកាសដល់យុវជនក្រីក្រសិក្សាដោយមិនយកថ្លៃ ។ | **គណបក្សយុវជនកម្ពុជា** |
| ២៦ | **លុបបំបាត់ការចរាចរគ្រឿងញៀន**នៅក្នុងមូលដ្ឋានឃុំ សង្កាត់ ។ | |
| ២៧ | **បោសសំអាតអំពើពុករលួយ** គ្រឿងញៀន ល្បែងស៊ីសង និងបម្រើសេវាសាធារណៈ ដោយគោរពតាមច្បាប់កំណត់។ | **គណបក្សសំបុកឃ្មុំ សង្គមប្រជាធិបតេយ្យ** |
| ២៨ | **ប្រជាពលរដ្ឋត្រូវមាន**បាយទទួលទាន មានពេទ្យព្យាបាល មានការសិក្សាប្រកបដោយគុណភាព និងក្រមសីលធម៌ ។ | |
| ២៩ | **បង្កើតក្លឹបកីឡា**សម្រាប់យុវជន បង្កើតការងារ និងតំបន់ទេសចរណ៍។ | |
| ៣០ | **រៀបចំឲ្យមានកម្មវិធីបណ្តុះបណ្តាលស្ត្រី**ដើម្បីបង្កើនសមត្ថភាពយល់ដឹង និងការចូលរួមក្នុងកិច្ចការសេដ្ឋកិច្ច សង្គម និងនយោបាយ។ | **គណបក្សប្រជាធិបតេយ្យមូលដ្ឋាន** |
| ៣១ | **ធានាឱ្យប្រជាពលរដ្ឋគ្រប់រូបទទួលបានសេវាព្យាបាលសុខភាព** និងពិគ្រោះយោបល់គ្រប់គ្រាន់ពីមណ្ឌលសុខភាពនៅតាមឃុំ/សង្កាត់ប្រកបដោយគុណភាព និងការទទួលខុសត្រូវខ្ពស់ ។ យើងនឹងរៀបចំឲ្យមានការចូលរួមចំណែករបស់សមាគមប្រជាពលរដ្ឋក្នុងការទ្រទ្រង់ និងឃ្លាំមើលមណ្ឌលសុខភាពឃុំ ដើម្បីធ្វើយ៉ាងណាឲ្យមណ្ឌលសុខភាពមានសម្ភារៈបរិក្ខារល្អគ្រប់គ្រាន់ មានថ្នាំព្យាបាលល្អ និងគ្រូពេទ្យល្អ ធ្វើការបម្រើប្រជាពលរដ្ឋដោយស្មើភាពគ្នា និងគោរពតាមស្តង់ដារក្រមសីលធម៌វិជ្ជាជីវៈគ្រូពេទ្យ។ | |
| ៣២ | **រៀបចំឲ្យមានសហគមន៍ជួយគ្នាទៅវិញទៅមកនៅតាមមូលដ្ឋាន** ជាពិសេស ជួយគាំពារដល់ចាស់ជរា ជនក្រីក្រគ្មានទីពឹង កុមារកំព្រា និងជនពិការ។ | |
| ៣៣ | **រៀបចំឱ្យមានបណ្តាញការងារ**ដែលមានការចូលរួមពីអ្នកពាក់ព័ន្ធទាំងឡាយ ដើម្បីចូលរួមក្នុងការអប់រំពលរដ្ឋ លុបបំបាត់ការប្រើប្រាស់ និងការជួញដូរគ្រឿងញៀន។ | |
| ៣៤ | **គាំទ្រដល់យុវជន និងយុវនារីដែលមិនមានលទ្ធភាពបន្តការសិក្សា**ដល់ថ្នាក់វិទ្យាល័យ និងមហាវិទ្យាល័យឲ្យទទួលបាននូវការបណ្តុះបណ្តាល | |

| | | |
|---|---|---|
| | វិជ្ជាជីវៈ និងទុនសម្រាប់បង្កើតមុខរបរដោយខ្លួនឯង ។ យើងនឹងជ្រើសរើសមន្ត្រីជំនាញយ៉ាងតិច១រូបក្នុង១ឃុំឲ្យជួយតម្រង់ទិស និងគាំទ្រដល់យុវជនដើម្បីទទួលបានការងារល្អ។ | |
| ៣៥ | **ធានាឲ្យបានប្រាកដថាកូនចៅរបស់ប្រជាពលរដ្ឋគ្រប់រូបបានទទួលការអប់រំល្អ** ដោយស្មើភាពយ៉ាងតិចបំផុតបានរៀនចប់ថ្នាក់ទី៩ ដោយមានចំណេះដឹងមូលដ្ឋានគ្រឹះគ្រប់គ្រាន់សម្រាប់អនាគតល្អប្រសើរ។ យើងនឹងរៀបចំឲ្យមានសហាគមន៍ប្រជាពលរដ្ឋ ជំរុញការអប់រំឲ្យមានគុណភាព ដើម្បីធ្វើយ៉ាងណាឱ្យសាលារៀនមានគ្រូបង្រៀនល្អ កម្មវិធីសិក្សាល្អ និងបរិស្ថានសិក្សាល្អ។ | |

## តារាងទី១២ ៖ កម្មវិធីនយោបាយរបស់គណបក្សតាមឃុំ សង្កាត់នីមួយៗ ដែលបានសន្យាដោយបេក្ខជនស្ត្រីដើម្បីដោះស្រាយបញ្ហាស្ត្រី និងកុមារ



ការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧នេះ បេក្ខជនស្ត្រីឈរឈ្មោះបានធ្វើការឃោសនាតាមកម្មវិធីនយោបាយថ្នាក់ជាតិ បង្ហាញពីសមិទ្ធិផលដែលបានកសាងទាំងអស់ក្នុង ឃុំ សង្កាត់ក្នុងរយៈពេល៥ឆ្នាំកន្លងមក និងបានធ្វើការសន្យាបន្ថែមទៀតទៅតាមតម្រូវការក្នុងឃុំ សង្កាត់ ដោយឡែកៗពីគ្នាទាក់ទងនឹងបញ្ហាស្ត្រី និងកុមារ។ ការសន្យាសំខាន់ៗតាមឃុំ សង្កាត់នេះបានដកស្រង់ព័ត៌មានពីបេក្ខជនស្ត្រីក្នុងតំបន់គោលដៅរបស់ខុមហ្វ្រែលចំនួន ៥ខេត្តគឺ ខេត្តកំពង់ធំ ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តតាកែវ និងខេត្តព្រះវិហារ ។

| ល.រ | កម្មវិធីនយោបាយរបស់គណបក្សតាម ឃុំ សង្កាត់ | បេក្ខជនស្ត្រី | ឈ្មោះគណបក្សនយោបាយ |
|---|---|---|---|
| ១ | បំពេញតួនាទីរបស់ខ្លួនឲ្យកាន់តែខ្លាំងបន្ថែមទៀតក្នុងការជួយលើកកម្ពស់ស្ត្រី និងកុមារបានស្វែងយល់ពីការ អភិវឌ្ឍសង្គមផ្សេងៗ ផ្តល់ការអប់រំ ដល់ពួកគាត់ ។ | លោកស្រី **ជុំ សោភ័ណ្ឌ** ជាប់ឆ្នោតជា**ជំទប់ទី២** នៅឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ | **គណបក្សប្រជាជនកម្ពុជា** |

| | | | |
|---|---|---|---|
| ២ | ធ្វើឲ្យប្រជាពលរដ្ឋមានទំនុកចិត្តលើគាត់ ព្រមទាំងជួយស្ត្រីមានផ្ទៃពោះ កុមារ មនុស្សចាស់ឲ្យមានភាពល្អប្រសើរ និងលើកកម្ពស់កម្ពស់ឲ្យស្ត្រីបានចូលរួមលើគ្រប់វិស័យដូចបុរសដែរ។ | លោកស្រី **កែវ យ៉ាន** ជាប់ឆ្នោត **ជាមេឃុំ** នៅឃុំក្រាំងស្គារ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។ | |
| ៣ | មានការលើកទឹកចិត្តឲ្យស្ត្រីចូលរួមឈរឈ្មោះជាបេក្ខជនយ៉ាងទូលំទូលាយព្រមទាំងផ្តល់ឪកាសគ្រប់គ្រាន់ដល់ស្ត្រីទូទាំងសង្កាត់ ឲ្យឈរឈ្មោះដោយគ្មានការលាក់បាំងព័ត៌មានឡើយ គឺធ្វើឡើងដោយតម្លាភាព និងសុច្ចរិតភាព ប្រជាធិបតេយ្យពេញលេញ ដោយផ្អែកលើលក្ខន្តិក:របស់គណបក្ស។ | លោកស្រី **ផាន់ សម្ផស្ស** ឈរឈ្មោះលេខរៀងទី២ **មិនបានជាប់ឆ្នោត** នៅក្នុងសង្កាត់កំពង់ឆ្នាំង ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។ | |
| ៤ | នឹងបំពេញតួនាទី ឲ្យកាន់តែប្រសើរឡើង ទាំងការលើកកម្ពស់ស្ត្រី និង កុមារ ផ្តល់ការអប់រំឲ្យកុមារគ្រប់ៗគ្នា។ | លោកស្រី **ហ៊ឹម សុវណ្ណារី** ជាប់ឆ្នោតជា **ជំទប់ទី២** នៅភូមិពងទឹកខាងត្បូង ឃុំគុស ស្រុកត្រាំកក់ ឈ្មោះខេត្តតាកែវ | |
| ៥ | នឹងចូលរួមយ៉ាងពេញទំហឹងក្នុងការអភិវឌ្ឍភូមិ ឃុំ និងជំរុញលើកទឹកចិត្តស្ត្រី និងកុមារតូចៗដោយមិនរើសអើងឡើយ។ | លោកស្រី **ហ៊ែល សុឃីម** ឈរឈ្មោះនៅលេខរៀងទី៩ **មិនបានជាប់ឆ្នោត** នៅឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ | **គណបក្សសង្គ្រោះជាតិ** |
| ៦ | នឹងជួយស្ត្រីមេម៉ាយគ្មានទីពឹងឲ្យមានជីវស់នៅ ។ ជាពិសេសជួយស្ត្រីមានផ្ទៃពោះ និង កុមារ ផ្តល់សេវាព្យាបាលដោយឥតគិតថ្លៃ | លោកស្រី **ជួប សុភីន** ជាប់ឆ្នោតជា**ជំទប់ទី២** នៅភូមិភ្នំចាន់ត្រក ឃុំក្រាំងស្គារ ស្រុកទឹកផុស | |

| | | | |
|---|---|---|---|
| | និងបញ្ជូនទៅមន្ទីរពេទ្យ បង្អែកខេត្តបានទាន់ចិត្ត ។ | ខេត្តកំពង់ឆ្នាំង ។ | |

## ៤- សមាជិកស្ត្រីរបស់ គ.ជ.ប គធ/ខប គឃ/សប មន្ត្រីការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត និង ស្ត្រីក្រុមចុះឈ្មោះបោះឆ្នោត

***ស្ត្រីនៅតែមានចំនួនតិចតួចក្នុងតួនាទីជាអ្នកគ្រប់គ្រង និងចាត់ចែងការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ ។***

### ថ្នាក់ជាតិ

មានស្ត្រីតែ**១នាក់**ប៉ុណ្ណោះក្នុងចំណោមសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ៩នាក់ ។ មានស្ត្រីតែ **៤២នាក់** ស្មើនឹង **១២,៩៦%** នៃចំនួនសរុប ៣២៤នាក់ជាបុគ្គលិកក្របខ័ណ្ឌបំរើការងារនៅទីស្ដីការគ.ជ.ប ចំនួននេះមានការ**ថយចុះ ៥,៤៨% (២២នាក់)** បើធៀបនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០១៣ ដែលមានស្ត្រីចំនួន **៦៤នាក់** ស្មើនឹង **១៨,៤៤%** ។ ជាមួយគ្នានេះ ក៏មានស្ត្រីជាមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លីបំរើការងារនៅទីស្ដីការគ.ជ.បដែរ ចំនួន **៥៥នាក់** ស្មើនឹង **៣១,៦០%** នៃចំនួនសរុប ១៧៤នាក់ ។

### ថ្នាក់ក្រោមជាតិ



ស្ត្រីនៅតែមានចំនួនតិចតួចនៅគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ក្រោមៗ ដូចជា គណៈកម្មការរាជធានី/ខេត្តរៀបចំការបោះឆ្នោត (គធ/ខប)មានស្ត្រីចំនួន **១១៤នាក់** ស្មើនឹង **១២,៦៣%**នៃចំនួនសរុប ៩០២នាក់ គឺមានការ**ថយចុះបន្តិចបន្តួច ០,៧៥% (១០នាក់)** បើធៀបនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០១៣ ដែលមានស្ត្រីចំនួន **១២៤នាក់** ស្មើនឹង **១៣,៣៨%** ។

**ប៉ុន្តែចំនួនស្ត្រីមានការកើនឡើងបន្តិច ០,២៩% (៣៩នាក់)**នៅគណៈកម្មការឃុំ/សង្កាត់រៀបចំការបោះឆ្នោត (គឃ/សប) គឺពី**១ ១៩៥នាក់** ស្មើនឹង **១៤,៦៤%** ក្នុងការបោះឆ្នោតជាតិឆ្នាំ២០១៣ ទៅ **១ ២៣៤នាក់ ស្មើនឹង ១៤,៩៣%** នៃចំនួនសរុប ៨ ២៦៣នាក់ ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១៧ ។

### *ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត*




**ចំនួនស្ត្រីកាន់តែច្រើន**នៅថ្នាក់ទាប ដូចជា គណៈកម្មការការិយាល័យបោះឆ្នោត (គកប) និងរាប់សន្លឹកឆ្នោត(គករ) មានស្ត្រីចំនួន**៥៨ ១៧៦នាក់** ស្មើនឹង **៤៣,៧៧%** នៃចំនួនសរុប ១៣២ ៨៨៨នាក់ ។ ចំនួននេះមានការកើនឡើង **១,៧៦% (១០ ២៦៣នាក់)** បើធៀបនឹងការបោះឆ្នោតជាតិឆ្នាំ២០១៣ ស្ត្រីមានចំនួនតែ **៤៧ ៩១៣នាក់** ស្មើនឹង **៤២,០១%** ប៉ុណ្ណោះ ។ ចំណែកឯ ស្ត្រីក្រុមចុះឈ្មោះបោះឆ្នោតថ្មីឆ្នាំ២០១៦ មានចំនួន **១ ២៣១នាក់** ស្មើនឹង **២០,១២%** នៃចំនួនសរុប ៦ ១១៧នាក់ ។

## ក្រាហ្វិកទី១៣ ៖ តួនាទីរបស់ស្ត្រីជាមន្ត្រីការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត



របាយការណ៍សង្កេតការណ៍របស់ខុមហ្វ្រែល ស្តីពី« *ការចូលរួម នយោបាយរបស់ស្ត្រី ក្នុងការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១៧*» បានរកឃើញ ថា នៅថ្ងៃបោះឆ្នោតក្នុងចំណោម ១៣៦ ការិយាល័យបោះឆ្នោត មានសមាសភាពមន្ត្រីការិយាល័យបោះឆ្នោតជាស្ត្រីចំនួន**៣១៥នាក់ (៣៨,៦០%)នៃចំនួនសរុប៨១៦នាក់** ក្នុងនោះស្ត្រីជាមន្ត្រីការិយាល័យបោះឆ្នោត**ភាគច្រើន**មានតួនាទីជា**សមាជិកទី១ ចំនួន ២៨,៨៨%** ខណៈដែលតួនាទីជា**ប្រធាន**មាន**តិចតួច**ចំនួន **៧,៦១%** ។ ទោះបីជាយ៉ាងណា ការិយាល័យបោះឆ្នោតខ្លះមាន**សុទ្ធតែស្ត្រី**ជាមន្ត្រីការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតដូចជា ការិយាល័យបោះឆ្នោតលេខ០២៣៦ នៅភូមិត្រពាំងទន្ទឹម ឃុំរមទម ស្រុករវៀង ខេត្តព្រះវិហារ[2] ។ ការិយាល័យបោះឆ្នោតលេខ០០៤៨ និងការិយាល័យបោះឆ្នោតលេខ០០៤៩ នៅ ភូមិឈើទាលភ្លោះ ឃុំកញ្ជោរ ស្រុកឆ្លូង ខេត្តក្រចេះ មាន**ស្ត្រី៤នាក់** (តំបន់គោលដៅរបស់គសន) ។

## ៤- អ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយជាស្ត្រី



ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧នេះ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍន៍ បណ្តាស្ថានទូតនានាប្រចាំនៅកម្ពុជា និងគណបក្សនយោបាយ បានដាក់ពង្រាយអ្នកសង្កេតការណ៍ និងតំណាងរបស់ខ្លួនតាមការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់នៃរាជធានី ខេត្ត ក្រុងនីមួយៗ ដើម្បីចូលរួមសង្កេត ឃ្លាំមើលដំណើរការរៀបចំការបោះឆ្នោត ។ តាមតួលេខផ្លូវការរបស់ គ.ជ.ប បានបង្ហាញនូវចំនួនអ្នកសង្កេតការណ៍ជាតិ អន្តរជាតិ និងភ្នាក់ងារគណបក្សនយោបាយ ដូចខាងក្រោម៖

### ❖ អ្នកសង្កេតការណ៍ជាតិជាស្ត្រី

**អ្នកសង្កេតការណ៍ជាតិជាស្ត្រី** ដែលគ.ជ.បបានអនុញ្ញាតិឲ្យចូលរួមសង្កេតមើលដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ មានចំនួន **៣៩ ៥៥៥នាក់ ស្មើនឹង ៥២,៩៧%** ក្នុងនោះ**ស្ត្រីពិការ**ចំនួន **៦១នាក់ (0,១៥%)** នៃចំនួនសរុប ៧៤ ៦៧១នាក់មកពីសមាគម-អង្គការមិនមែនរដ្ឋាភិបាល ចំនួន២១ ។ គួរកត់សម្គាល់ថា ការបោះឆ្នោតលើកនេះ **អ្នកសង្កេតការណ៍ជាស្ត្រីមានចំនួនច្រើនលើសលុប** ជាក់ស្តែង សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ (CWPD)បានដាក់ពង្រាយអ្នកសង្កេតការណ៍ស្ត្រី របស់ខ្លួនដល់ទៅ **២០ ៧១៧នាក់ ស្មើនឹង ៩៩,៦៣%** នៃចំនួនសរុប ២០ ៧៩៣នាក់ ។ រីឯអង្គការខុមហ្វ្រែលក៏បានបង្កើនអ្នកសង្កេតការណ៍ស្ត្រីរបស់ខ្លួនដែរ គឺចំនួន **៦ ១៥៣នាក់ ស្មើនឹង ៥២,២០%**

[2] របាយការណ៍សង្កេតការណ៍របស់ខុមហ្វ្រែល ស្តីពី «ការចូលរួមនយោបាយរបស់ស្ត្រីក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧» ក្នុងខេត្តគោលដៅ៖ ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង ខេត្តតាកែវ និងខេត្តព្រះវិហារ

នៃចំនួនសរុប ១៤ ៥៨០នាក់ ដែលចំនួននេះមានការ**កើនឡើង ៣,៧៦%** (**១ ៧៤៤នាក់**) បើធៀបនឹងការបោះឆ្នោតជាតិឆ្នាំ២០១៣ ស្ត្រីមានចំនួនតែ ៤ ៤០៩នាក់ ស្មើនឹង ៣៨,៨៥%)ប៉ុណ្ណោះ ។ *(ព័ត៌មានលម្អិតសូមមើលឧបសម្ព័ន្ធ៥)*



មានការប្រឈមតិចតួចមកលើ អ្នកសង្កេតការណ៍ស្ត្រីរបស់ខុមហ្វ្រែលនៅថ្ងៃបោះឆ្នោត ដូចជា មន្ត្រីការិយាល័យបោះឆ្នោតមិនផ្តល់ អាទិភាពឲ្យអ្នកសង្កេតការណ៍ស្ត្រីខុមហ្វ្រែលបានបោះឆ្នោតមុន និងមិនអនុញ្ញាតឲ្យចូលសង្កេតការណ៍ នៅក្នុងការិយា-ល័យបោះឆ្នោត ។

ជាក់ស្តែង ករណីកើតឡើងទៅលើ លោកស្រី **អ៊ុច សុធា** ជាអ្នកសង្កេតការណ៍ស្ត្រីរបស់ខុមហ្វ្រែលនៅឃុំកំពង់ឆ្នាំង ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង បានជួបបញ្ហា២ករណី ៖ **ករណីទី១** មន្ត្រីការិយាល័យបោះឆ្នោតមិនផ្តល់អាទិភាពឲ្យលោកស្រី **អ៊ុច សុធា** ចូលបោះឆ្នោត ខណៈពេលដែលលោកស្រី **អ៊ុច សុធា** ត្រូវមានភារកិច្ចសង្កេតការណ៍នៅការិយាល័យបោះឆ្នោតលេខ ១៥៥០ ។ **ករណីទី២** លោកស្រី **អ៊ុច សុធា** មិនត្រូវបានអនុញ្ញាតឲ្យចូលសង្កេតការណ៍ក្នុងការិយាល័យបោះឆ្នោតលេខ ១៥៥០ ដែលមន្ត្រីការិយាល័យបោះឆ្នោតនេះអះអាងថា មានអ្នកសង្កេតការណ៍គ្រប់ហើយប៉ុន្តែការពិតគ្មានអ្នកសង្កេតការណ៍ខុមហ្វ្រែលម្នាក់សោះក្នុងការិយាល័យបោះឆ្នោតនេះ។ ក្រោយមក ដោយមានការតវ៉ាខ្លាំងពីអ្នកសង្កេតការណ៍ស្ត្រីរូបនេះ និងមានមន្ត្រីគយ/សបមកធ្វើអន្តរាគមន៍ លោកស្រី **អ៊ុច សុធា** ក៏ត្រូវបានអនុញ្ញាតឲ្យចូលសង្កេតការណ៍ក្នុងការិយាល័យបោះឆ្នោតនេះ ។

## ❖ *អ្នកសង្កេតការណ៍អន្តរជាតិជាស្ត្រី*

**អ្នកសង្កេតការណ៍អន្តរជាតិជាស្ត្រី**ដែលគ.ជ.បបានអនុញ្ញាតិ មានចំនួន **១២៤នាក់** ស្មើនឹង **៣២,២៩%** នៃចំនួនសរុប៣៨៤នាក់ដែលមកពី ***ស្ថានទូត អង្គការអន្តរជាតិចំនួន៣៤*** ។ ចំនួនប្រុស-ស្រីនៃអ្នកសង្កេត-ការណ៍អន្តរជាតិមានការ**កើនឡើង**ចំនួន **៩២នាក់** ពី ២៩២នាក់ក្នុងការបោះឆ្នោតជាតិឆ្នាំ២០១៣ ទៅ ៣៨៤នាក់ក្នុងការបោះឆ្នោតឃុំ សង្កាត់ ឆ្នាំ២០១៧ ។ *(ព័ត៌មានលម្អិតសូមមើលឧបសម្ព័ន្ធ៦)*

## ❖ *ភ្នាក់ងារគណបក្សនយោបាយជាស្ត្រី*

**ភ្នាក់ងារគណបក្សនយោបាយជាស្ត្រី**ដែលអនុញ្ញាតិដោយ គ.ជ.ប មានចំនួន **២២ ៩២៤នាក់** ស្មើនឹង **២១,៨១%** នៃចំនួនសរុបស្រី-ប្រុស ១០៥ ០៧៦នាក់ មកពី **១២ គណបក្សនយោបាយ** សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ។ ចំនួនសរុបនេះ មានការ**កើនឡើង ៥ ៥៩៥នាក់**

បើធៀបនឹងឆ្នាំ២០១៣ ការបោះឆ្នោតជាតិមានចំនួនតែ ៩៩ ៤៨១នាក់ ។ (ព័ត៌មានលម្អិតសូមមើលឧបសម្ព័ន្ធ៧)

## ៦. អ្នកបោះឆ្នោតស្ត្រី

### ❖ ស្ត្រីក្នុងដំណើរការចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៦

| ចំនួនអ្នកបានចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៦ | | | |
|---|---|---|---|
| ចំនួនសរុប ប្រុស-ស្រី | | ចំនួនស្ត្រី | |
| ចំនួន | % | ចំនួន | %ស្ត្រី |
| ៧ ៨៦៥ ០៣៣ | ៨១,៣៨% | ៤ ២១០ ៩១៤ | ៥៣,៥៣% |

*(សូមមើលព័ត៌មានលម្អិតនៅក្នុងឧបសម្ព័ន្ធ៨)*

**ស្ត្រីបានចុះឈ្មោះបោះឆ្នោតថ្មី** ឆ្នាំ២០១៦ក្នុងបញ្ជីបោះឆ្នោតផ្លូវការ ចំនួន **៤ ២១០ ៩១៤ នាក់ ស្មើនឹង ៥៣,៥៣%** នៃចំនួនប្រុស-ស្រីដែលបានចុះឈ្មោះសរុប **៧ ៨៦៥ ០៣៣នាក់** ហើយក៏មិនមានករណីមិនប្រក្រតីណាមួយមកលើស្ត្រីក្នុងការចូលរួមនយោបាយក្នុងដំណើរការចុះឈ្មោះបោះឆ្នោតនេះដែរ ។ ទោះបីជាយ៉ាងណាក៏ដោយ មានការ**ខកខានប្រើប្រាស់សិទ្ធិរបស់ខ្លួន**ក្នុងការចុះឈ្មោះបោះឆ្នោត ដូចជា ចាស់ជរា ស្ត្រីទើបសម្រាលកូន ពិការទូជន ដែលមិនមានក្រុមចល័តទៅចុះឈ្មោះបោះឆ្នោតដល់ផ្ទះ ឬទីកន្លែងរបស់ពួកគាត់ ជាពិសេស កម្មករ កម្មការិនីចំណាកស្រុកទៅក្រៅប្រទេសដែលមិនមាននីតិវិធីសម្របសម្រួលណាមួយឲ្យពួកគាត់បានអនុវត្តសិទ្ធិរបស់ខ្លួនស្របនឹងរដ្ឋធម្មនុញ្ញ ដែលបានធានាអំពីសិទ្ធិនេះ ។

ខាងក្រោមនេះ ជាមតិរបស់ស្ត្រីដែលបានចុះឈ្មោះ និងមិនបានចុះឈ្មោះបោះឆ្នោត[3] ៖

### ❖ *មតិស្ត្រីដែលបានចុះឈ្មោះបោះឆ្នោត*

| ស្ត្រីដែលបានចុះឈ្មោះបោះឆ្នោត បានបង្ហាញហេតុផលមួយចំនួនថា ពួកគេទៅចុះឈ្មោះបោះឆ្នោតគឺដើម្បី ៖ |
|---|
| *ប្រទេសជាតិ* |
| *ចង់ឲ្យបក្សដែលខ្លួនស្រឡាញ់បានឈ្នះ* |

[3] ខុមហ្វ្រែលបានដាក់ពង្រាយអ្នកសង្កេតការណ៍ស្ត្រីក្នុងខេត្តគោលដៅ៥ ៖ ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង ខេត្តតាកែវ និងខេត្តព្រះវិហារ ក្នុងរយៈពេលនៃការចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៦

| |
|---|
| *អភិវឌ្ឍន៍ក្នុងឃុំ សង្កាត់* |
| *បំពេញកាតព្វកិច្ចជាពលរដ្ឋ* |
| *សម្លេងឆ្នោតរបស់ខ្លួនគឺសំខាន់ក្នុងការជ្រើសរើសតំណាងល្អ* |

- ***មតិស្ត្រីដែលមិនបានចុះឈ្មោះបោះឆ្នោត***

| ស្ត្រីដែលមិនបានចុះឈ្មោះបោះឆ្នោត បានបង្ហាញពីហេតុផលរបស់ខ្លួនថា ៖ |
|---|
| *បាត់/គ្មាន អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ* |
| *គ្មានសំបុត្រកំណើត* |
| *ខ្លួនមានអាយុច្រើន* |
| *គិតថាពិបាកក្នុងការទៅចុះឈ្មោះបោះឆ្នោត* |
| *រវល់នឹងកិច្ចការងារ* |
| *មុខរបរចិញ្ចឹមជីវិតប្រចាំថ្ងៃ* |
| *ទីទាល់ក្រ* |
| *ជាជនទុរគត* |
| *មិនមានឯកសារអ្វីទាំងអស់* |
| *អស់ជំនឿគ្មានការរីកចំរើនអ្វីសោះក្នុងឃុំរបស់ខ្លួន* |

ក្នុងរយៈពេលនៃការចុះឈ្មោះបោះឆ្នោតថ្មី **គ.ជ.បបានខិតខំ**ធ្វើសកម្មភាពអប់រំ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីការចុះឈ្មោះបោះឆ្នោត**យ៉ាងផុលផុស និងទូលំទូលាយ**ដោយប្រើប្រាស់ឯកសារជាច្រើនប្រភេទ និងវិធីសាស្រ្តផ្សេងៗគ្នានៅទូទាំងប្រទេស ខណៈដែល**២ខែចុងក្រោយ**សកម្មភាពអប់រំផ្សព្វផ្សាយទាំងនេះ**ពុំសូវមានភាពសកម្ម និងមានការថយចុះខ្លាំង** ។ ជាមួយគ្នានេះដែរ **គ.ជ.បបានសហការយ៉ាងជិតស្និទ្ធជាមួយអង្គការសង្គមស៊ីវិល និងខិតខំអន្តរាគមន៍ជាមួយអាជ្ញាធរដែនដី** ព្រមទាំងបានផ្តត់ផ្គង់ឯកសារអប់រំមួយចំនួនដល់ក្រុមយុវជនក្នុងយុទ្ធនាការអប់រំផ្សព្វផ្សាយពិសេស អំពីការចុះឈ្មោះបោះឆ្នោតដល់ប្រជាពលរដ្ឋក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប អកអំបុក និងសំពះព្រះខែរយៈពេល៣ថ្ងៃ ។ ប៉ុន្តែគួរឲ្យសោកស្តាយ **គ.ជ.ប មិនអាចការពារយុទ្ធនាការពិសេសនេះជាមួយការប្រើប្រាស់ ឧបករណ៍បំពងសម្លេង**ដែលជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុត បើទោះបីមានលិខិតអនុញ្ញាតរបស់សាលារាជធានីភ្នំពេញក៏ដោយ ។

### ❖ *ថ្ងៃបោះឆ្នោត*






**មានអ្នកបោះឆ្នោតចំនួន ៧ ១០៧ ៣៩៥ នាក់ ស្មើនឹង ៩០,៣៧%** ក្នុងនោះតាមការប៉ាន់ស្មាន **អ្នកបោះឆ្នោតស្ត្រីច្រើនជាង**អ្នកបោះឆ្នោតបុរស*បានបោះឆ្នោត*នៅថ្ងៃអាទិត្យ ទី០៤ ខែមិថុនា ឆ្នាំ២០១៧ ។

**អ្នកមានសិទ្ធិបោះឆ្នោតចំនួន ៧៥៧ ៦៣៨នាក់ ស្មើនឹង ៩,៦៣%***មិនបានទៅបោះឆ្នោត និង/ឬមិនបានបោះឆ្នោត* ។ ការខកខានមិនបានទៅបោះឆ្នោត និង/ឬមិនបានបោះឆ្នោតនេះ ក៏អាចមានស្ត្រីមួយចំនួនធំផងដែរ ។ ពួកគេបានជួបការលំបាកខ្លះក្នុងការទៅបោះឆ្នោតនៅថ្ងៃបោះឆ្នោត ដោយសារមានមូលហេតុ និងភាពមិនប្រក្រតីមួយចំនួនដែលប៉ះពាល់ដល់សិទ្ធិអ្នកបោះឆ្នោត ជាពិសេសអ្នកបោះឆ្នោតស្ត្រី ដូចជា៖ *(១)រកឈ្មោះមិនឃើញនៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត (២)ឈ្មោះ និងទិន្នន័យមិនត្រឹមត្រូវនៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត (៣)រវល់ធ្វើកិច្ចការផ្ទះ និងស្រែចម្ការ (៤)ជាប់រវល់លក់ដូរ (៥)បាត់/គ្មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និង (៦)ជួបបញ្ហាដោយយថាហេតុ* ។

របាយការណ៍សង្កេតការណ៍ស្ត្រីរបស់ខុមហ្វ្រែល[4] បានរកឃើញថា **៣៨,៤៦%**នៃអ្នកបោះឆ្នោតស្ត្រីខកខានមិនបានទៅបោះឆ្នោត និង/ឬមិនបានបោះឆ្នោត ដោយសារពួកគេជួបនូវភាពមិនប្រក្រតីមួយចំនួនដូចជា *រកឈ្មោះមិនឃើញ ឈ្មោះ និងទិន្នន័យមិនត្រឹមត្រូវនៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត* និងមាន*មូលហេតុមួយចំនួនដូចជា រវល់ធ្វើកិច្ចការផ្ទះ និងស្រែចម្ការ ជាប់រវល់លក់ដូរ បាត់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សម្រាលកូន គ្រោះថ្នាក់ចរាចរណ៍ មានសាច់ញាតិទទួលមរណភាព និងមិនបានចុះឈ្មោះបោះឆ្នោត* ។ ជាក់ស្តែង ក្នុងចំណោម ១៣៦ការិយាល័យបោះឆ្នោត មាន១៤ការិយាល័យបោះឆ្នោតដែលមានភាពមិនប្រក្រតីមួយចំនួនបានកើតឡើងចំពោះអ្នកបោះឆ្នោតស្ត្រីដែលមានចំនួនសរុប **៤១ករណី** ក្នុងនោះ **៣១ករណី**មានការ**ខុសទិន្នន័យ**របស់អ្នកបោះឆ្នោត **មិនមាន**អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ រកឈ្មោះមិន

[4]ខុមហ្វ្រែលបានដាក់ពង្រាយអ្នកសង្កេតការណ៍ស្ត្រីរយៈពេលវែង និងខ្លីចំនួន១២២នាក់ដើម្បីសង្កេត ឃ្លាំមើលការចូលរួមនយោបាយរបស់ស្ត្រីក្នុងដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ ក្នុងខេត្តគោលដៅ៥ គឺខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង ខេត្តតាកែវ និងខេត្តព្រះវិហារ

**ឃើញ**នៅក្នុងបញ្ជីឈ្មោះបោះឆ្នោត មិនដឹងពីការ**ផ្លាស់ប្តូរលេខកូត**ការិយាល័យបោះឆ្នោតរបស់ខ្លួនព្រោះមិនបានទទួលប័ណ្ណព័ត៌មានអ្នកបោះឆ្នោត និងជួបនូវ**បញ្ហាជាយថាហេតុ**ដូចជា គ្រោះថ្នាក់ចរាចរ ការសម្រាលកូន សាច់ញាតិទទួលមរណភាព ។ **៧ករណី** អ្នកបោះឆ្នោត**ចូលខុស**ការិយាល័យបោះឆ្នោត និង**៣ករណី**មានការប្រើអាកប្បកិរិយា**បៀតបៀន** ឬមានការ**រើសអើង** ដូចជា ការប្រើប្រាស់ពាក្យសម្តីមិនសមរម្យ កាយវិការដែលធ្វើឲ្យស្ត្រីមានការភ័យខ្លាច ឬបាត់បង់ទំនុកចិត្តក្នុងការបោះឆ្នោត ។



របាយការណ៍សង្កេតការណ៍ស្ត្រីរបស់ខុមហ្វ្រែល បានរកឃើញទៀតថា ក្នុងចំណោម**ការិយាល័យបោះឆ្នោតសរុបចំនួន** ***៩៧*** មាន***៧៨*****ការិយាល័យបោះឆ្នោត ស្មើនឹង** ***៨០,៤១%*** **ស្ត្រីបានមកបោះឆ្នោត ច្រើនជាងបុរស** ដែលមានចន្លោះពី **៥០,៧៨% ដល់ ៨០, ៣៨%** ។

ខាងក្រោមនេះជាទិន្នន័យលំអិតតាមខេត្តនីមួយៗ ស្តីពីការចូលរួមរបស់ស្ត្រីនៅថ្ងៃបោះឆ្នោត ៖

- ***ខេត្តតាកែវ*** ក្នុងចំណោមការិយាល័យបោះឆ្នោតសរុបចំនួន២៨ មានស្ត្រីបានបោះឆ្នោតច្រើនជាងបុរសចំនួន**២៥ការិយាល័យបោះឆ្នោត ស្មើនឹង ៨៩,២៨%** គឺចន្លោះពី **៥០,៧៨%ដល់ ៧០,២៥%** ។
- ***ខេត្តព្រះវិហារ*** ក្នុងចំណោមការិយាល័យបោះឆ្នោត១៧ មាន**១១ការិយាល័យបោះឆ្នោត ស្មើនឹង ៦៤,៧០%ស្ត្រីបានបោះឆ្នោតច្រើនជាងបុរស** គឺចន្លោះពី **៥០.៨៦% ដល់ ៦០.៦៧%** ។
- ***ខេត្តកំពង់ឆ្នាំង*** ក្នុងចំណោមការិយាល័យបោះឆ្នោតចំនួន៨ មាន**៦ការិយាល័យបោះឆ្នោត ស្មើនឹង ៧៥% ស្ត្រីបានបោះឆ្នោតច្រើនជាងបុរស** ដែលមានចន្លោះពី **៥១,៦០% ដល់ ៦៣,៤៧%** ។
- ***ខេត្តកំពង់ធំ*** ក្នុងចំណោមការិយាល័យបោះឆ្នោតចំនួន១៩ មាន**១៧ការិយាល័យបោះឆ្នោត ស្មើនឹង ៨៩,៤៧%ស្ត្រីបានបោះឆ្នោតច្រើនជាងបុរស** ដែលមានចន្លោះពី **៥២,១៦% ដល់ ៨០,៣៨%** ។
- ***ខេត្តកំពង់ចាម*** ក្នុងចំណោមការិយាល័យបោះឆ្នោតចំនួន២៥ មាន**១៩ការិយាល័យបោះឆ្នោត ស្មើនឹង ៧៦%**ស្ត្រីបានបោះឆ្នោតច្រើនជាងបុរស ដែលមានចន្លោះពី **៥០,៨៦% ដល់ ៧៣,៧៨%** ។

ការស្ទង់មតិរហ័ស (Rapid Survey) ស្តីពីការចូលរួមនយោបាយរបស់ស្ត្រី នៅក្នុងខេត្តគោលដៅ៥របស់ខុមហ្វ្រែលនៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៧បន្ទាប់ពីថ្ងៃបោះឆ្នោត ទៅលើ ***«ស្ត្រីបានបោះឆ្នោត ឬមានទឹកខ្មៅនៅម្រាមដៃ និងស្ត្រីមិនបានបោះឆ្នោត ឬមិនមានទឹកខ្មៅនៅម្រាមដៃ»*** បានរកឃើញថា ក្នុងចំណោមស្ត្រីសរុប **៣៩នាក់**ដែលបានសម្ភាសន៍ មាន **៦១,៥៤%**នៃស្ត្រីបានបោះឆ្នោតបានលើកពីមូលហេតុ

ដែលខ្លួនបានចេញទៅបោះឆ្នោត។ **៣៨,៤៦%**នៃស្ត្រីមិនបានបោះឆ្នោតបានលើកឡើងពីបញ្ហារបស់ខ្លួនដែលមិនអាចចេញទៅបោះឆ្នោតបាន ។

- ៦១,៥៤%នៃស្ត្រីដែលបានទៅបោះឆ្នោត បានលើកឡើងថា ពួកគាត់ចង់ទៅបោះឆ្នោតដោយសារៈ

| មូលហេតុ |
|---|
| ពួកគាត់ចង់ប្រើប្រាស់សិទ្ធិក្នុងការបោះឆ្នោត |
| ពួកគាត់គាំទ្រគណបក្សដែលគាត់ពេញចិត្ត |
| ព្រោះគ្រប់ៗគ្នាគេទៅបោះឆ្នោត |
| ការចូលរួមរបស់ស្ត្រីមានសារៈសំខាន់សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១៧ |
| សង្ឃឹមថានឹងទទួលបានតំណាងស្ត្រីដែលជាមេដឹកនាំល្អ និងមានការគិតគូដល់បញ្ហាស្ត្រី និងកុមារ |
| សង្ឃឹមថានឹងមានការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងឃុំ សង្កាត់របស់ខ្លួន |

- ៣៨,៤៦%នៃស្ត្រីដែលមិនបានទៅបោះឆ្នោត បានលើកឡើងថា ពួកគាត់មិនចង់ទៅបោះឆ្នោតដោយសារៈ

| មូលហេតុ |
|---|
| មិនមានពេលទៅបោះឆ្នោត |
| មិនគិត ឬមិនយកចិត្តទុកដាក់លើបញ្ហានយោបាយ |
| រកឈ្មោះមិនឃើញ |
| ឈ្មោះ និងទិន្នន័យមិនត្រឹមត្រូវ (ក្នុងបញ្ជីឈ្មោះបោះឆ្នោត) |
| បាត់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ |
| មានភារកិច្ចផ្ទាល់ខ្លួន |
| មិនបានទៅចុះឈ្មោះបោះឆ្នោត |

# III. សេចក្តីសន្និដ្ឋាន និងសង្ខេប

មានការ**ថយចុះចំនួនស្ត្រីជាប់ឆ្នោត**ជាក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ ប៉ុន្តែមានការ**កើនឡើងចំនួនមេឃុំ ចៅសង្កាត់ស្ត្រី** ។

បេក្ខជនស្ត្រីមួយចំនួន **នៅតែប្រឈមនឹងការរើសអើង** មើលងាយពីសំណាក់បុរសៗថាស្ត្រីគ្មានសមត្ថភាពធ្វើនយោបាយ ។

**មានការយកចិត្តទុកដាក់ពីគណបក្សនយោបាយ និងបេក្ខជនស្ត្រី**ទាក់ទងនឹង**ការដោះស្រាយបញ្ហា ស្ត្រី និងកុមារ**នៅក្នុងកម្មវិធីនយោបាយរបស់ខ្លួន ។ គណបក្ស និងបេក្ខជនមួយចំនួនក៏បានបង្ហាញពីការបង្កើត**គោលនយោបាយសមភាពយេនឌ័រ** ដើម្បីលើកស្ទួយការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត លើកស្ទួយសិទ្ធិកុមារ កុមារពិការ កុមារកំព្រា កុមារមកពីគ្រួសារក្រីក្រ គោរពសិទ្ធិស្ត្រី និងសិទ្ធិជនជាតិភាគតិច ព្រមទាំងជួយដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋ ជាពិសេសស្ត្រីមានផ្ទៃពោះ ស្ត្រីមេម៉ាយ ចាស់ជរា ជនពិការ និងកុមារដែលមានជីវភាពក្រីក្រ។

**ស្ត្រីបានចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៦**ក្នុងបញ្ជីបោះឆ្នោតផ្លូវការ ចំនួន **៤ ២១០ ៩១៤នាក់ ស្មើនឹង ៥៣,៥៣%** នៃចំនួនប្រុស-ស្រីដែលបានចុះឈ្មោះ**សរុប ៧ ៨៦៥ ០៣៣**នាក់ ហើយ**អ្នកបោះឆ្នោតស្ត្រីច្រើនជាងបុរសបានចេញទៅបោះឆ្នោតនៅថ្ងៃបោះឆ្នោត** ។

អ្នកបោះឆ្នោតស្ត្រី **ច្រើនជាង** បុរសបានចេញ ទៅបោះឆ្នោតនៅតាមការិយាល័យបោះឆ្នោតនីមួយៗ ចន្លោះពី **៥០,៧៨%** ទៅ **៨០,៣៨%** ។ ទោះបីជាយ៉ាងណាក៏ដោយ មានការ**ខកខានប្រើប្រាស់សិទ្ធិ**របស់ស្ត្រីចំណាកស្រុកទៅក្រៅប្រទេសក្នុងការចុះឈ្មោះ បោះឆ្នោត ។

**៣៨,៦០%**នៃស្ត្រីជាមន្ត្រីការិយាល័យបោះឆ្នោត**ភាគច្រើន**មានតួនាទីជា**សមាជិកទី១** ខណៈ ដែលតួនាទីជា**ប្រធានមានចំនួនតិចតួច** ។ ទោះបីជាយ៉ាងណា ការិយាល័យបោះឆ្នោតខ្លះ មាន**សុទ្ធតែស្ត្រី**ជាមន្ត្រីការិយាល័យបោះឆ្នោត ។

# IV. អនុសាសន៍

ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងផ្តល់អំណាចនយោបាយដល់ស្ត្រី វិធានការមួយចំនួនគួរដោះស្រាយ៖

## ១- ការកំណត់វិធានការពិសេសនៅក្នុងច្បាប់បោះឆ្នោត

**“វិធានការពិសេសបណ្តោះអាសន្ន”** ជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយដែលអាចលើកទឹកចិត្តគ្រប់គណបក្សនយោបាយដាក់បេក្ខភាពស្ត្រីក្នុងបញ្ជីបេក្ខជនរបស់គណបក្ស ។ ការលើកទឹកចិត្តដើម្បីអនុវត្តរបស់គណបក្សនយោបាយនេះ គឺត្រូវបង្កើតក្នុងក្របខណ្ឌច្បាប់ គឺនិយាយដល់ការធ្វើវិសោធនកម្មច្បាប់សម្រាប់ការបោះឆ្នោត ។ វិសោធកម្មច្បាប់នេះកែលម្អបន្ថែមលក្ខណៈនៃការដាក់ពាក្យចុះឈ្មោះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលតម្រូវឲ្យដាក់**ឆ្លាស់គ្នា**រវាងបេក្ខជនស្ត្រី និងបុរសតាមលំដាប់លេខរៀងពីលើដល់ក្រោមនៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះរបស់គណបក្សនយោបាយ ។ ការធ្វើវិសោធនកម្មច្បាប់ ស្តីពី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ **ជំពូកទី៤ មាត្រា៣៧ថ្មី** ***«បញ្ជីបេក្ខជនឈរឈ្មោះតាម មណ្ឌលនីមួយៗត្រូវមានបេក្ខជនស្ត្រី និងបេក្ខជនបុរសឆ្លាស់គ្នាតាមលំដាប់ លេខរៀងពីលើដល់ក្រោម»*** និងច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ **ជំពូកទី៧ មាត្រា៥៩ថ្មី** ***«បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗត្រូវមានឈ្មោះបេក្ខជនតាមលំដាប់លេខរៀង និងឆ្លាស់គ្នារវាងស្ត្រី និងបុរសពីលើដល់ក្រោម»*** ក្នុងបំណងធានាថា បេក្ខភាពស្ត្រីត្រូវបានឈរឈ្មោះក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយដោយដាក់ឆ្លាស់គ្នារវាងស្ត្រី និងបុរសតាមលំដាប់លេខរៀងពីលើ ដល់ ក្រោមដែលជាវិធានការសមស្រប និងមានប្រសិទ្ធភាពបំផុតក្នុងការធ្វើឲ្យមានសមភាពយេនឌ័រពិតប្រាកដ ។

## ២-លុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី

ត្រូវផ្តល់ឱកាសចំពោះស្ត្រី និងលុបបំបាត់រាល់ទម្រង់នៃការរើសអើងទាំងឡាយ ដើម្បីលើកតម្កើង និងលើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងកិច្ចការនយោបាយ ធ្វើយ៉ាងណាឲ្យមានសមភាពនៃតំណាងអ្នកជាប់ឆ្នោតរវាងស្ត្រី និងបុរស រួមទាំងទទួលបាននូវអំណាចនយោបាយស្មើគ្នាតាំងពីថ្នាក់មូលដ្ឋាន រហូតដល់ថ្នាក់ជាតិ។

## ៣-ការអភិវឌ្ឍន៍សមត្ថភាពស្ត្រី

ចាំបាច់ត្រូវតែផ្តល់វគ្គហ្វឹកហ្វឺនខ្លីៗដើម្បីអភិវឌ្ឍន៍សមត្ថភាពដល់បេក្ខជនស្ត្រី និងស្ត្រីជាប់ឆ្នោត ដើម្បីបង្កើនភាពជឿជាក់ និងប្រសិទ្ធភាពការងារក្រោយពេលជាប់ឆ្នោត។ ជាងនេះទៅទៀត ត្រូវមានការរៀបចំ និងបណ្តុះបណ្តាលដល់អ្នកដឹកនាំជាស្ត្រីដែលមានសក្តានុពល និងសកម្មជនស្ត្រីនយោបាយជំនាន់ក្រោយទៀត។

## ៤-បរិយាកាសនយោបាយល្អ

បង្កើតបរិយាកាសល្អសម្រាប់ស្ត្រី និងធានានូវសុវត្ថិភាពសម្រាប់បេក្ខនារី ។ រាជរដ្ឋាភិបាលអាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងគ.ជ.បបន្តអនុវត្តន៍ឲ្យបានតឹងរឹងនូវវិធានការពិសេស និងអន្តរាគមន៍ក្នុងការបញ្ឈប់រាល់សកម្មភាពគំរាមកំហែង បំភិតបំភ័យ និងអំពើហិង្សាលើអ្នកបោះឆ្នោត បេក្ខនារី និងសកម្មជនស្ត្រីនយោបាយ។

## ៥-ចែករំលែកព័ត៌មានតាមប្រព័ន្ធផ្សព្វផ្សាយ

ព័ត៌មានត្រូវតែមានលក្ខណៈងាយស្រួលក្នុងការទទួលយកសម្រាប់ប្រជាពលរដ្ឋតាមរយៈប្រព័ន្ធផ្សព្វផ្សាយ។ ប្រព័ន្ធផ្សព្វផ្សាយត្រូវចែករំលែកព័ត៌មាន និងផ្សព្វផ្សាយជាសាធារណៈ ពិសេសសហគមន៍មូលដ្ឋាន *អំពីសារៈសំខាន់ និងតួនាទីរបស់ស្ត្រីនៅក្នុងវិស័យនយោបាយ ការងារបោះឆ្នោត ការបំពេញភារកិច្ច និងសមិទ្ធិផលដែលពួកគេសម្រេចបានមុន និងក្នុងពេលដែលស្ត្រីកំពុងបំពេញការងារ ការសម្រេចចិត្ត ការគ្រប់គ្រង និងការចាត់ចែងធនធានជាដើម ។* សេចក្តីត្រូវការផ្សេងទៀត គឺបង្កើនប្រសិទ្ធភាពបញ្ជូនព័ត៌មាន និងធ្វើការអប់រំប្រជាពលរដ្ឋមូលដ្ឋាន អំពីតួនាទីរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានបោះឆ្នោតដោយប្រជាពលរដ្ឋ ការទទួលខុសត្រូវ និងអាណត្តិ (អំណាចចាត់ចែងការងារដែលច្បាប់ប្រគល់ឲ្យ) របស់ពួកគេ។ ធ្វើដូចនេះ ប្រជាពលរដ្ឋនឹងមានការយល់ដឹងកាន់តែច្បាស់អំពីឥទ្ធិពលនៃបេក្ខភាពស្ត្រី (បេក្ខនារី និងស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់)។

៙៙៙☆ចប់☆៚៚៚

# Appendix 1

## Number of Women Candidates by Capital-Province
## The 4th mandate Commune Council Elections 2017

| Nº | Provinces/Capital | Candidates | Women | |
|---|---|---|---|---|
| | | | Amount | Percentage (%) |
| 1 | Banteay Meanchey | 5,276 | 1,419 | 26.89% |
| 2 | BattamBang | 7,521 | 2,303 | 30.62% |
| 3 | Kampong Cham | 7,037 | 1,911 | 27.15% |
| 4 | Kampong Chhnang | 3,802 | 1,028 | 27.03% |
| 5 | Kampong Speu | 5,901 | 1,485 | 25.16% |
| 6 | Kampong Thom | 4,702 | 1,174 | 24.96% |
| 7 | Kampot | 4,050 | 916 | 22.61% |
| 8 | Kandal | 7,364 | 2,151 | 29.20% |
| 9 | Koh Kong | 873 | 210 | 24.05% |
| 10 | Kratie | 2,680 | 786 | 29.32% |
| 11 | Mondolkiri | 797 | 185 | 23.21% |
| 12 | Phnom Penh | 5,913 | 1,939 | 32.79% |
| 13 | Preah Vihear | 2,308 | 553 | 23.96% |
| 14 | Prey Veng | 7,932 | 2,308 | 29.09% |
| 15 | Pursat | 2,247 | 630 | 28.03% |
| 16 | Ratanakiri | 1,540 | 323 | 20.97% |
| 17 | Siem Reap | 6,567 | 1,707 | 25.99% |
| 18 | Preah Shihanouk | 15,04 | 369 | 24.53% |
| 19 | Stung Treng | 1,103 | 254 | 23.04% |
| 20 | Svay Rieng | 3,308 | 822 | 24.84% |
| 21 | Takoe | 5,312 | 1,240 | 23.34% |
| 22 | Kep | 237 | 73 | 30.80% |
| 23 | Pailin | 501 | 158 | 31.53% |
| 24 | Oddor Meanchey | 1,327 | 387 | 29.16% |
| 25 | Tbong Khmum | 4,793 | 1,457 | 30.39% |
| | **Grand Total** | **94,595** | **25,788** | **27.26%** |

# Appendix 2:

## Number of Elected Women by Capital- Province
## 4th mandate Commune Council Elections 2017

| Nº | Provinces/Capital | Total | Women | |
|---|---|---|---|---|
| | | | Amount | Percentage (%) |
| 1 | Banteay Meanchey | 515 | 89 | 17.28% |
| 2 | BattamBang | 814 | 148 | 18.18% |
| 3 | Kampong Cham | 817 | 106 | 12.97% |
| 4 | Kampong Chhnang | 422 | 73 | 17.30% |
| 5 | Kampong Speu | 607 | 90 | 14.78% |
| 6 | Kampong Thom | 577 | 92 | 15.94% |
| 7 | Kampot | 561 | 101 | 18% |
| 8 | Kandal | 915 | 135 | 14.75% |
| 9 | Koh Kong | 167 | 34 | 20.36% |
| 10 | Kratie | 295 | 62 | 21.02% |
| 11 | Mondolkiri | 107 | 20 | 18.69% |
| 12 | Phnom Penh | 899 | 207 | 23.02% |
| 13 | Preah Vihear | 333 | 63 | 18.92% |
| 14 | Prey Veng | 892 | 124 | 13.90% |
| 15 | Pursat | 343 | 57 | 16.62% |
| 16 | Ratanakiri | 260 | 43 | 16.54% |
| 17 | Siem Reap | 668 | 121 | 18.11% |
| 18 | Preah Shihanouk | 177 | 28 | 15.82% |
| 19 | Stung Treng | 176 | 38 | 21.59% |
| 20 | Svay Rieng | 518 | 92 | 17.76% |
| 21 | Takoe | 736 | 92 | 12.50% |
| 22 | Kep | 31 | 7 | 22.58% |
| 23 | Pailin | 52 | 15 | 28.85% |
| 24 | Oddor Meanchey | 152 | 36 | 23.68% |
| 25 | Tbong Khmum | 536 | 67 | 12.50% |
| **Grand Total** | | **11,572** | **1,940** | **16.76%** |

## Appendix 3

**Number of Commune/Sangkat without any elected women as Commune/Sangkat councilors**

| N$^{O}$ | Province | District | Commune | Commune without women | Percentage |
|---|---|---|---|---|---|
| 1 | Kandal | 11 | 127 | 29 | 22.83% |
| 2 | KohKong | 7 | 29 | 6 | 20.69% |
| 3 | PreyVeng | 13 | 116 | 27 | 23.28% |
| 4 | Pursat | 6 | 49 | 11 | 22.45% |
| 5 | Ratanakiri | 9 | 50 | 11 | 22% |
| 6 | SiemReap | 12 | 100 | 25 | 25% |
| 7 | Sihanouk | 4 | 29 | 10 | 34.48% |
| 8 | StungTreng | 5 | 34 | 3 | 8.82% |
| 9 | BTM | 9 | 65 | 12 | 18.46% |
| 10 | BTB | 14 | 102 | 20 | 19.61% |
| 11 | KompongCham | 10 | 109 | 36 | 33.03% |
| 12 | KompongChnang | 8 | 70 | 20 | 28.57% |
| 13 | KompongSpou | 7 | 87 | 17 | 19.54% |
| 14 | KompongThom | 8 | 81 | 17 | 20.99% |
| 15 | Kompot | 8 | 93 | 9 | 9.68% |
| 16 | SvayReing | 8 | 80 | 13 | 16.25% |
| 17 | Takeo | 10 | 100 | 28 | 28% |
| 18 | Kep | 2 | 5 | 1 | 20% |
| 19 | Peilin | 2 | 8 | 1 | 12.5% |
| 20 | OrdorMeanchhey | 5 | 24 | 3 | 12.5% |
| 21 | TboungKhmom | 7 | 64 | 16 | 25% |
| 22 | Mondolkiri | 5 | 21 | 2 | 9.52% |
| 23 | PhnomPenh | 12 | 105 | 18 | 17.14% |
| 24 | PreahVihear | 8 | 51 | 6 | 11.76% |
| 25 | Kratie | 6 | 47 | 3 | 6.38% |
| | **Total** | **196** | **1646** | **344** | **21%** |

# Appendix 4

## Women Commune/Sangkat Chiefs

### បញ្ជីឈ្មោះមេឃុំ / ចៅសង្កាត់ស្ត្រី ១២៨នាក់ អាណត្តិទី៤ (ឆ្នាំ២០១៧-ឆ្នាំ២០២២)

**ពណ៌សម្គាល់**

| | | | |
|---|---|---|---|
| (ពណ៌ខៀវខ្ចី) | មេឃុំជាស្ត្រីវ័យក្មេង | (ពណ៌ទឹកក្រូច) | តំបន់ដាច់ស្រយាល |
| (ពណ៌លឿង) | មេឃុំថ្មី ជាស្ត្រីវ័យចំណាស់ | (ពណ៌បៃតង) | ជនជាតិដើមភាគតិច |

| ល.រ | ឈ្មោះ | ឆ្នាំកំណើត | អាយុ | ឃុំ/សង្កាត់ | ក្រុង ស្រុក ខណ្ឌ | រាជធានី ខេត្ត | ឃុំ ដាច់ស្រយាល | ជនជាតិភាគតិច | គណបក្សនយោបាយ | ក្រុមប្រឹក្សាចាស់/ថ្មី |
|---|---|---|---|---|---|---|---|---|---|---|
| ១ | សេង សៅមាន | ១៩៧៤ | ៤៣ឆ្នាំ | អូរប្រាសាទ | មង្គលបូរី | បន្ទាយមានជ័យ | | | សង្គ្រោះជាតិ | ថ្មី |
| ២ | គង់ សុភាព | ១៩៨៤ | ៣៣ឆ្នាំ | រហាត់ទឹក | មង្គលបូរី | បន្ទាយមានជ័យ | | | ប្រជាជនកម្ពុជា | ថ្មី |
| ៣ | ឡាញ់ ថាវី | ១៩៨៩ | ២៨ឆ្នាំ | ឫស្សីក្រោក | មង្គលបូរី | បន្ទាយមានជ័យ | | | សង្គ្រោះជាតិ | ថ្មី |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៤ | គឹម ឡាង | ១៩៧០ | ៤៧ឆ្នាំ | ស្ពានស្រែង | ភ្នំស្រុក | បន្ទាយមានជ័យ | | | ប្រជាជនកម្ពុជា | ថ្មី |
| ៥ | ជ្រូក សុផល | ១៩៦៩ | ៤៨ឆ្នាំ | ស្វាយចេក | ស្វាយចេក | បន្ទាយមានជ័យ | | | ប្រជាជនកម្ពុជា | ចាស់ |
| ៦ | យុន ចន្ទី | ១៩៧៤ | ៤៣ឆ្នាំ | សង្កាត់ផ្សារកណ្ដាល | ក្រុងប៉ោយប៉ែត | បន្ទាយមានជ័យ | | | សង្គ្រោះជាតិ | ថ្មី |
| ៧ | គឹម គឹមអាន | ១៩៧៧ | ៤០ឆ្នាំ | ស្ទឹង | បាណន់ | បាត់ដំបង | | | សង្គ្រោះជាតិ | ថ្មី |
| ៨ | ស៊ិន ចាន់ពៅរ៉ូហ្សែត | ១៩៨៥ | ៣២ឆ្នាំ | សង្កាត់អូរចារ | ក្រុងបាត់ដំបង | បាត់ដំបង | | | សង្គ្រោះជាតិ | ថ្មី |
| ៩ | នី រំដួល | ១៩៨៧ | ៣០ឆ្នាំ | ព្រែកហ្លួង | ឯកភ្នំ | បាត់ដំបង | | | សង្គ្រោះជាតិ | ថ្មី |
| ១០ | លឿម អៀប | ១៩៧២ | ៤៥ឆ្នាំ | មោង | មោងឫស្សី | បាត់ដំបង | | | សង្គ្រោះជាតិ | ថ្មី |
| ១១ | សេង រត្នមុនី | ១៩៧២ | ៤៥ឆ្នាំ | ជ្រៃ | មោងឫស្សី | បាត់ដំបង | | | សង្គ្រោះជាតិ | ថ្មី |
| ១២ | សឿម យាប់ | ១៩៦៣ | ៥៤ឆ្នាំ | តាប៉ុន | សង្កែ | បាត់ដំបង | | | ប្រជាជនកម្ពុជា | ថ្មី |
| ១៣ | ស៊ឹម ពៅ | ១៩៦២ | ៥៥ឆ្នាំ | វត្ត | សង្កែ | បាត់ដំបង | | | ប្រជាជនកម្ពុជា | ចាស់ |
| ១៤ | គឹម លី | ១៩៥១ | ៦៦ឆ្នាំ | តាតោក | សំឡូត | បាត់ដំបង | | | ប្រជាជនកម្ពុជា | ចាស់ |
| ១៥ | យុន ភន | ១៩៥២ | ៦៥ឆ្នាំ | តាស្តា | សំពៅលូន | បាត់ដំបង | | | ប្រជាជនកម្ពុជា | ថ្មី |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ១៦ | ប៉ុល ហាក់ | ១៩៥២ | ៦៥ឆ្នាំ | ជ្រៃសីមា | សំពៅលូន | បាត់ដំបង | | | សង្គ្រោះជាតិ | ថ្មី |
| ១៧ | ជួន សុផល | ១៩៥៨ | ៥៩ឆ្នាំ | តាសែន | កំរៀង | បាត់ដំបង | | | ប្រជាជនកម្ពុជា | ថ្មី |
| ១៨ | ស៊ឹង ចាន់ធូ | ១៩៧០ | ៤៧ឆ្នាំ | តាក្រី | កំរៀង | បាត់ដំបង | | | សង្គ្រោះជាតិ | ថ្មី |
| ១៩ | មៃ ចាន់ណេត | ១៩៨០ | ៣៧ឆ្នាំ | សំបូរ | បាធាយ | កំពង់ចាម | | | សង្គ្រោះជាតិ | ថ្មី |
| ២០ | ថាយ អ៊ន់ | ១៩៥៧ | ៦០ឆ្នាំ | អរអាង | កំពង់សៀម | កំពង់ចាម | | | សង្គ្រោះជាតិ | ថ្មី |
| ២១ | ស្រេង សុឃឿន | ១៩៧៥ | ៤២ឆ្នាំ | ស្រក | កំពង់សៀម | កំពង់ចាម | | | សង្គ្រោះជាតិ | ថ្មី |
| ២២ | ស៊ិន ចន្ថា | ១៩៥០ | ៦៧ឆ្នាំ | កំពង់រាប | កោះសូទិន | កំពង់ចាម | | | ប្រជាជនកម្ពុជា | ថ្មី |
| ២៣ | ទ្រី ណៃយ៉េង | ១៩៥៤ | ៦៣ឆ្នាំ | មហាលាភ | កោះសូទិន | កំពង់ចាម | | | សង្គ្រោះជាតិ | ថ្មី |
| ២៤ | ខាន់ ផល្លា | ១៩៥៨ | ៥៩ឆ្នាំ | មហាខ្ញូង | កោះសូទិន | កំពង់ចាម | | | សង្គ្រោះជាតិ | ថ្មី |
| ២៥ | បាវ ស៊ីមអ៊ន់ | ១៩៦២ | ៥៥ឆ្នាំ | ព្រែករំដេង | ស្រីសន្ធរ | កំពង់ចាម | | | សង្គ្រោះជាតិ | ថ្មី |
| ២៦ | សួន សាមាន | ១៩៦១ | ៥៦ឆ្នាំ | ត្រពាំងចាន់ | បរិបូណ៌ | កំពង់ឆ្នាំង | | | សង្គ្រោះជាតិ | ចាស់ |
| ២៧ | ភួន ឈុយអេង | ១៩៤៣ | ៧៤ឆ្នាំ | សង្កាត់ផ្សារឆ្នាំង | ក្រុងកំពង់ឆ្នាំង | កំពង់ឆ្នាំង | | | ប្រជាជនកម្ពុជា | ចាស់ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ២៨ | កែវ សុជាត | ១៩៥៧ | ៦០ឆ្នាំ | សង្កាត់កំពង់ឆ្នាំង | ក្រុងកំពង់ឆ្នាំង | កំពង់ឆ្នាំង | | | ប្រជាជនកម្ពុជា | ចាស់ |
| ២៩ | ឌុច មុលី | ១៩៦៩ | ៤៨ឆ្នាំ | សង្កាត់ប្អេរ | ក្រុងកំពង់ឆ្នាំង | កំពង់ឆ្នាំង | | | ប្រជាជនកម្ពុជា | ថ្មី |
| ៣០ | គុយ ចន្ធី | ១៩៦០ | ៥៧ឆ្នាំ | កំពង់ហៅ | កំពង់លែង | កំពង់ឆ្នាំង | | | ប្រជាជនកម្ពុជា | ថ្មី |
| ៣១ | ទេព យ៉ារ៉េម | ១៩៥៨ | ៥៩ឆ្នាំ | ពានី | កំពង់ត្រឡាច | កំពង់ឆ្នាំង | | | ប្រជាជនកម្ពុជា | ថ្មី |
| ៣២ | ខៀវ សុគឿន | ១៩៦២ | ៥៥ឆ្នាំ | ប្រស្និង | រលាប្អៀរ | កំពង់ឆ្នាំង | ✓ | | ប្រជាជនកម្ពុជា | ចាស់ |
| ៣៣ | ថោង ហុង | ១៩៤៦ | ៧១ឆ្នាំ | ព្រៃមូល | រលាប្អៀរ | កំពង់ឆ្នាំង | | | ប្រជាជនកម្ពុជា | ថ្មី |
| ៣៤ | ប៉ែន សោភា | ១៩៨០ | ៣៧ឆ្នាំ | ស្វាយជុក | សាមគ្គីមានជ័យ | កំពង់ឆ្នាំង | ✓ | | ប្រជាជនកម្ពុជា | ចាស់ |
| ៣៥ | ហែម គៀន | ១៩៥៨ | ៥៩ឆ្នាំ | ជៀប | ទឹកផុស | កំពង់ឆ្នាំង | | | ប្រជាជនកម្ពុជា | ថ្មី |
| ៣៦ | ស៊ឹម រ៉ុន | ១៩៦៥ | ៥២ឆ្នាំ | ក្បាលទឹក | ទឹកផុស | កំពង់ឆ្នាំង | | | ប្រជាជនកម្ពុជា | ថ្មី |
| ៣៧ | ភឿក ហឹង | ១៩៦៦ | ៥១ឆ្នាំ | ខ្លុងពពក | ទឹកផុស | កំពង់ឆ្នាំង | | | ប្រជាជនកម្ពុជា | ចាស់ |
| ៣៨ | កែវ យ៉ាន | ១៩៧៨ | ៣៩ឆ្នាំ | ក្រាំងស្គារ | ទឹកផុស | កំពង់ឆ្នាំង | | | ប្រជាជនកម្ពុជា | ថ្មី |
| ៣៩ | កែវ ពិសី | ១៩៧៦ | ៤១ឆ្នាំ | កក់ | បរសេដ្ឋ | កំពង់ស្ពឺ | | | ប្រជាជនកម្ពុជា | ថ្មី |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៤០ | ផៃ សុភាព | ១៩៦២ | ៥៥ឆ្នាំ | ហោងសំណំ | ឱរ៉ាល់ | កំពង់ស្ពឺ | | | ប្រជាជនកម្ពុជា | ថ្មី |
| ៤១ | តាំង គីមចេង | ១៩៥៩ | ៥៨ឆ្នាំ | អូរ | ភ្នំស្រួច | កំពង់ស្ពឺ | | | ប្រជាជនកម្ពុជា | ចាស់ |
| ៤២ | គឹម តុលា | ១៩៨៩ | ៣១ឆ្នាំ | ត្រែងត្រយឹង | ភ្នំស្រួច | កំពង់ស្ពឺ | | | សង្គ្រោះជាតិ | ថ្មី |
| ៤៣ | ព្រំ នី | ១៩៧០ | ៤៧ឆ្នាំ | កាហែង | សំរោងទង | កំពង់ស្ពឺ | | | ប្រជាជនកម្ពុជា | ថ្មី |
| ៤៤ | អ៊ឹម សុខជា | ១៩៦៣ | ៥៤ឆ្នាំ | ក្រវ៉ា | បារាយណ៍ | កំពង់ធំ | | | សង្គ្រោះជាតិ | ថ្មី |
| ៤៥ | សេង ចាន់ថូ | ១៩៧០ | ៤៧ឆ្នាំ | ទ្រៀល | បារាយណ៍ | កំពង់ធំ | | | សង្គ្រោះជាតិ | ថ្មី |
| ៤៦ | យឹង ហ៊ាប | ១៩៦៤ | ៥៣ឆ្នាំ | ដំរីស្លាប់ | កំពង់ស្វាយ | កំពង់ធំ | | | ប្រជាជនកម្ពុជា | ថ្មី |
| ៤៧ | ប៉ាច នាម | ១៩៥៣ | ៦៤ឆ្នាំ | តាំងក្រសៅ | ប្រាសាទសំបូរ | កំពង់ធំ | | | សង្គ្រោះជាតិ | ថ្មី |
| ៤៨ | រុន សួ | ១៩៥៣ | ៦៤ឆ្នាំ | កំពង់ចិនជើង | ស្ទោង | កំពង់ធំ | | | សង្គ្រោះជាតិ | ថ្មី |
| ៤៩ | ប៉ែន សុភណ្ណារី | ១៩៧២ | ៤៥ឆ្នាំ | ទូកមាសខាងលិច | បន្ទាយមាស | កំពត | | | ប្រជាជនកម្ពុជា | ចាស់ |
| ៥០ | លឹម លុយ | ១៩៥០ | ៦៧ឆ្នាំ | កំពង់ត្រាចខាងកើត | កំពង់ត្រាច | កំពត | | | ប្រជាជនកម្ពុជា | ថ្មី |
| ៥១ | កាំង ហ៊ីវ | ១៩៨៨ | ២៩ឆ្នាំ | ឫស្សីស្រុកខាងកើត | កំពង់ត្រាច | កំពត | | | ប្រជាជនកម្ពុជា | ថ្មី |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៥២ | យន សុម៉ាលី | ១៩៨២ | ៣៥ឆ្នាំ | កំពង់ក្រែង | ទឹកឈូ | កំពត | | | ប្រជាជនកម្ពុជា | ចាស់ |
| ៥៣ | សេង សុភីន | ១៩៥៥ | ៦២ឆ្នាំ | ត្រពាំងធំ | ទឹកឈូ | កំពត | | | ប្រជាជនកម្ពុជា | ថ្មី |
| ៥៤ | រឿង សុភាព | ១៩៤៥ | ៧២ឆ្នាំ | បារគូ | កណ្តាលស្ទឹង | កណ្តាល | | | ប្រជាជនកម្ពុជា | ថ្មី |
| ៥៥ | បូ សំអាត | ១៩៤៩ | ៦៨ឆ្នាំ | ថ្មី | កណ្តាលស្ទឹង | កណ្តាល | | | ប្រជាជនកម្ពុជា | ថ្មី |
| ៥៦ | លឹម សុឃឿន | ១៩៦០ | ៥៧ឆ្នាំ | សៀមរាប | កណ្តាលស្ទឹង | កណ្តាល | | | ប្រជាជនកម្ពុជា | ថ្មី |
| ៥៧ | យ៉ា សារឿន | ១៩៥៦ | ៦១ឆ្នាំ | ត្រពាំងវែង | កណ្តាលស្ទឹង | កណ្តាល | | | ប្រជាជនកម្ពុជា | ចាស់ |
| ៥៨ | តន់ ស៊ុនណារី | ១៩៧០ | ៤៧ឆ្នាំ | ទ្រា | កណ្តាលស្ទឹង | កណ្តាល | | | ប្រជាជនកម្ពុជា | ថ្មី |
| ៥៩ | ប៊ុន សុគាំ | ១៩៦០ | ៥៧ឆ្នាំ | ជ័យធំ | ខ្សាច់កណ្តាល | កណ្តាល | | | ប្រជាជនកម្ពុជា | ថ្មី |
| ៦០ | ជុង ឈុននី | ១៩៥៩ | ៥៨ឆ្នាំ | ព្រះប្រសព្វ | ខ្សាច់កណ្តាល | កណ្តាល | | | សង្គ្រោះជាតិ | ថ្មី |
| ៦១ | ទូច សារ៉ុជ | ១៩៥៩ | ៥៨ឆ្នាំ | អរិយក្សត្រ | ល្វាឯម | កណ្តាល | | | សង្គ្រោះជាតិ | ថ្មី |
| ៦២ | ហួន ម៉ើ | ១៩៥៧ | ៦០ឆ្នាំ | កោះកែវ | ល្វាឯម | កណ្តាល | | | ប្រជាជនកម្ពុជា | ចាស់ |
| ៦៣ | យុន សុខេម | ១៩៦៩ | ៤៨ឆ្នាំ | ព្រែកដំបង | មុខកំពូល | កណ្តាល | | | ប្រជាជនកម្ពុជា | ចាស់ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៦៤ | ជួន ស្រីពៅ | ១៩៧២ | ៤៥ឆ្នាំ | ស្វាយអំពារ | មុខកំពូល | កណ្តាល | ✓ | | ប្រជាជនកម្ពុជា | ចាស់ |
| ៦៥ | ស៊ឹម ណាង | ១៩៥៨ | ៥៩ឆ្នាំ | ឆក់ឈើនាង | អង្គស្នួល | កណ្តាល | | | ប្រជាជនកម្ពុជា | ចាស់ |
| ៦៦ | ស៊ុំ កល្យាណ | ១៩៦៥ | ៥២ឆ្នាំ | ដំណាក់អំពិល | អង្គស្នួល | កណ្តាល | | | ប្រជាជនកម្ពុជា | ចាស់ |
| ៦៧ | ហេង មួប់ | ១៩៥៩ | ៥៨ឆ្នាំ | កំពង់ហ្លួង | ពញាឮ | កណ្តាល | | | ប្រជាជនកម្ពុជា | ចាស់ |
| ៦៨ | កង ឡាយ | ១៩៦៩ | ៤៨ឆ្នាំ | ត្រពាំងរូង | កោះកុង | កោះកុង | | | ប្រជាជនកម្ពុជា | ថ្មី |
| ៦៩ | នាង គុន | ១៩៦៥ | ៥២ឆ្នាំ | ពាមក្រសោប | មណ្ឌលសីមា | កោះកុង | | | ប្រជាជនកម្ពុជា | ថ្មី |
| ៧០ | គឹម សុខេម | ១៩៥៧ | ៦០ឆ្នាំ | ទួលគគីរ | មណ្ឌលសីមា | កោះកុង | | | ប្រជាជនកម្ពុជា | ថ្មី |
| ៧១ | ដួង លឹមហ៊ាង | ១៩៧៩ | ៣៨ឆ្នាំ | ដំរីផុង | ឆ្លូង | ក្រចេះ | | | ប្រជាជនកម្ពុជា | ថ្មី |
| ៧២ | គា ប៉ុណ្ណារី | ១៩៦៦ | ៥១ឆ្នាំ | កញ្ជរ | ឆ្លូង | ក្រចេះ | | | ប្រជាជនកម្ពុជា | ថ្មី |
| ៧៣ | ពេញ ពៅ | ១៩៦០ | ៥៧ឆ្នាំ | ចង្រ្កង់ | ចិត្របុរី | ក្រចេះ | | | ប្រជាជនកម្ពុជា | ថ្មី |
| ៧៤ | ឡាយ ជុនអេង | ១៩៥២ | ៦៥ឆ្នាំ | សំបូរ | សំបូរ | ក្រចេះ | | | សង្គ្រោះជាតិ | ថ្មី |
| ៧៥ | ថ្លាង ណារ៉េត | ១៩៥៩ | ៥៨ឆ្នាំ | ឃ្សឹម | ស្នួល | ក្រចេះ | | | ប្រជាជនកម្ពុជា | ថ្មី |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៧៦ | ខឿន ណារឿន | ១៩៧៦ | ៤១ឆ្នាំ | ស្រែសង្គម | កោះញែក | មណ្ឌលគិរី | | | ប្រជាជនកម្ពុជា | ថ្មី |
| ៧៧ | ថ្វាន់ ត្រែល | ១៩៧២ | ៤៥ឆ្នាំ | សែនមនោរម្យ | អូររាំង | មណ្ឌលគិរី | | | ប្រជាជនកម្ពុជា | ថ្មី |
| ៧៨ | ម៉ន ចាន់ធី | ១៩៧៣ | ៤៤ឆ្នាំ | ក្រង់តេះ | ពេជ្រាដា | មណ្ឌលគិរី | | | ប្រជាជនកម្ពុជា | ថ្មី |
| ៧៩ | ប្រាក់ ម៉ាលី | ១៩៥៥ | ៦២ឆ្នាំ | បឹងកេងកងទី១ | ចំការមន | រាជធានីភ្នំពេញ | | | ប្រជាជនកម្ពុជា | ចាស់ |
| ៨០ | ស៊ី គួន | ១៩៥០ | ៦៧ឆ្នាំ | ផ្សារថ្មីទី១ | ដូនពេញ | រាជធានីភ្នំពេញ | | | ប្រជាជនកម្ពុជា | ចាស់ |
| ៨១ | ទៀង ស៊ីឡេង | ១៩៥៤ | ៦៣ឆ្នាំ | បឹងរាំង | ដូនពេញ | រាជធានីភ្នំពេញ | | | ប្រជាជនកម្ពុជា | ថ្មី |
| ៨២ | ប៉ែន អ៊ិន | ១៩៥៤ | ៦៣ឆ្នាំ | ផ្សារកណ្តាលទី២ | ដូនពេញ | រាជធានីភ្នំពេញ | | | ប្រជាជនកម្ពុជា | ថ្មី |
| ៨៣ | ខឹម មុន្នា | ១៩៥៩ | ៥៨ឆ្នាំ | ស្រះចក | ដូនពេញ | រាជធានីភ្នំពេញ | | | សង្គ្រោះជាតិ | ថ្មី |
| ៨៤ | ឡុង ផល្លី | ១៩៥៣ | ៦៤ឆ្នាំ | មិត្តភាព | ៧ មករា | រាជធានីភ្នំពេញ | | | ប្រជាជនកម្ពុជា | ចាស់ |
| ៨៥ | តៅ មន្នា | ១៩៥៥ | ៦២ឆ្នាំ | បឹងព្រលឹត | ៧ មករា | រាជធានីភ្នំពេញ | | | ប្រជាជនកម្ពុជា | ចាស់ |
| ៨៦ | ពៅ សាម៉ោច | ១៩៤៩ | ៦៨ឆ្នាំ | ផ្សារដេប៉ូទី១ | ទួលគោក | រាជធានីភ្នំពេញ | | | ប្រជាជនកម្ពុជា | ថ្មី |
| ៨៧ | សេង សុខន | ១៩៥១ | ៦៦ឆ្នាំ | ផ្សារដេប៉ូទី២ | ទួលគោក | រាជធានីភ្នំពេញ | | | សង្គ្រោះជាតិ | ថ្មី |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៨៨ | ហ៊ឹម សុខជា | ១៩៦៦ | ៥១ឆ្នាំ | ទឹកល្អក់ទី២ | ទួលគោក | រាជធានីភ្នំពេញ | | | សង្គ្រោះជាតិ | ថ្មី |
| ៨៩ | ទិត្យ សំអុន | ១៩៥០ | ៦៧ឆ្នាំ | សាក់សំពៅ | ដង្កោ | រាជធានីភ្នំពេញ | | | ប្រជាជនកម្ពុជា | ចាស់ |
| ៩០ | ជុំ សារ៉ុម | ១៩៥៤ | ៦៣ឆ្នាំ | ស្វាយប៉ាក | ឫស្សីកែវ | រាជធានីភ្នំពេញ | | | សង្គ្រោះជាតិ | ថ្មី |
| ៩១ | ច័ន្ទ សំណាង | ១៩៥៦ | ៦១ឆ្នាំ | ឫស្សីកែវ | ឫស្សីកែវ | រាជធានីភ្នំពេញ | | | សង្គ្រោះជាតិ | ថ្មី |
| ៩២ | សោម សុខុម | ១៩៧០ | ៤៧ឆ្នាំ | ចំរើន | សង្គមថ្មី | ព្រះវិហារ | | | ប្រជាជនកម្ពុជា | ចាស់ |
| ៩៣ | ម៉ុង សំអាន | ១៩៥៤ | ៦៣ឆ្នាំ | សង្កាត់បាលហាល | ក្រុងព្រះវិហា | ព្រះវិហារ | | | ប្រជាជនកម្ពុជា | ចាស់ |
| ៩៤ | ហេង ស្រីពៅ | ១៩៧០ | ៤៧ឆ្នាំ | កន្សោមអក | កំពង់ត្របែក | ព្រៃវែង | | | ប្រជាជនកម្ពុជា | ថ្មី |
| ៩៥ | នូ សាមួន | ១៩៧២ | ៤៥ឆ្នាំ | បន្ទាយចក្រី | ព្រះស្តេច | ព្រៃវែង | ✓ | | ប្រជាជនកម្ពុជា | ថ្មី |
| ៩៦ | កែវ សុង | ១៩៥៣ | ៦៤ឆ្នាំ | អំពិលក្រៅ | ស៊ីធរកណ្តាល | ព្រៃវែង | | | សង្គ្រោះជាតិ | ថ្មី |
| ៩៧ | នួន សុភី | ១៩៦៩ | ៤៨ឆ្នាំ | សង្កាត់ស្វាយអាត់ | ក្រុងពោធិសាត់ | ពោធិសាត់ | | | ប្រជាជនកម្ពុជា | ថ្មី |
| ៩៨ | សេក សំអាត | ១៩៥៣ | ៦៤ឆ្នាំ | ប្រម៉ោយ | វាលវែង | ពោធិសាត់ | ✓ | | ប្រជាជនកម្ពុជា | ចាស់ |
| ៩៩ | ខាញ់ ស៊ូរី | ១៩៧៧ | ៤០ឆ្នាំ | អូរជុំ | អូរជុំ | រតនគិរី | | ✓ | ប្រជាជនកម្ពុជា | ចាស់ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ១០០ | គ្រួន ចន្ទ្រា | ១៩៨៧ | ៣០ឆ្នាំ | ល្អក់ | អូរជុំ | រតនគិរី | | | ប្រជាជនកម្ពុជា | ថ្មី |
| ១០១ | លិវ សុខប | ១៩៥៦ | ៦១ឆ្នាំ | ចារឈូក | អង្គរជុំ | សៀមរាប | | | ប្រជាជនកម្ពុជា | ថ្មី |
| ១០២ | ម៉ាន់ ចំប៉ា | ១៩៨១ | ៣៦ឆ្នាំ | លាងដៃ | អង្គរជុំ | សៀមរាប | | | សង្គ្រោះជាតិ | ថ្មី |
| ១០៣ | លេម ហ៊ាង | ១៩៧៧ | ៤០ឆ្នាំ | មុខប៉ែន | ពួក | សៀមរាប | | | ប្រជាជនកម្ពុជា | ថ្មី |
| ១០៤ | ធិម សុគន្ធី | ១៩៧៨ | ៣៩ឆ្នាំ | ព្រៃជ្រូក | ពួក | សៀមរាប | | | ប្រជាជនកម្ពុជា | ថ្មី |
| ១០៥ | ឌុច ម៉ាលីន | ១៩៦១ | ៥៦ឆ្នាំ | យាង | ពួក | សៀមរាប | | | ប្រជាជនកម្ពុជា | ចាស់ |
| ១០៦ | យឹម ផល្លី | ១៩៧២ | ៤៥ឆ្នាំ | សង្កាត់គោកចក | ក្រុងសៀមរាប | សៀមរាប | | | សង្គ្រោះជាតិ | ថ្មី |
| ១០៧ | លឹម ម៉ាក់យូរី | ១៩៥៥ | ៦២ឆ្នាំ | សង្កាត់សៀមរាប | ក្រុងសៀមរាប | សៀមរាប | | | សង្គ្រោះជាតិ | ថ្មី |
| ១០៨ | ឈាវ សាក់ | ១៩៧២ | ៤៥ឆ្នាំ | ពពេល | សូត្រនិគម | សៀមរាប | | | សង្គ្រោះជាតិ | ថ្មី |
| ១០៩ | ខាវ ខាំអន | ១៩៥៦ | ៦១ឆ្នាំ | សាមឃួយ | សេសាន | ស្ទឹងត្រែង | | ✓ | ប្រជាជនកម្ពុជា | ចាស់ |
| ១១០ | ជា ណាម | ១៩៥៨ | ៥៩ឆ្នាំ | កោះស្រឡាយ | សៀមបូក | ស្ទឹងត្រែង | ✓ | | ប្រជាជនកម្ពុជា | ចាស់ |
| ១១១ | ចាន់ សុផល | ១៩៥៥ | ៦២ឆ្នាំ | អូររម្រះ | សៀមបូក | ស្ទឹងត្រែង | ✓ | | ប្រជាជនកម្ពុជា | ចាស់ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ១១២ | គឹម សាន់ | ១៩៥៥ | ៦២ឆ្នាំ | អូរឬស្សីកណ្តាល | សៀមបូក | ស្ទឹងត្រែង | ✓ | | ប្រជាជនកម្ពុជា | ចាស់ |
| ១១៣ | ហែម សាវី | ១៩៥០ | ៦៧ឆ្នាំ | អូររៃ | ថាឡាបរិវ៉ាត់ | ស្ទឹងត្រែង | | | ប្រជាជនកម្ពុជា | ចាស់ |
| ១១៤ | សំ កញ្ញា | ១៩៨១ | ៣៦ឆ្នាំ | បន្ទាយក្រាំង | កំពង់រោទិ៍ | ស្វាយរៀង | | | ប្រជាជនកម្ពុជា | ថ្មី |
| ១១៥ | គឹម ស៊ុនណារី | ១៩៥២ | ៦៥ឆ្នាំ | អណ្តូងពោធិ៍ | រំដួល | ស្វាយរៀង | | | ប្រជាជនកម្ពុជា | ចាស់ |
| ១១៦ | គឹម សំអឿន | ១៩៦៤ | ៥៣ឆ្នាំ | គគីរ | រំដួល | ស្វាយរៀង | | | ប្រជាជនកម្ពុជា | ថ្មី |
| ១១៧ | អ៊ុយ ស៊ន់ | ១៩៧៥ | ៤២ឆ្នាំ | ចំបក់ | ស្វាយជ្រុំ | ស្វាយរៀង | | | ប្រជាជនកម្ពុជា | ថ្មី |
| ១១៨ | ជា ស៊ីម | ១៩៥៦ | ៦១ឆ្នាំ | ដូនស | ស្វាយជ្រុំ | ស្វាយរៀង | | | ប្រជាជនកម្ពុជា | ចាស់ |
| ១១៩ | មាស យុន | ១៩៥៧ | ៦០ឆ្នាំ | គោកព្រីង | ស្វាយជ្រុំ | ស្វាយរៀង | | | សង្គ្រោះជាតិ | ថ្មី |
| ១២០ | សុក ណន | ១៩៥២ | ៦៥ឆ្នាំ | សង្កាត់សង្ឃ័រ | ក្រុងស្វាយរៀង | ស្វាយរៀង | | | ប្រជាជនកម្ពុជា | ថ្មី |
| ១២១ | កែវ សុជាត | ១៩៥២ | ៦៥ឆ្នាំ | កំពែង | គិរីវង់ | តាកែវ | | | ប្រជាជនកម្ពុជា | ថ្មី |
| ១២២ | ទន់ ស៊ីម៉េន | ១៩៥៦ | ៦១ឆ្នាំ | សង្កាត់ទួលល្វា | ក្រុងប៉ៃលិន | ប៉ៃលិន | | | ប្រជាជនកម្ពុជា | ថ្មី |
| ១២៣ | សេក សុភី | ១៩៥៩ | ៥៨ឆ្នាំ | អូរអណ្តូង | សាលាក្រៅ | ប៉ៃលិន | | | ប្រជាជនកម្ពុជា | ថ្មី |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ១២៤ | ច្រឹក ពេជ្រណេង | ១៩៥៨ | ៥៩ឆ្នាំ | ផ្កាវ | ត្រពាំងប្រាសាទ | ឧត្តរមានជ័យ | ✓ | | ប្រជាជនកម្ពុជា | ចាស់ |
| ១២៥ | សុខ ណារិទ្ធ | ១៩៨៤ | ៣៣ឆ្នាំ | ចេក | មេមត់ | ត្បូងឃ្មុំ | | | ប្រជាជនកម្ពុជា | ថ្មី |
| ១២៦ | ទ្រី ទាង | ១៩៦១ | ៥៦ឆ្នាំ | បឹងព្រួល | ត្បូងឃ្មុំ | ត្បូងឃ្មុំ | | | ប្រជាជនកម្ពុជា | ចាស់ |
| ១២៧ | គូវ សារ៉ន | ១៩៦១ | ៥៦ឆ្នាំ | គរ | ត្បូងឃ្មុំ | ត្បូងឃ្មុំ | | | ប្រជាជនកម្ពុជា | ថ្មី |
| ១២៨ | ដួង សុផាន | ១៩៥៥ | ៦២ឆ្នាំ | ល្វៀង | ត្បូងឃ្មុំ | ត្បូងឃ្មុំ | | | ប្រជាជនកម្ពុជា | ចាស់ |

# Appendix 5

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**អគ្គលេខាធិការដ្ឋាន**
**លេខ ១៣០ គ.ជ.ប/អគ្គ/ប្រ.ក.៣**

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០១៧

**ចំនួនអ្នកសង្កេតការណ៍ជាតិ ចូលរួមសង្កេតមើលដំណើរការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧**

ចំនួនអ្នកសង្កេតការណ៍ជាតិ ចូលរួមសង្កេតមើលដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ មានដូចខាងក្រោម ៖

| ល.រ | អង្គការ | ចំនួនអ្នកសង្កេតការណ៍ | | |
|---|---|---|---|---|
| | | សរុប | ស្រី | ចល័ត |
| ១ | សហភាពសហព័ន្ធយុវជនកម្ពុជា (UYFC) | ៣១,៤៣១ | ៩,២៩៣ | ០ |
| ២ | សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ (CWPD) | ២០,៧៩៣ | ២០,៧១៧ | ១០ |
| ៣ | គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL) | ១៤,៥៨០ | ៦,១៥៣ | ១០ |
| ៤ | សហព័ន្ធនិស្សិត បញ្ញវ័ន្ត ប្រជាធិបតេយ្យកម្ពុជា (CDSIF) | ២,៦៤២ | ១,៤០៧ | ១០ |
| ៥ | អង្គការតម្លាភាពកម្ពុជា (TIC) | ១,២៣៩ | ៥៦០ | ១០ |
| ៦ | គណៈកម្មាធិការអព្យាក្រឹត និងយុត្តិធម៌ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា(NICFEC) | ១,០៥២ | ៤១១ | ១០ |
| ៧ | គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (NGO-CEDAW) | ៥៦៧ | ៣០៤ | ១០ |
| ៨ | សមាគមរួមគ្នាដើម្បីអភិវឌ្ឍន៍កម្ពុជា (CCDA) | ៤៣៨ | ១៩ | ០ |
| ៩ | សមាគមយុវជនកិច្ចការសង្គម | ៤០៧ | ១៤៥ | ០ |
| ១០ | សហគមន៍អភិវឌ្ឍន៍ជាតិ(UND) | ២៦៥ | ៤៥ | ៣ |
| ១១ | មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព (ភីឌីភី), (PDP-Center) | ២២៨ | ១០៧ | ១០ |
| ១២ | អង្គការប្រជាធិបតេយ្យ និងសិទ្ធិមនុស្សក្នុងប្រតិបត្តិការ(DHRAC) | ២០១ | ១០៤ | ៨ |
| ១៣ | សមាគមសិទ្ធិមនុស្សដើម្បីអភិវឌ្ឍន៍ និងថែរក្សាកុមារកំព្រាស្ត្រីក្រីក្រ(CO.P.A) | ១៦២ | ៤៥ | ៧ |
| ១៤ | អង្គការជនពិការកម្ពុជា (C.D.P.O) | ១៤១ | ៦១ | ០ |
| ១៥ | អង្គការសេវាប្រជាធិបតេយ្យ(D.S.O) | ១៣៤ | ៤៨ | ៦ |
| ១៦ | សមាគមយុវជនសេដ្ឋកិច្ចកម្ពុជា (ស.យ.ស.ក) | ១១៩ | ៥១ | ០ |
| ១៧ | សមាគម បញ្ញវ័ន្ត និងយុវជនស្ម័គ្រចិត្ត (VIYA) | ៦៤ | ២៧ | ១០ |
| ១៨ | សហព័ន្ធសិទ្ធិមនុស្ស និងអភិវឌ្ឍន៍កម្ពុជា(C.FHRAD) | ៦០ | ៣០ | ០ |
| ១៩ | សមាគមអ្នកលក់ឱសថកម្ពុជា (C.P.A) | ៦០ | ២៦ | ០ |
| ២០ | វិទ្យាស្ថានអភិវឌ្ឍន៍ធនធានមនុស្ស, Institute of Human Resources Development (Non-Governmental Organization) | ៥០ | ២ | ០ |
| ២១ | សមាគម សិស្ស និស្សិត បញ្ញវ័ន្តក្មេងវត្ត (PCISA) | ៣៨ | ០ | ០ |
| **សរុប** | | **៧៤,៦៧១** | **៣៩,៥៥៥** | **១០៤** |

សមទំនាក់ទំនង : 023 214 231 / 012 855 018 ; E-mail: necinfo@forum.org.kh ; Website: www.necelect.org.kh

# Appendix 6

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
អគ្គលេខាធិការដ្ឋាន
លេខ ១៣២ គ.ជ.ប/អគ្គ/រប.ក.៣

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០១៧

**ចំនួនអ្នកសង្កេតការណ៍អន្តរជាតិ ចូលរួមសង្កេតមើលដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧**

ចំនួនអ្នកសង្កេតការណ៍អន្តរជាតិ ចូលរួមសង្កេតមើលដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤ ឆ្នាំ២០១៧ មានដូចខាងក្រោម ៖

| ល.រ | អង្គការ | ចំនួនអ្នកសង្កេតការណ៍ | |
|---|---|---|---|
| | | សរុប | ស្រី |
| 1 | Embassy of United States of America in Phnom Penh | 98 | 28 |
| 2 | Asian Network for free elections (ANFREL) | 51 | 14 |
| 3 | Australian Embassy in Phnom Penh | 26 | 13 |
| 4 | EU (រួមទាំងអ្នកបកប្រែភាសា ០៣/០១នាក់) | 22 | 9 |
| 5 | Centrist Democrats International (CDI) | 22 | 4 |
| 6 | Internation Conference of Asian Political Parties (ICAPP) | 18 | 6 |
| 7 | National Democratic Institute (NDI) | 17 | 8 |
| 8 | Centrist Asia-Pacific Democrats International (CAPDI) | 16 | 3 |
| 9 | Sweden Embassy in Phnom Penh | 14 | 9 |
| 10 | Japanese Embassy in Phnom Penh | 11 | 4 |
| 11 | Germany Embassy in Phnom Penh | 11 | 4 |
| 12 | People's Republic of China Embassy in Phnom Penh | 9 | 2 |
| 13 | DAN CHURCH AID | 7 | 2 |
| 14 | Swiss Cooperation office and Swiss Consular Agency in Cambodia | 6 | 2 |
| 15 | Inter Band Organization | 6 | 2 |
| 16 | Royal Thai Embassy in Phnom Penh | 6 | 2 |
| 17 | Canada Embassy in Bangkok | 5 | 2 |
| 18 | British Embassy in Phnom Penh | 5 | 1 |
| 19 | The Socialist Republic of Viet Nam Embassy in the Kingdom of Cambodia | 4 | |
| 20 | International For Electoral Systems (IFES) | 4 | 1 |
| 21 | French Embassy in Cambodia | 4 | 1 |
| 22 | The Republic of the Philippines in PP | 3 | 1 |
| 23 | Poland Embassy in Bangkok (លើកទី១&២ ) | 2 | 1 |
| 24 | Indonesian Embassy in Phnom Penh | 2 | 1 |
| 25 | អង្គការ GIZ | 2 | 1 |

សូមទំនាក់ទំនង : 023 214 231 / 012 855 018 ; E-mail: necinfo@forum.org.kh ; Website: www.necelect.org.kh 1

| | | | |
|---|---|---|---|
| 26 | The Democratic Republic of Timor Lester Embassy in Phnom Penh | 2 | |
| 27 | Singapore Embassy in Phnom Penh | 2 | |
| 28 | Brunei Darussalam Embassy in PP | 2 | 1 |
| 29 | Japan International Cooperation Agency in Cambodia (JICA) | 2 | |
| 30 | Belgium Embassy in Bangkok | 1 | 1 |
| 31 | New Zealand Embassy in Bangkok | 1 | 1 |
| 32 | Finland Embassy in Bangkok | 1 | |
| 33 | Malaysia Embassy of Phnom Penh | 1 | |
| 34 | Embassy of Switzerland in Thailand | 1 | |
| | សរុប | 384 | 124 |

សូមទំនាក់ទំនង : 023 214 231 / 012 855 018 ; E-mail: necinfo@forum.org.kh ; Website: www.necelect.org.kh 2

# Appendix 7

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
អគ្គលេខាធិការដ្ឋាន
លេខ ១០៣ គ.ជ.ប/អគ្គ/ប្រ.ក.ព

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៧

**ចំនួនភ្នាក់ងារគណបក្សនយោបាយសម្រាប់ការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧**

គិតត្រឹមថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៧ គណបក្សនយោបាយចំនួន ១២ ដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ ជាផ្លូវការរួចហើយ បានដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ សរុបចំនួន ១០៥,០៧៦ នាក់ ក្នុងនោះមានស្រីចំនួន ២២,៩២៤ នាក់ ដែល គ.ជ.ប បានអនុញ្ញាតដើម្បីចូលរួមសង្កេតមើលដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧។

ចំនួនភ្នាក់ងារគណបក្សនយោបាយនីមួយៗមានដូចខាងក្រោម៖

| ល.រ | ឈ្មោះគណបក្សនយោបាយ | ចំនួនភ្នាក់ងារគណបក្សនយោបាយ | |
|---|---|---|---|
| | | សរុប | ស្រី |
| ១ | គណបក្សប្រជាជនកម្ពុជា | ៤៤,៦១៤ | ៧,៣៦៩ |
| ២ | គណបក្សសង្គ្រោះជាតិ | ៤៣,៥៨៦ | ១០,០៥៤ |
| ៣ | គណបក្ស ហ៊្វុន ស៊ិន ប៉ិច | ៤,៨៨៨ | ១,៨១៩ |
| ៤ | គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ៥,១៦៦ | ១,៣៦៤ |
| ៥ | គណបក្សខ្មែររួបរួមជាតិ | ៥,១៩៨ | ១,៤៧៦ |
| ៦ | គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ | ៨៣៤ | ២១៩ |
| ៧ | គណបក្សសញ្ជាតិកម្ពុជា | ៩ | ៦ |
| ៨ | គណបក្សប្រជាធិបតេយ្យមូលដ្ឋាន | ៣៨៤ | ១០៨ |
| ៩ | គណបក្សយុវជនកម្ពុជា | ៥៦ | ២០ |
| ១០ | គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា | ១០៨ | ១៩ |
| ១១ | គណបក្សអំណាចខ្មែរ | ៩៨ | ៥០ |
| ១២ | គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ | ៦៤ | ១៦ |
| | **សរុបរួម** | ១០៥,០៧៦ | ២២,៩២៤ |

សូមទំនាក់ទំនង : 023 214 231 / 012 855 018 ; E-mail: necinfo@forum.org.kh ; www.necelect.org.kh

# Appendix 8

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## តារាងលទ្ធផលផ្លូវការនៃការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦

| កូដ | រាជធានី ខេត្ត | ចំនួន | | ស្ថិតិប៉ាន់ស្មាន | | ចំនួនឈ្មោះក្នុងបញ្ជីបោះឆ្នោត | | |
|---|---|---|---|---|---|---|---|---|
| | | ឃុំ សង្កាត់ | ការិ.បោះឆ្នោត | សរុបរួម | ១៨ឆ្នាំឡើង | សរុប | ភាគរយ | ស្ត្រី |
| 01 | បន្ទាយមានជ័យ | 65 | 1,019 | 759,920 | 464,927 | 323,956 | 69.68 | 172,589 |
| 02 | បាត់ដំបង | 102 | 1,566 | 1,201,888 | 765,292 | 527,528 | 68.93 | 278,959 |
| 03 | កំពង់ចាម | 109 | 1,555 | 1,136,252 | 707,011 | 541,721 | 76.62 | 292,977 |
| 04 | កំពង់ឆ្នាំង | 70 | 781 | 553,654 | 330,674 | 290,655 | 87.90 | 160,462 |
| 05 | កំពង់ស្ពឺ | 87 | 1,472 | 849,213 | 523,396 | 475,129 | 90.78 | 258,186 |
| 06 | កំពង់ធំ | 81 | 1,053 | 750,885 | 445,563 | 345,228 | 77.48 | 187,651 |
| 07 | កំពត | 93 | 932 | 699,192 | 441,333 | 345,412 | 78.27 | 185,834 |
| 08 | កណ្ដាល | 127 | 1,720 | 1,242,861 | 801,813 | 700,525 | 87.37 | 373,674 |
| 09 | កោះកុង | 29 | 179 | 131,811 | 78,550 | 61,846 | 78.73 | 31,469 |
| 10 | ក្រចេះ | 47 | 501 | 385,059 | 224,548 | 171,520 | 76.38 | 88,046 |
| 11 | មណ្ឌលគិរី | 21 | 122 | 77,959 | 41,195 | 36,797 | 89.32 | 18,022 |
| 12 | រាជធានីភ្នំពេញ | 105 | 2,080 | 1,513,583 | 983,828 | 849,214 | 86.32 | 450,814 |
| 13 | ព្រះវិហារ | 51 | 328 | 223,723 | 131,247 | 115,621 | 88.09 | 59,024 |
| 14 | ព្រៃវែង | 116 | 1,749 | 1,232,975 | 764,836 | 620,995 | 81.19 | 344,575 |
| 15 | ពោធិ៍សាត់ | 49 | 679 | 482,223 | 279,367 | 235,221 | 84.20 | 127,334 |
| 16 | រតនគិរី | 50 | 273 | 182,553 | 96,509 | 87,273 | 90.43 | 42,960 |
| 17 | សៀមរាប | 100 | 1,389 | 1,049,794 | 599,193 | 493,626 | 82.38 | 262,472 |
| 18 | ព្រះសីហនុ | 29 | 280 | 224,977 | 135,787 | 119,362 | 87.90 | 60,810 |
| 19 | ស្ទឹងត្រែង | 34 | 207 | 139,644 | 80,053 | 71,028 | 88.73 | 35,558 |
| 20 | ស្វាយរៀង | 80 | 921 | 626,230 | 390,935 | 328,166 | 83.94 | 180,178 |
| 21 | តាកែវ | 100 | 1,525 | 1,036,721 | 642,059 | 549,599 | 85.60 | 298,311 |
| 22 | កែប | 5 | 63 | 39,250 | 24,776 | 23,050 | 93.03 | 12,028 |
| 23 | ប៉ៃលិន | 8 | 114 | 67,137 | 39,387 | 35,850 | 91.02 | 18,081 |
| 24 | ឧត្តរមានជ័យ | 24 | 361 | 231,858 | 134,314 | 116,643 | 86.84 | 58,265 |
| 25 | ត្បូងឃ្មុំ | 64 | 1,279 | 882,004 | 537,623 | 399,068 | 74.23 | 212,635 |
| សរុប | | 1,646 | 22,148 | 15,721,366 | 9,664,216 | 7,865,033 | 81.38 | 4,210,914 |

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ២០១៧

ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រធាន

ស៊ិក ប៊ុនហុក

# ចំនួនស្ត្រីឈរឈ្មោះបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់កើនឡើងតិចតួច

*ដោយ សុ ជីវី*

*2017-05-11 (RFA)*

ក្រុមអង្គការសង្គមស៊ីវិលធ្វើការងារលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ រកឃើញថា ចំនួនស្ត្រីដែលបានចូលរួមឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៤ នេះមានការកើនឡើងតិចតួច បើប្រៀបធៀបនឹងអាណត្តិទី៣ កន្លងទៅ។

បើទោះបីជាពួកគេសាទរចំពោះការកើនឡើងនេះ ក៏ពួកគេព្រួយបារម្ភថា ចំនួននេះនឹងមិនអាចធ្វើឲ្យចំនួនស្ត្រីដែលអាចក្លាយជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់នោះ អាចកើនឡើងដើម្បីឆ្លើយតបបញ្ហាស្ត្រី និងកុមារនៅមូលដ្ឋានឡើយ។

ក្រុមអង្គការសង្គមស៊ីវិលបារម្ភថា ចំនួនស្ត្រីឋិតក្នុងតួនាទីធ្វើសេចក្ដីសម្រេចនៅថ្នាក់មូលដ្ឋាននៅតែតិច នឹងជំរុញឲ្យការដោះស្រាយបញ្ហាឆ្លើយតបនឹងសេចក្ដីត្រូវការរបស់ស្ត្រីនៅមូលដ្ឋាន នៅតែមានតិចតួច។

អ្នកសម្របសម្រួលផ្នែកអប់រំ និងយេនឌ័រនៃអង្គការខុមហ្វ្រែល (Comfrel) អ្នកស្រី សីនកេត សិរីលក្ខណ៍ ថ្លែងថា ចំនួនស្ត្រីដែលបានឈរឈ្មោះក្នុងបញ្ជីផ្លូវការរបស់ គ.ជ.ប មានចំនួនជាង ២ម៉ឺននាក់ (២៥.៧៨៨នាក់) បានកើនឡើងចំនួន ១,៦២ភាគរយ បើប្រៀបធៀបនឹងចំនួនបេក្ខនារីនៅអាណត្តិទី៣។

ទោះជាយ៉ាងណា អ្នកស្រីថាចំនួនស្ត្រីដែលឈរនៅលេខរៀងទី១ ពោលគឺអ្នកដែលអាចក្លាយជាមេឃុំ ចៅសង្កាត់ មានចំនួនកើនឡើងក្នុងនោះរួមទាំងគណបក្សដែលមានប្រជាប្រិយភាព៖ *«បើសិនជាពួកគាត់ទាំងអស់ហ្នឹងជាប់ឆ្នោតជាមេឃុំ ចឹងចំនួនមេឃុំអាចកើនឡើងច្រើន បើប្រៀបធៀបនឹងអាណត្តិមុនដែលមេឃុំ (ស្រី) មានចំនួន ១០៨នាក់។ ប៉ុន្តែយើងនៅតែឃើញថា ស្ត្រីជួបការប្រឈមមួយចំនួន ដែលភាគច្រើនគណបក្សនយោបាយដែលជាគណបក្សមានប្រជាប្រិយភាព អត់បានខិតខំបង្កើនចំនួនស្ត្រីដូចអ្វីដែលរដ្ឋាភិបាល និងសង្គមស៊ីវិលចង់បានដូចអ្វីដែលរដ្ឋាភិបាលបានទទួលយកនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព»*។

នៅក្នុងបញ្ជីបេក្ខជនចូលរួមបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលផ្សព្វផ្សាយដោយ គ.ជ.ប បង្ហាញថា គណបក្សធំៗចំនួនពីរដែលមានប្រជាប្រិយភាព គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ បាន ដាក់ស្ត្រីឲ្យឈរឈ្មោះបោះឆ្នោតតិចតួចនៅឡើយ បើប្រៀបធៀបនឹងភាគរយស្ត្រីនៅគណបក្សចំនួន ១០ ទៀតដែលចូលរួមប្រកួតប្រជែង។

គណបក្សប្រជាជនកម្ពុជា មានបេក្ខភាពស្ត្រីចំនួន ២២,១៩ភាគរយ រីឯគណបក្សសង្គ្រោះជាតិ ចំនួន ១៦,០៥ ភាគរយ។

ដូចជាគណបក្សហ្វ៊ុនស៊ិនប៉ិច មានស្ត្រី ៣៨,០៦% គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ មានស្ត្រី ៣៣,៤០% គណបក្សខ្មែររួបរួមជាតិ មានស្ត្រី ៤០,១២% គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ មានស្ត្រី ចំនួន ៣៨,៣១% គណបក្សសញ្ជាតិកម្ពុជា មានស្ត្រីចំនួន ៥២,៧៦% គណបក្សជនជាតិដើមប្រជាធិបតេយ្យ កម្ពុជា មានស្ត្រីចំនួន ២១,១១% គណបក្សអំណាចខ្មែរ មានស្ត្រីចំនួន ៣១,១៩% គណបក្សប្រជាធិបតេយ្យ មូលដ្ឋាន មានស្ត្រីចំនួន ២៦,៥២% គណបក្សយុវជនកម្ពុជា មានស្ត្រីចំនួន ៤៧,៦៣% និងគណបក្ស សាធារណរដ្ឋប្រជាធិបតេយ្យ មានស្ត្រី ៤០,៥៧%។

ក្រុមអង្គការសង្គមស៊ីវិលមើលឃើញថា គម្លាតនេះបង្ហាញពីវិសមភាពយេនឌ័រនៅក្នុងការចូលរួមក្នុងវិស័យ នយោបាយ។ ពួកគេក៏បានរកឃើញថា មានបញ្ហាចំនួន ៦ចំណុច ដែលធ្វើឲ្យស្ត្រីពិបាកនឹងចូលទៅកាន់ តំណែងអ្នកដឹកនាំនៅមូលដ្ឋាន ក្នុងនោះរួមមាន ខ្វះក្របខ័ណ្ឌច្បាប់កំណត់ចំនួនស្ត្រីនៅក្នុងបញ្ជីបោះឆ្នោត ការ រើសអើងស្ត្រី ផ្ទៃក្នុងបក្ស ដែលនាំឲ្យមិនដាក់ស្ត្រីនៅលេខរៀងល្អ និងថ្នាក់ដឹកនាំបក្សនៅមិនទាន់មានឆន្ទៈ បង្កើនចំនួនស្ត្រីនៅឡើយ។

បេក្ខជនឈរលេខរៀងទី៣ នៅសង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ មកពីគណបក្សសង្គ្រោះជាតិ កញ្ញា ម៉ៃម វណ្ណណៃត ថ្លែងថា ស្ត្រី ជាពិសេសស្ត្រីវ័យក្មេងដូចកញ្ញា ត្រូវតែស៊ូមតិនៅក្នុងជួរបក្សជាច្រើនលើក ទើបអាច មានការយល់ព្រមក្នុងចំណោមអ្នកដឹកនាំក្នុងបក្ស៖ *«ពេលខ្លះបុរសកន្លែងដែលគាត់ធ្លាប់អង្គុយ គាត់អត់ចង់ឲ្យ យើងអ្នកថ្មីទៅអង្គុយទេ។ អ៊ីចឹងបើយើងអត់ធ្វើការតវ៉ាមតិ យើងអត់បានបង្ហាញពីសកម្មភាពយើង។ យើងអត់ បង្ហាញពីសមត្ថភាពយើង គឺយើងមិនអាចមានឱកាសឈរជាបេក្ខជនបានទេ គឺយើងត្រូវការបង្ហាញសមត្ថភាព ចំណេះដឹង និងពីផលលំបាកនៃស្ត្រីបានគាត់ឲ្យយើងឈរ»*។

ចំពោះបញ្ហានេះ នាយិកាអង្គការសីលការ (SILAKA) និងជាប្រធានគណៈកម្មការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ អ្នកស្រី ធីតា ឃឹះ ក៏បារម្ភដែរថា ចំនួនស្ត្រីតិចតួចនេះនឹងកើតមានបន្តទៀតនៅក្នុងការឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឬការបោះឆ្នោតជាតិ។ អ្នកស្រីថា បើចំនួនស្ត្រីចូលរួមតិចតួចនោះ នឹងរុញច្រានឲ្យរដ្ឋាភិបាលបរាជ័យម្តងទៀតចំពោះគោលដៅជំរុញឲ្យស្ត្រី និងបុរសមានចំនួនស្មើគ្នានៅក្នុងជួរអ្នកដឹកនាំ និងធ្វើសេចក្តីសម្រេចះ *«ពីព្រោះជារឿងមួយសំខាន់ បើអត់មានស្ត្រីចូលរួម គឺវាបាត់សំឡេងស្ត្រី បាត់ព័ត៌មានពីសង្គម។ វាធ្វើឲ្យការសម្រេចចិត្ត និងការអភិវឌ្ឍរបស់យើងវាអត់ប្រសិទ្ធភាព ហើយបើប្រៀបធៀបជាមួយគេទៀត គឺយើងអាចដើរក្រោយគេទៀត។ បើចង់ឲ្យមានមុខមាត់ក្នុងសង្គមនៅក្នុងពិភពលោក គួរចាប់ផ្តើមគិតគូរពីរឿងហ្នឹង»*។

កន្លងទៅ ទាំងគណបក្សកាន់អំណាច និងគណបក្សប្រឆាំង សុទ្ធតែបានអះអាងថា លើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ។ ប៉ុន្តែគណបក្សប្រជាជនកម្ពុជា បញ្ជាក់ថា ការដាក់ចំនួនស្ត្រីរបស់គណបក្សនេះដោយផ្អែកលើប្រជាប្រិយភាព និងសមត្ថភាពរបស់ស្ត្រី ចំណែកគណបក្សប្រឆាំងវិញលើកឡើងថា ពិបាកនឹងរកស្ត្រីដែលក្លាហាន។

យ៉ាងនេះក្តី ក្រុមអង្គការសង្គមស៊ីវិលចាត់ទុកការលើកឡើងនេះ ថាគ្រាន់តែជាលេសរបស់គណបក្សនយោបាយប៉ុណ្ណោះ ហើយបានស្នើនូវអនុសាសន៍មួយចំនួនដែលពួកគេមើលឃើញថា អាចបង្កើនចំនួនស្ត្រី។ ក្នុងនោះរួមមាន ត្រូវវិសោធនកម្មច្បាប់បោះឆ្នោត ដែលអាចតម្រូវឲ្យគណបក្សនយោបាយបង្កើតបញ្ជីមានលេខរៀងឆ្លាស់រវាងបុរស និងស្ត្រី គណបក្សនយោបាយត្រូវមានគោលការណ៍លាយលក្ខណ៍អក្សរពីសមភាពយេនឌ័រ និងបង្កើតបរិយាកាសល្អសម្រាប់ការចូលរួមរបស់ស្ត្រី៕

# ក្រុមស្ត្រីធ្វើការក្នុងវិស័យនយោបាយខកចិត្តនឹងចំនួនបេក្ខជនស្ត្រីឈរឈ្មោះបោះឆ្នោត

ដោយ លោក ហួត វុទ្ធី | ថ្ងៃអង្គារ ទី៩ ខែឧសភា ឆ្នាំ២០១៧ ម៉ោង 5:04 PM (ដោយ VOD)

គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ(គ.ស.ន) បានសំដែងការមិនពេញចិត្តចំពោះចំនួនបេក្ខជនស្ត្រីឈរឈ្មោះបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ ដែលកើនតែជិត២ភាគរយប៉ុណ្ណោះធៀបនឹងអាណត្តិមុន។

ក្នុងសន្និសីទសារព័ត៌មាន ស្តីពី «**លទ្ធផលអង្កេត នៃការដាក់បេក្ខភាពស្ត្រីឈរឈ្មោះក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៤**» ព្រឹកមិញនេះ គ.ស.ន បង្ហាញថា ក្នុងឆ្នាំ២០១៧ បេក្ខភាពស្ត្រីឈរឈ្មោះជាបេក្ខជនបោះឆ្នោតមានចំនួនសរុប ២៥ ៧៨៨នាក់ ស្មើនឹង ២៧,២៦% នៃបេក្ខជនប្រុស-ស្រីសរុប ៩៤ ៥៩៥នាក់ គឺកើនចំនួន១,៦២% ធៀបនឹងឆ្នាំ២០១២ ដែលមានចំនួនតែ ២៥,៦៤% ប៉ុណ្ណោះ។

គ.ស.ន ស្នើរិសោធនកម្ម «**ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ**» និង «**ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ**» ព្រមទាំង «**ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់**» និងស្នើថែមមួយចំណុចទៀតថា គណបក្សនយោបាយត្រូវមានគោលនយោបាយសមភាពយេនឌ័រដែលមានចែងជាលាយល័ក្ខអក្សរ។

អ្នកសម្របសម្រួលផ្នែកអប់រំនិងយេនឌ័រ មកពីអង្គការខុមហ្វ្រែល លោកស្រី សឺនកេត សិរីលក្ខណ៍ មានប្រសាសន៍ថា ក្រុមលោកស្រីលើកទឹកចិត្តគណបក្សនយោបាយដែលខិតខំបង្កើនចំនួនស្ត្រី ប៉ុន្តែអត់ពេញចិត្តនឹងតួលេខដែលកើនតែ ១,៦២% បែបនេះទេ។

លោកស្រីថា៖ *«ថ្មីៗហ្នឹងយើងបានជួបដែរ រកឃើញថាមេឃុំ-ចៅសង្កាត់ស្ត្រី ធ្វើការពិតជាមានប្រសិទ្ធិភាព ហើយយកចិត្តទុកដាក់ខ្លាំងទៅលើបញ្ហាស្ត្រីនិងកុមារ។ មានការឲ្យតម្លៃខ្លាំងមែនទែនទាំងប្រជាពលរដ្ឋក្តី រដ្ឋាភិបាលក្តី សង្គមស៊ីវិលក្តី ប៉ុន្តែចំនួននេះយើងឃើញថាកើន តែវាតិចតួច ដែលយើងគិតថាមិនទាន់ពេញចិត្តនូវអ្វីដែលយើងបានទទួលនៅក្នុងប្រទេសកម្ពុជាទេ»*។

អ្នកសម្របសម្រួល គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ កញ្ញា សេង រាសី បានលើកឡើងពីបញ្ហាប្រឈមសំរាប់ស្ត្រីថា គឺដោយសាររចនាសម្ព័ន្ធក្នុងបក្សនយោបាយនៅមានភាពតឹងតែង និងមានផ្នត់គំនិតថាដាក់ស្ត្រីច្រើនខ្លាចចាញ់។

កញ្ញាថា៖ «*ដោយសារតែប្រទេសយើងប្រើប្រព័ន្ធសមាមាត្រ ដូច្នេះហើយត្រូវបោះឲ្យគណបក្ស អញ្ចឹងបើសិនជាបោះឲ្យគណបក្សគឺស្ត្រីនៅក្នុងគណបក្សហ្នឹង! ចឹងបើសិនជាខ្ញុំពេញចិត្តគាត់ខ្ញុំត្រូវបោះឲ្យបក្សដែលគាត់ឈរហ្នឹង! ក៏ប៉ុន្តែជាក់ស្តែងនៅពេលដែលស្ត្រីគាត់ខំប្រឹងប្រែងរកប្រជាប្រិយឲ្យគណបក្សនយោបាយ បែរជាអ្នកដែលមានតួនាទីសំរេចចិត្តឬអ្នកដែលឈរលេខរៀងខ្ពស់គឺជាបុរសទៅវិញ។ ដោយសារគាត់មើលឃើញថាដាក់អ្នកនយោបាយ អ្នកនយោបាយគេប្រើពាក្យថា ឲ្យតែអ្នកនយាបាយភាគច្រើនគេស្រម៉ៃដល់បុរស អ្នកដឹកនាំគេស្រម៉ៃដល់បុរស ចៀសជាងស្រម៉ៃដល់ស្ត្រី*»។

លោកស្រី ធីតា ឃិះ នាយិកាប្រតិបត្តិអង្គការសីលការ និងជាប្រធានគណៈកម្មាធិការដឹកនាំ គ.ស.ន សង្ឃឹមថាអ្នកដឹកនាំបុរសដែលជាអ្នកធ្វើការសម្រេចចិត្តនឹងចាប់ផ្តើមគិតគូររឿងនេះដើម្បីដើរឲ្យទាន់ពិភពលោក។

លោកស្រីថា៖ «*យើងកំពុងធ្វើការតស៊ូមតិហ្នឹងដើម្បីឲ្យមានច្បាប់! យើងទៅនិយាយជាមួយមេគណបក្ស មេគណបក្សធ្វើការសម្រេចចិត្តហើយ ៣០%ស្ត្រី ៣០%យុវជន ហើយនិង៤០%អ្នកដែលចាស់! ប៉ន្តែគាត់ធ្វើកើតទេ? អញ្ចឹងទៅគាត់ធ្វើការសម្រេចចិត្តគាត់ចង់បានអញ្ចឹងដែរ តែដល់អនុវត្តមែនទែន អត់! អញ្ចឹងទៅបានថាយើងទាមទារឲ្យមានច្បាប់ជាតិ ហើយទាមទារឲ្យមានគោលនយោបាយយេនឌ័រនៅក្នុងគណបក្សគាត់ផង ព្រោះតែមិនអញ្ចឹងអនុវត្តអត់បាន*»។

បេក្ខជនស្ត្រីលេខរៀងទី៣ គណបក្សសង្គ្រោះជាតិ មកពីសង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ អ្នកនាង យ៉ាន វ៉ាន់ណែត ថាមិនមែនជាការងាយស្រួលទេដែលមកឈរបេក្ខជននេះ។

អ្នកស្រីថា៖ «*ចង់បញ្ជាក់ថាស្ត្រីដែលមានវត្តមាននៅទៅនេះ ហើយជាបេក្ខជនដែលជាប់លេខហ្នឹង គឺពួកខ្ញុំតវ៉ាមតិខ្លាំងមែនទែន ទើបពួកយើងអាចឈរលេខរៀងជាប់បាន*»។

សូមបញ្ជាក់ផងដែរថា ការអភិវឌ្ឍដោយមានចេរភាព គឺគេរាប់ពីឆ្នាំ២០១៦ដល់ឆ្នាំ២០៣០ ហើយនៅក្នុងឆ្នាំ២០៣០នោះ គោលដៅដែលគេកំណត់ទូទាំងពិភពលោក គឺឲ្យមានការដឹកនាំរវាងស្ត្រីនិងបុរស៥០ភាគរយស្មើគ្នា។ នៅពេលបច្ចុប្បន្ននេះ យើងមានស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ មានតែ១៧,៧៨% ប៉ុណ្ណោះ៕

# សង្គមស៊ីវិលៈ បក្សនយោបាយខកខានក្នុងការលើកកម្ពស់ស្ត្រីក្នុងវិស័យនយោបាយ

***ដោយ (VOA)***

ក្រុមអង្គការសង្គមស៊ីវិលសម្តែងក្តីបារម្ភថា កម្ពុជា ក៏នឹងបរាជ័យក្នុងការសម្រេចឲ្យបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចិរភាព (Sustainable Development Goals) របស់អង្គការសហប្រជាជាតិ ដែលបានកំណត់ថាស្ត្រីត្រូវចូលរួមឲ្យបាន៥០ភាគរយ នៃការដឹកនាំក្នុងកិច្ចការនយោបាយ នៅឆ្នាំ២០៣០។

ភ្នំពេញ —

ស្ត្រីកម្ពុជានៅតែមិនអាចចូលរួមបម្រើវិស័យនយោបាយក្នុងលំដាប់ខ្ពស់បានច្រើនដដែលនៅពេលដែលចំនួនស្ត្រីឈរឈ្មោះក្នុងការបោះឆ្នោតឃុំ-សង្កាត់នៅមានចំនួនតិចបើធៀបនឹងចំនួនបុរស។ នេះបើយោងតាមការបញ្ជាក់ពីក្រុមអង្គការសង្គមស៊ីវិលដែលធ្វើការពង្រឹងសិទ្ធិស្ត្រីក្នុងវិស័យនយោបាយ។

ក្រុមអង្គការសង្គមស៊ីវិល បាននិយាយនៅថ្ងៃអង្គារនេះថា ការដាក់បេក្ខជនស្ត្រីឈរឈ្មោះសម្រាប់លេខរៀងកំពូលក្នុងបញ្ជីដែលភាគច្រើនសម្រេចដោយបុរស និងស្ថានភាពហិរញ្ញវត្ថុដែលមានកម្រិតរបស់ស្ត្រី ក៏ដូចជាបណ្តាញរឹងមាំរបស់បុរសក្នុងគណបក្សនយោបាយ បានធ្វើឲ្យស្ត្រីបាត់ឱកាសក្នុងការទទួលបានតួនាទីខ្ពស់ក្នុងកិច្ចការរដ្ឋបាល ដែលអាចអនុញ្ញាតឲ្យពួកគេមានអំណាចក្នុងការសម្រេចចិត្ត ដោះស្រាយបញ្ហាប្រឈមរបស់ស្ត្រី និងបញ្ហាផ្សេងទៀតសម្រាប់ពលរដ្ឋទូទៅ។

ពួកគេសម្តែងក្តីបារម្ភថា កម្ពុជាក៏នឹងបរាជ័យក្នុងការសម្រេចឲ្យបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចិរភាព (Sustainable Development Goals) របស់អង្គការសហប្រជាជាតិ ដែលបានកំណត់ថា ស្ត្រីត្រូវចូលរួមឲ្យបាន៥០ភាគរយ នៃការដឹកនាំក្នុងកិច្ចការនយោបាយ នៅឆ្នាំ២០៣០។

កញ្ញា សេង រាសី អ្នកសម្របសម្រួលគណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ ថ្លែងក្នុងសន្និសីទព័ត៌មានស្តីពីលទ្ធផលអង្កេតនៃការដាក់បេក្ខភាពស្ត្រីឈរឈ្មោះបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ រៀបចំឡើងនៅរាជធានីភ្នំពេញនាថ្ងៃ អង្គារនេះថា កំណើនដ៏តិចតួចនៃចំនួនស្ត្រីឈរឈ្មោះឆ្នោតនេះនឹងនៅតែជារនាំងមួយ ដែលមិនអាចបើកផ្លូវឲ្យស្ត្រីដោះស្រាយបញ្ហាស្ត្រីខ្លួនឯងបាន និងបញ្ហានៅថ្នាក់មូលដ្ឋានផ្សេងទៀត។

«ប្រសិនបើចំនួនរបស់ស្ត្រីនៅតែកើនឡើងតិចតួច បែបនេះ បញ្ហារបស់ស្ត្រី នៅថ្នាក់មូលដ្ឋាន ក៏ដូចជា បញ្ហាផ្សេងៗ នៅថ្នាក់ក្រោមជាតិ នៅតែមិនទាន់អាចឆ្លើយតបបានពេញលេញ ដោយសារតែចំនួនស្ត្រីនៅក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ មានកើនតិចតួច»។

កញ្ញា សេង រាសី បានប្រាប់ VOA បន្ថែមថា ការបន្តផ្តល់អំណាចឲ្យបុរសជាអ្នកជ្រើសរើសបេក្ខជនស្ត្រី នឹងនៅតែធ្វើឲ្យស្ត្រីមានការពិបាកក្នុងការទទួលតំណែងកំពូលសម្រាប់ការសម្រេចចិត្ត។ កញ្ញាបន្តថា កង្វះតម្លាភាពក្នុងការជ្រើសរើសបេក្ខជនឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយនីមួយៗ ជាផ្នែកមួយនាំឲ្យស្ត្រីបាត់បង់លេខរៀងលំដាប់ខ្ពស់ក្នុងការឈរឈ្មោះផងដែរ។

មួយវិញទៀត កញ្ញា សេង រាសី និយាយថា ស្ត្រីក៏មានបញ្ហាប្រឈមជាមួយនឹងផ្នែកថវិកាសម្រាប់ការចូលរួមក្នុងវិស័យនយោបាយ នៅពេលគណបក្សនយោបាយនីមួយៗសម្លឹងរកបុគ្គលណាដែលមានលទ្ធភាពអាចទ្រទ្រង់គណបក្សនយោបាយបានផង និងអាចបំពេញការងារបម្រើរដ្ឋបានផង។

«ធម្មតាទេ រឿងធ្វើនយោបាយត្រូវការលុយកាក់ ហើយស្ត្រីពិបាកណាស់ក្នុងការឲ្យគាត់ មកយកលុយកាក់ពីផ្ទះហ្នឹងមកធ្វើនយោបាយ បើសិនគ្រួសារគាត់ជាបុរសហ្នឹង ជាប្តីហ្នឹងធ្វើនយោបាយ ប្រហែលជាគាត់សុខចិត្តឲ្យប៉ុន្តែ បើគាត់ ជាអ្នកធ្វើនយោបាយវិញ គាត់ពិចារណាថាតើគាត់គួរយកលុយផ្ទះមកធ្វើនយោបាយ ឬអត់»។

យោងតាមលទ្ធផលនៃការសង្កេតបេក្ខជនស្ត្រីឈរឈ្មោះសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ ដែលស្រាវជ្រាវដោយអង្គការសង្គមស៊ីវិលចំនួនបី បានឲ្យដឹងថា ក្នុងឆ្នាំ ២០១៧នេះ មានបេក្ខជនស្ត្រីចំនួនសរុប ២៥.៧៨៨នាក់ ស្មើនឹង ២៧,២៦ភាគរយ នៃបេក្ខជនប្រុស ស្រី សរុប ៩៤.៥៩៥ នាក់ គឺកើន ចំនួន ១,៦២ភាគរយ ធៀបនឹងឆ្នាំ ២០១២ ដែលមានចំនួនតែ ២៥, ៦៤ភាគរយប៉ុណ្ណោះ។

កញ្ញាសេង រាសី បានបន្ថែមថា កម្ពុជានឹងមិនអាចសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចិរភាព បានទេ ប្រសិនបើកំណើនស្ត្រីឈរឈ្មោះបោះឆ្នោតនៅបន្តកើនត្រឹមតែជិត២ភាគរយ ក្នុងរយៈពេលប្រាំឆ្នាំទៅមុខទៀតនោះ។

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ចំនួនជាង១.៦០០ ដែលជាការបោះឆ្នោត ថ្នាក់ក្រោមជាតិគឺដើម្បីផ្លាស់ប្តូរមន្ត្រីដឹកនាំថ្នាក់មូលដ្ឋានដ៏សំខាន់នឹងរៀបចំឡើងនៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៧នេះ។

គណបក្សនយោបាយ ដែលចូលរួមប្រកួតប្រជែងចំនួន១២ កំពុងរៀបចំគោលនយោបាយ យុទ្ធសាស្ត្ររបស់ខ្លួន ដើម្បីឃោសនារកសំឡេងឆ្នោតក្នុងរយៈពេល១៤ថ្ងៃមុនថ្ងៃបោះឆ្នោតដើម្បីយកជ័យជម្នះលើគូប្រជែងនយោបាយ។

ក្រុមអង្គការសង្គមស៊ីវិល ដែលឃ្លាំមើលបេក្ខជនស្ត្រីឈរឈ្មោះសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ សម្រាប់អាណត្តិទីបួន បានស្នើឲ្យមានការកែសម្រួលច្បាប់ពាក់ព័ន្ធនឹងការបោះឆ្នោត និងការបង្កើតគោលនយោបាយ ដើម្បីបង្កើនចំនួនបេក្ខជនស្ត្រី ក្នុងការឈរឈ្មោះបោះឆ្នោត។

ពួកគេស្នើឲ្យធ្វើវិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងបំណងធានាថា បេក្ខភាពស្ត្រីត្រូវបានឈរឈ្មោះក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ដោយដាក់ឆ្លាស់គ្នារវាងស្ត្រី និងបុរសតាមលំដាប់លេខរៀងពីលើដល់ក្រោម ដែលជាវិធានការសមស្រប និងមានប្រសិទ្ធភាពបំផុតក្នុងការធ្វើឲ្យមានសមភាពយេនឌ័រពិតប្រាកដ។

អ្នកស្រី ធីតា ឃឺះ នាយិកាប្រតិបត្តិនៃអង្គការសីលការ ដែលធ្វើការងារលើការពង្រឹងអភិបាលកិច្ចសាធារណៈ ប្រាប់ VOA ថា មានហេតុផលមួយចំនួនទៀតដែលមេដឹកនាំគណបក្សនយោបាយ ពិបាកក្នុងការដាក់បេក្ខជនស្ត្រីនោះ គឺផលប្រយោជន៍បុគ្គល និងតំបន់ដែលមានទំនាស់សង្គម។

អ្នកស្រីមានប្រសាសន៍ថា ជាគោលការណ៍ មេដឹកនាំគណបក្សនយោបាយមានបំណងចង់ដាក់បេក្ខជនស្ត្រីឲ្យបានច្រើននៅតាមមូលដ្ឋានមួយចំនួន ក៏ប៉ុន្តែការណ៍នេះមិនអាចធ្វើបាន ដោយហេតុបុគ្គលកំពុងកាន់តួនាទីដែលជាបុរសនោះមិនព្រមចុះចេញ។

«ក៏ប៉ុន្តែនៅតែមានការលំបាក ជាពិសេសកន្លែងណាដែលរកលុយបានច្រើន កន្លែងណាដែលចម្រូងចម្រាសរឿងដីធ្លី»។

អ្នកស្រី ធីតា ឃឺះ នាយិកាប្រតិបត្តិនៃអង្គការសីលការ នៅក្នុងសន្និសីទសារព័ត៌មានស្តីពី«លទ្ធផលអង្កេតនៃការដាក់បេក្ខភាពស្ត្រីឈរឈ្មោះក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤» ក្នុងរាជធានីភ្នំពេញ នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៧។ (ហ៊ាន សុជាតា/VOA)

យ៉ាងណាក៏ដោយ អ្នកស្រីជឿថា ចំណុចរាំងស្ទះនឹងអាចដោះស្រាយបាន នៅពេលមានស្ត្រីកាន់តែច្រើន ចូលកាន់តំណែងដែលអាចធ្វើការសម្រេចចិត្តបាន។

ដោយឡែក សកម្មជនគណបក្សនយោបាយដែលបានចូលរួមស្តាប់លទ្ធផលអង្កេតនៃការដាក់បេក្ខភាពស្ត្រីឈរឈ្មោះបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់បាននិយាយថា ជាការពិបាកសម្រាប់ពួកគេក្នុងការទទួលបានលេខរៀងខ្ពស់ក្នុងបញ្ជីបេក្ខជន។ ពួកគេលើកឡើងថា ប្រសិនបើមិនមានការតស៊ូមតិ ឬចងក្រងជាក្រុម ដើម្បីតវ៉ានោះទេលេខរៀងខ្ពស់ៗនឹងបានតែទៅលើបេក្ខជនបុរស។

អ្នកស្រី យ៉ែម វណ្ណណែត បេក្ខជនស្ត្រីលេខរៀងទី ៣ មកពីគណបក្សសង្គ្រោះជាតិសម្រាប់ការបោះឆ្នោតឃុំ-សង្កាត់ នៅសង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ ប្រាប់ VOA ថា អ្នកស្រីបានធ្វើការតស៊ូជាច្រើនទម្រាំនឹងត្រូវបានជ្រើសរើសឲ្យឈរក្នុងលេខរៀងទី ៣។ អ្នកស្រីនិយាយថា៖

«អញ្ចឹងនាងខ្ញុំក៏លើកពីបញ្ហាស្ត្រីទាំងអស់ប្រាប់គាត់ហើយក៏ថា បើសិនជាខ្ញុំជាស្ត្រី ខ្ញុំអាចចូលរួមជួយស្ត្រី និងដោះស្រាយបញ្ហាស្ត្រីទាក់ទងនឹងគាត់មានផ្ទៃពោះ អាចជួយកុមារសាលាមតេយ្យសម្រាប់កុមារ។ ខ្ញុំលើកអញ្ចឹងហេតុផល ដែលទាក់ទងបញ្ហាស្ត្រីទៅ គាត់ក៏ផ្តល់ឱកាសឲ្យខ្ញុំជាស្ត្រីហ្នឹង ឈរជាបេក្ខជនលេខរៀងជាប់នៅក្នុងសង្កាត់សួង»។

អ្នកស្រី បានស្នើឲ្យគណបក្សនយោបាយអ្នកស្រី បង្កើតកម្មវិធីនយោបាយដែលនឹងឆ្លាស់គ្នានៅលេខរៀងកំពូលគឺបើស្ត្រីឈរក្នុងលេខរៀងទីមួយបុរសត្រូវឈរក្នុងលេខរៀងទីពីរហើយបើបុរសឈរក្នុងលេខរៀងទីមួយស្ត្រីត្រូវឈរក្នុងលេខរៀងទីពីរ។

ក្រុមអង្គការសង្គមស៊ីវិលដែលធ្វើការពង្រឹងសិទ្ធិស្ត្រីក្នុងវិស័យនយោបាយ ក៏បានឲ្យដឹងដែរថា គណបក្សធំៗពីរដែលមានប្រជាប្រិយភាព គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ បានបង្កើនបេក្ខជនស្ត្រីក្នុងបញ្ជីឈ្មោះបេក្ខជនរបស់ខ្លួន តែចំនួននេះគឺនៅទាបជាងចំនួនបេក្ខជនស្ត្រីដែលសម្រេចដាក់ឲ្យឈរឈ្មោះពីគណបក្សតូចៗ១០ផ្សេងទៀត។

ពួកគេនិយាយថា គណបក្សធំៗពីរនេះទំនងជាបារម្ភថា ខ្លួននឹងចាញ់ការបោះឆ្នោតបើដាក់ស្ត្រីច្រើនឲ្យឈរឈ្មោះ។ ពួកគេសង្កត់ធ្ងន់ថា ការបារម្ភបែបនេះអាចជាការយល់ខុសដោយសារតាមការស្ទាបស្ទង់មតិ យុវជនភាគច្រើនដែលជាម្ចាស់ឆ្នោតពេញចិត្តបេក្ខជនស្ត្រីជាងបុរស៕

# ខុមហ្វ្រែលប្រតិកម្មមិនចង់ឲ្យសួរពីសមត្ថភាពស្ត្រីក្នុងការដឹកនាំ

រៀបរៀងដោយ :
តោះអាន May 9, 2017
ដោយ៖ ឃី ពិសី

អ្នកសម្របសម្រួលផ្នែកអប់រំ និងយេនឌ័ររបស់ ខុមហ្វ្រែល លោកស្រី សឺនកេត សិរីលក្ខណ៍ មិនចង់ឲ្យមានអ្នកសួរអំពីសមត្ថភាពស្ត្រីក្នុងការដឹកនាំសង្គមថាអាចធ្វើអ្វីបានខ្លះនោះទេ។ ព្រោះលោកស្រីយល់ថា វាជាសំណួររើសអើងបំផុត ដែលជាសកម្មភាពបង្អាក់ដល់ការចូលរួមរបស់ស្ត្រីក្នុងឆាកនយោបាយ។ ប្រតិកម្មនេះធ្វើឡើងបន្ទាប់ពីមានអ្នកការសែតលើកជាសំនួរឡើង ក្នុងសន្និសិទសារព័ត៌មាន ស្តីពី «លទ្ធផលអង្កេតបេក្ខជនក្រុមប្រឹក្សាឃុំ/សង្កាត់» នាព្រឹកថ្ងៃទី ០៩ ឧសភា នៅសណ្ឋាគារសាន់វេ ។

តំណាងអង្គការខុមហ្វ្រែលដដែល បានអះអាងដោយទឹកមុខរឹងមាំ ប្រាប់ឲ្យអ្នកចូលរួម ដែលភាគច្រើនជាស្ត្រីចង្អុលបង្ហាញពីសមិទ្ធិផល ឬសកម្មភាពណាខ្លះ ដែលមេឃុំបុរសៗ ជាង៩០% ស្មើ ១៦៣៣ ឃុំនោះបានធ្វើ។ ប្រតិកម្មភ្លាម នៅពេលអ្នកកាសែត លើកជាសំនួរ ថា តើស្ត្រីគួរមានសមត្ថភាពអ្វីខ្លះក្នុងការដឹកនាំសង្គម? ដោយលោកស្រី សឺនកេត សិរីលក្ខណ៍ ចាត់ទុកសំនួរបែបនេះថា ជាការរើសអើងស្ត្រីបំផុត។

លោកស្រី សឺនកេត សិរីលក្ខណ៍ បញ្ជាក់ថា៖ *«គួរឈប់លើកសំណួរអំពីសមត្ថភាពរបស់ស្ត្រី ហើយសក្តានុពលរបស់ស្រី ធើការបានអីខ្លះ? ប៉ុន្តែសំណួរដដែលៗ សួរថាស្ត្រីមានសក្តានុពលទេ ? ធ្វើការងារក្នុងសង្កាត់រីកចម្រើនទេ ? ស្ត្រីក៏ជាមនុស្ស បុរសក៏ជាមនុស្ស ស្ត្រីមិនមែនជាអាទិទេព ដែលចូលទៅត្រូវឲ្យផ្ការីកព្រោងព្រាតក្នុងក្នុងឃុំហ្នឹងទាំងអស់ទេ វាមិនអាចទេ»* ។

ការឆ្លើយតបរបស់លោកស្រីបែរជាមានន័យទៅលើផ្ការីកទៅវិញ។ បើតាមអត្ថន័យពិតនៃសំណួរ គឺអ្នកសារព័ត៌មានគ្រាន់តែចង់ដឹងអំពីគោលនយោបាយ របៀបនៃការដឹកនាំរបស់ស្ត្រី ដើម្បីផ្សព្វផ្សាយដល់សាធារណជន ក្នុងបោះឆ្នោតជូនប៉ុណ្ណោះ មិនមានអ្វីផ្សេងទេ។

ទាក់ទងនឹងបញ្ហានេះ អ្នកសម្របសម្រួលនៃគណៈកម្មាលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ កញ្ញា សេង រាសីហាក់ដូចជាសម្តែងនូវអាកប្បកិរិយាមើលរំលងទៅលើការដឹកនាំរបស់មេឃុំបុរសៗមួយចំនួនធំ ដោយប្រាប់ឲ្យអ្នកចូលរួមក្នុងពិធីសង្កេតលើការដោះស្រាយបញ្ហានានាដែលស្ត្រីជួបប្រទះក្នុងមូលដ្ឋានរបស់បុរស។

នៅពេលដែលអ្នកសារព័ត៌មានលើកជាសំណួរអំពីសមត្ថភាព ឬសក្ដានុពលរបស់ស្ត្រីក្នុងការដឹកនាំឃុំ/ សង្កាត់វិញតើអាចធ្វើអ្វីបានខ្លះនៅពេលជាប់ឆ្នោត? កញ្ញា សេង រាសី បានឆ្លើយតបថាមិនចាំបាច់ឲ្យកញ្ញាឆ្លើយតបនោះទេ ដោយសួរអ្នកដែលបានចូលរួមទៅដឹងហើយ។

កញ្ញា សេង រាសី បញ្ជាក់ថា៖ « *ខ្ញុំជឿជាក់ថាស្ត្រីណាក៏ដោយក៏មានសក្ដានុពលរបស់គាត់ដែរ ប៉ុន្តែសក្ដានុពលនេះពេលខ្លះត្រូវបានគេកប់ចោល។ តែនេះមិនជាសក្ដានុពលជាក់ស្ដែងដែលយើងបានឃើញទេ។ មិនបន្ទោសទៅលើបុរសគ្មានសមត្ថភាពទេ លោកមានហើយ ទើបឈរឈ្មោះជាក្រុមប្រឹក្សាឃុំ/សង្កាត់បាន ក៏ប៉ុន្តែមើលទៅក្រុមប្រឹក្សា ឃុំ/សង្កាត់ ១៦០០ ឃុំជាងហ្នឹង ថាតើប្រសិទ្ធិភាពនៃកិច្ចការងាររបស់មេឃុំទាំងអស់ឆ្លើយតបបញ្ហាស្ត្រី និងប្រជាពលរដ្ឋបានកម្រិតប៉ុណ្ណា? ប្រជាពលរដ្ឋក្នុងបន្ទប់នេះសួរទៅថាតើសមត្ថភាពចៅសង្កាត់ខ្លួនឯងសមត្ថភាពយ៉ាងម៉េចដែរ? មិនបាច់ឲ្យខ្ញុំឆ្លើយតបទេ*» ។

កញ្ញាក៏បានផ្ដាំទៅបុរសៗ ការលើកកម្ពស់ស្ត្រីដែលកញ្ញាកំពុងធ្វើនេះ គឺមិនមែនសំដៅទៅដណ្ដើមអំណាចតំណែង ឬផាត់បុរសចោលនោះទេ។ កញ្ញាបន្តថា កុំយល់ច្រឡំ ហើយកញ្ញាបានសង្កត់ធ្ងន់ដូច្នេះ បើមិនចង់ឲ្យមានការលើកស្ទួយស្ត្រីទេ លុះត្រាតែការអនុវត្តច្បាប់ក្នុងស្រុកខ្មែរចាប់តែបុរស គឺកុំចាប់ស្ត្រី។ កញ្ញាបានចោទទៅលើគណបក្សនយោបាយល្បីៗ ដែលមិនបានដាក់បេក្ខភាពស្ត្រីច្រើនក្នុងរចនាសម្ព័ន្ធគឺគ្រាន់តែលេសមួយប៉ុណ្ណោះ។

មិនខុសគ្នាប៉ុន្មានលោកស្រី ធីដា ឃិះ នាយិកាប្រតិបត្តិអង្គការសីលការ ចង់ឲ្យរដ្ឋាភិបាលបង្កើតច្បាប់ពិសេសមួយក្នុងការបើកផ្លូវឲ្យស្ត្រីមានលទ្ធភាពចូលក្នុងរចនាសម្ព័ន្ធធំៗក្នុងជួរគណបក្សនយោបាយ។ ការថ្លែងរបស់លោកស្រីទំនងជាចង់បើកផ្លូវឲ្យស្ត្រី ងាយស្រួលឈោងទៅចាប់យកតំណែងកំពូលនៃស្ថាប័នជាតិ ហើយបើសិនគណបក្សណាមួយមិនអនុវត្តន៍ទេ លោកស្រីចង់ឲ្យរដ្ឋាភិបាលត្រូវតែដាក់ពិន័យចំពោះគណបក្សនោះ។

លោកស្រី ធីដា ឃិះ បញ្ជាក់ថា៖ «*ស្ត្រីនៅតែជួបប្រឈមនឹងការលំបាក ជាមួយជួរគណបក្ស ដូច្នេះបញ្ហាសំខាន់ដែលយើងត្រូវធ្វើ គឺខាងរដ្ឋាភិបាលគួរតែបង្កើតច្បាប់ពិសេសដើម្បីឲ្យទាំងអស់គ្នា គណបក្សនយោបាយទាំងអស់ គាត់អនុវត្តន៍ ហើយបើមិនអនុវត្តន៍ទេ គាត់នឹងមានជាការពិន័យអីទៅចឹងឯង*» ។

លោកស្រីបានបន្ថែមថាស្ត្រីគួរតែជាអ្នកសម្រេចចិត្តក្នុងការចាយលុយ និងការរៀបចំគោលនយោបាយតាំងពីថ្នាក់ក្រោម រហូតដល់ថ្នាក់ជាតិ ចាំបាច់ត្រូវតែមានស្ត្រីចូលរួម ដើម្បីឲ្យមានសេវាសាធារណៈ និងសង្គមកិច្ចបានដល់ពលរដ្ឋ។

របាយការណ៍នេះត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ ចាប់ដៃជាមួយអង្គការសីលការ និងអង្គការខុមហ្វ្រែល បានបង្ហាញក្ដីខកចិត្តនៅពេលដែលពួកគេរករកឃើញថា មានបេក្ខភាពស្ត្រី ២៥,៧៨៨នាក់ ស្មើនឹង ២៧,២៦% នៃបេក្ខជនសរុប ៩៤,៥៩៥នាក់ ដែលបានឈរឈ្មោះជាបេក្ខភាព ឃុំ/សង្កាត់ ក្នុងការបោះឆ្នោតអាណត្តិទី ៤ ឆ្នាំ ២០១៧៕

# Female representation in politics decreased in commune elections

**30 June, 2017 Phnom Penh Post**

Despite repeated vows by both of Cambodia's major political parties to increase female representation, the number of female candidates elected in the Kingdom's recently concluded commune elections actually decreased since they were last held in 2012.

"For years, women have been trying so hard, but the number is not growing – it's even decreasing," said Seng Reasey, of women's rights NGO Silaka, visibly disappointed at a press conference yesterday.

In the June 4 election, a total of 1,940 women secured seats as commune chiefs, deputy chiefs or commune councillors – almost a hundred fewer than in the 2012 elections, in which 2,038 were elected.

Sonket Sereyleak, gender equality coordinator at election monitor Comfrel, recommended tackling the issue on two levels: first, by amending the election law to include gender equality provisions, and second, by having political parties adopt written internal policies that prescribed the number of female candidates.

"Sometimes people say it's difficult to amend election laws, but laws can be amended quickly when there is political will," she said.

Reasey agreed after the press conference.

"In the Cambodian political context, if they want to, they can amend laws in a day, a week or a month," she said, pointing to the recent quick, albeit controversial, amendments to the Law on Political Parties.
"We need to promote equality in the written form, not only verbally," Reasey said. "Otherwise we won't achieve the Sustainable Development Goal [SDG] of 25 percent [female political representation]."

In only seven provinces will more than 20 percent of commune councillors be women, while only one province – Pailin – reached the SDG, with 28.85 percent. Takeo and Tbong Khmum scored the lowest, with only 12.5 percent each.

Neither the ruling Cambodian People's Party, nor the main opposition Cambodia National Rescue Party improved on their total percentages in any significant sense. The elected female candidates from the CPP make up just 21.33 percent of the total number of victorious candidates – a slight decrease from the 21.48 percent in 2012. For the CNRP, 11.04 percent of winning candidates were women, barely up from 11 percent in 2012.

However, Silaka's Reasey said, at least the number of female commune chiefs had increased from 95 to 128.

Reasey said the drop in representation might discourage women. "If you see the negative trend, you ask yourself: 'Is that a place for me?'" she said.

But CNRP Deputy President Mu Sochua yesterday said the increase of female commune chiefs proved that their efforts “have borne fruit”.

Still, she said, “I’m unhappy with the overall achievement.”

She said adopting a written policy was difficult, because her colleagues, “especially older men”, were not willing to step down for younger candidates – “let alone women”, she said.

“But pushing too hard will antagonise the men and some women, so our strategy is to show that . . . we have made some positive gains,” she said.

Ministry of Women’s Affairs spokesperson Pon Puthborei declined to comment, and representatives of the CPP could not be reached yesterday.

Chak Sopheap, executive director of the Cambodian Center for Human Rights, said in an email that “it is no surprise to see these bitterly disappointing figures emerge”.

“Reports of political parties actively disempowering women candidates by pushing them down electoral lists [are] representative of the misogyny that permeates all facets of Cambodian society. Our political leaders should be promoting full gender equality, and not just [be] talking about it,” she said.

The Post reported last month that women were pushed down on the ballots to rankings where their election was more unlikely.

“Anything less than full gender equality is simply not good enough,” Sopheap said.

# ចំនួនស្ត្រីជាប់ឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តទី៤ថយចុះ

**ដោយ សុ ជីវី 2017-07-01**

ក្រុមអង្គការសង្គមស៊ីវិលធ្វើការងារលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយរកឃើញថា ចំនួនស្ត្រីដែលបានជាប់ឆ្នោតនៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៤ នេះ បានថយចុះបើប្រៀបធៀបនឹងអាណត្តិទី៣ កន្លងទៅ។

ពួកគេសោកស្តាយ និងព្រួយបារម្ភថា ការថយចុះចំនួនស្ត្រីជាតំណាងនៅក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់នេះ នឹងធ្វើអោយបញ្ហាស្ត្រី និងកុមារនៅមូលដ្ឋានមិនអាចឆ្លើយតបបានគ្រប់គ្រាន់ឡើយ។ លើសពីនេះ នឹងធ្វើអោយប៉ះពាល់ដល់ការជំរុញលើកកម្ពស់សមភាពយេនឌ័រ និងផែនការរបស់រដ្ឋាភិបាលសម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចិរភាព។ ទោះបីជាយ៉ាងណា ពួកគេសាទរចំពោះការកើនឡើងនូវចំនួនមេឃុំ និងជំទប់ឃុំជាស្ត្រី។

ក្រុមអង្គការសង្គមស៊ីវិលបញ្ជាក់ថា តាមលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៤ ដែលចេញដោយ គ.ជ.ប គឺចំនួនស្ត្រីដែលបានជាប់ឆ្នោតសរុបមានចំនួនជិត ២ពាន់នាក់ (១.៩៤០) នៃចំនួនក្រុមប្រឹក្សាឃុំ-សង្កាត់សរុបជាង ១ម៉ឺននាក់ (១១.៥៧២) គឺបានថយចុះមកនៅជិត ១៧ ភាគរយ (១៦,៧៦%) បើប្រៀបធៀបនឹងការបោះឆ្នោតអាណត្តិទី៣ កាលពីឆ្នាំ២០១២។

របាយការណ៍ដដែលអោយដឹងទៀតថា ចំនួនមេឃុំស្ត្រីនៅក្នុងអាណត្តិថ្មីនេះ មានចំនួន ១២៨រូប ដោយបានកើនឡើងចំនួន ៣៣រូប បើប្រៀបធៀបនឹងអាណត្តិមុន។

អ្នកសម្របសម្រួលគណៈកម្មការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយកញ្ញា សេង រាសី ថ្លែងនៅក្នុងសន្និសីទសារព័ត៌មាននៅរសៀលថ្ងៃទី២៩ ខែមិថុនា ថា ការថយចុះចំនួនស្ត្រីនេះនឹងធ្វើអោយមានផលប៉ះពាល់ចំនួន៣ធំៗ រួមមានផលប៉ះពាល់ទៅលើគោលដៅរបស់រដ្ឋាភិបាល ប៉ះពាល់ទឹកចិត្តស្ត្រីដែលមានបំណងចូលរួមក្នុងវិស័យនយោបាយ និងការដោះស្រាយបញ្ហាស្ត្រី និងកុមារ៖ *«បានប៉ះពាល់ដល់ស្ត្រីដែលគាត់កំពុងតែធ្វើកិច្ចការនយោបាយក៏ដូចជាត្រៀមប្រឡូកក្នុងនយោបាយ នៅពេលណាដែលគំរូភាពរបស់គាត់នេះមានការធ្លាក់ចុះ។ ហេតុអ្វីបានយើងលើកអ៊ីចឹង? នៅពេលដែលស្ត្រីចូលរួមក្នុងឆាកនយោបាយដូចជាមុខងារសាធារណៈផ្សេងៗទៀត ចំនួនស្ត្រីកាន់តែច្រើនឡើង បានបង្ហាញឲ្យឃើញជាគំរូភាពសម្រាប់ស្ត្រីវ័យក្មេងក៏ដូចជាស្ត្រីផ្សេងទៀតថា ស្ត្រីអាចធ្វើបាន អាចចូលរួមបាន ចុះឥឡូវនេះគំរូភាពទាំងអស់នេះមានការធ្លាក់*

*ចុះ? ទី៣ ទៀត ការធ្លាក់ចុះនេះក៏ធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងទៅដល់ប្រជាពលរដ្ឋ ជាពិសេសស្ត្រី និងកុមារ ដោយសារតែសំឡេងរបស់ស្ត្រីនៅថ្នាក់មូលដ្ឋានមានការថយចុះ»។*

ក្រុមអង្គការសង្គមស៊ីវិលបានរកឃើញបញ្ហាមួយចំនួនដែលនាំអោយចំនួនស្ត្រីបានថយចុះនេះ។

អ្នកសម្របសម្រួលផ្នែកអប់រំ និងយេនឌ័រនៃអង្គការខុមហ្វ្រែល (COMFREL) អ្នកស្រី សឺន កេតសិរីលក្ខណ៍ មានប្រសាសន៍ថា ចំណុចសំខាន់ពីរដែលត្រូវយកចិត្តទុកដាក់គឺការធ្វើវិសោធនកម្មច្បាប់បោះឆ្នោត និង គណបក្សនយោបាយត្រូវបង្កើតគោលនយោបាយយេនឌ័រក្នុងគណបក្សនីមួយៗ៖ *«គិតគួរធ្វើម៉េចឲ្យមាននៅក្នុងច្បាប់បោះឆ្នោតកំណត់ឲ្យច្បាស់ក្នុងការដាក់ស្ត្រីឈរឈ្មោះ ទាល់តែមានការដាក់ឆ្លាស់គ្នារវាងបុរសស្ត្រីនៅក្នុងបញ្ជីឈ្មោះបោះឆ្នោតពីលើដល់ក្រោម ទើបចំនួនស្ត្រីអាចមានការកើនឡើង។ យើងមើលឃើញថាសម្រាប់ការបោះឆ្នោតលើកនេះ គណបក្សដែលមានសក្តានុពល គណបក្សដែលមានប្រជាប្រិយភាពខ្លាំងមានតែពីរគណបក្សទេ គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ហើយយើងមើលនៅក្នុងបញ្ជីឈរឈ្មោះរបស់បេក្ខជនរបស់គណបក្សទាំង១២ (គណបក្សដែលចូលរួមបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់) គឺគណបក្សទាំងពីរដាក់ស្ត្រីតិចជាងគេ»។*

អ្នកស្រី សឺន កេតសិរីលក្ខណ៍ បានរិះគន់ក្រសួងកិច្ចការនារីថា ពុំបានបំពេញតួនាទីអោយបានសកម្មនៅក្នុង ការជំរុញស្ត្រីអោយចូលរួមក្នុងវិស័យនយោបាយ៖ *«បើតាមដែលដឹង គឺគាត់ជំរុញទៅគ្រប់ក្រសួងទាំងអស់ត្រូវតែមានគោលនយោបាយសមភាពយេនឌ័រ។ បើយើងមើលក្នុងឯកសារដែលគាត់ធ្លាប់ធ្វើការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិលក្តី ជាមួយក្រសួងដែលពាក់ព័ន្ធក្តី យើងពិតជាមានការកោតសរសើរ ហើយសប្បាយចិត្ត។ ប៉ុន្តែយើងមើលថាបន្ទាប់ពីហ្នឹងមក ជាពិសេសគឺនៅក្នុងអំឡុងពេលនៃការធ្វើយុទ្ធនាការក្នុងដំណើរការរៀបចំការបោះឆ្នោត យើងឃើញថាក្រសួងកិច្ចការនារី គាត់ហាក់ដូចជាសកម្មភាពរបស់គាត់ដែលជំរុញឲ្យស្ត្រីចូលរួមក្នុងវិស័យនយោបាយហ្នឹង សកម្មភាពវាអត់ឃើញថាស្អីដែលវាលេចធ្លោ ដែលយើងគួរឲ្យសាទរ»។*

បើទោះជាយ៉ាងណា អង្គការសង្គមស៊ីវិលទទួលស្គាល់ដែរថា ក្រសួងកិច្ចការនារីបានធ្វើការងារក្នុងការរៀបចំអោយមានគោលនយោបាយជាច្រើនរួចហើយ ប៉ុន្តែទាមទារអោយមានការអនុវត្តសកម្មថែមទៀត។

អគ្គនាយករងនៃអគ្គនាយកដ្ឋានសមភាពយេនឌ័រ នៃក្រសួងកិច្ចការនារី លោក ថេ ឈុនហាក់ ឆ្លើយតបថា ក្រសួងមានគោលនយោបាយច្រើនដែលត្រូវអនុវត្ត នៅពេលដែលសង្គមស៊ីវិលមើលឃើញពីភាពអសកម្មអាចផ្តល់យោបល់ទៅក្រសួងដើម្បីកែលម្អ៖ *«យើងមានការជជែកគ្នានៅក្នុងកិច្ចប្រជុំបច្ចេកទេសជាមួយដៃគូ*

*អភិវឌ្ឍន៍ ជាមួយសង្គមស៊ីវិលដែរ គឺយើងមានយន្តការ។ អ៊ីចឹងក្នុងកន្លែងណាដែលគាត់ឃើញមិនទាន់សកម្ម គឺយើងអត់ប្រកែកថាយើងធ្វើអ្វីអត់ខ្វោះទេ ប៉ុន្តែបើគាត់មើលឃើញថាកន្លែងណាយើងអត់សកម្ម គាត់អាចលើកឡើងជាលាយលក្ខណ៍អក្សរ ឬក៏តាមរយៈកិច្ចប្រជុំភ្នាក់ងារបច្ចេកទេសយេនឌ័រ។ គឺយើងធ្វើការងារដើម្បីស្ត្រីកម្ពុជា យើងទាំងអស់គ្នា»*។

ចំពោះបញ្ហាថយចុះចំនួនស្ត្រីជាក្រុមប្រឹក្សាឃុំ-សង្កាត់នេះ លោក ឈុនហាក់ លើកឡើងថា ក្រសួងបានទទួលស្គាល់ថា ចំនួនស្ត្រីអាចនឹងថយចុះបែបនេះតាំងពីបានឃើញបញ្ជីឈ្មោះបេក្ខជនឈរឈ្មោះបោះឆ្នោតមកដែរ ហើយក្រសួងនឹងយកបទពិសោធន៍នេះ រួមនឹងបទពិសោធន៍ក្នុងការបោះឆ្នោតជាតិឆ្នាំ២០១៣ ដើម្បីរៀបចំផែនការត្រៀមសម្រាប់ការបោះឆ្នោតជាតិនៅក្នុងឆ្នាំ២០១៨ ខាងមុខ។ លោក ថេ ឈុនហាក់ លើកឡើងទៀតថា គោលបំណងរបស់សង្គមស៊ីវិល និងក្រសួងកិច្ចការនារីគឺដើរស្របគ្នាចំពោះការជំរុញអោយគណបក្សនយោបាយបង្កើតគោលនយោបាយសមភាពយេនឌ័រ ប៉ុន្តែលោកថា ការងារនេះជាការលំបាក៖ *«យើងនឹងធ្វើជាលក្ខណៈកម្រិតម៉ាក្រូ ដើម្បីជំរុញធ្វើយ៉ាងម៉េចឲ្យក្មេងស្ត្រីគាត់ចាប់អារម្មណ៍ច្រើនជាងមុននៅក្នុងការអភិវឌ្ឍមូលដ្ឋាន ហើយវាជាមូលដ្ឋានគ្រឹះធំណាស់សម្រាប់យើងបង្កើតជាលក្ខណៈម៉ាក្រូសម្រាប់ឈានទៅបោះឆ្នោតនៅលើកក្រោយៗទៀត ព្រោះយើងអត់ធ្វើតែសម្រាប់ថាឃើញលទ្ធផលប៉ុណ្ណឹងហើយ យើងធ្វើសម្រាប់តែរយៈពេលខ្លី យើងត្រូវគិតថាតើអ្វីជាយុទ្ធសាស្ត្ររយៈពេលវែង កុំឲ្យបទពិសោធន៍ហ្នឹងវាថយ វារាងថយបន្តិចនៅក្នុងឆ្នាំនេះ បើយើងប្រៀបធៀបនឹងឆ្នាំ២០០២ មក វាបានកើនបន្តិចៗ មកដល់ពេលនេះវារាងថយបន្តិច»*។

នៅក្នុងរបាយការណ៍ដែលចងក្រងដោយក្រសួងកិច្ចការនារីក្នុងឆ្នាំ២០១៤ អោយដឹងថា នៅក្នុងឆ្នាំ២០១២ តំណាងស្ត្រីនៅក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ បានកើនឡើងបើប្រៀបធៀបនឹងឆ្នាំ២០០៧ គឺកើនឡើងពី ១៥,១០% ភាគរយទៅ ១៧,៧៨%។ ក្នុងនោះស្ត្រីជាមេឃុំ និងចៅសង្កាត់មានចំនួន ៦៩រូប (៤,២២%) ស្ត្រីជាជំទប់ទី១ មានចំនួន ១៨៩រូប (១១,៥៧%) និងជំទប់ទី២ ចំនួន ១៥១រូប (៩,២៤%)។

អង្គការសង្គមស៊ីវិលមើលឃើញថា បញ្ហាស្ត្រី និងកុមារនៅមូលដ្ឋាននៅតែមិនអាចដោះស្រាយបានច្រើន ប្រសិនបើចំនួនស្ត្រីនៅក្នុងចំណោមសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ នៅតែមានចំនួនតិច។

កន្លងទៅទាំងគណបក្សកាន់អំណាច និងគណបក្សប្រឆាំងសុទ្ធតែបានអះអាងថា លើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ។ ប៉ុន្តែគណបក្សប្រជាជនកម្ពុជា បញ្ជាក់ថា ការដាក់ចំនួនស្ត្រីរបស់គណបក្សនេះ

ដោយផ្អែកលើប្រជាប្រិយភាព និងសមត្ថភាពរបស់ស្ត្រី ចំណែកគណបក្សប្រឆាំងវិញលើកឡើងថា ពិបាកនឹងរកស្ត្រីដែលក្លាហាន។

អ្នកសម្របសម្រួលផ្នែកអប់រំ និងយេនឌ័រនៃអង្គការខុមហ្វ្រែល អ្នកស្រី សឹន កេតសិរីលក្ខណ៍ លើកឡើងថា គណបក្សនយោបាយក៏ជាផ្នែកពាក់ព័ន្ធដែលត្រូវធានាអោយការសន្យារបស់រដ្ឋាភិបាលជាមួយសហគមន៍អន្តរជាតិក្នុងការជំរុញស្ត្រីក្នុងវិស័យនយោបាយបានជោគជ័យ៖ *«អ៊ីចឹងគណបក្សនយោបាយគាត់អាចមានផែនការ ឬក៏គោលនយោបាយក្នុងការដាក់ចំនួនស្ត្រីឲ្យបានច្រើនជាងមុន អាច ៤០ភាគរយក្តី ឬថាធ្វើឲ្យមានសមភាពយេនឌ័រ។ អ្វីដែលមានប្រសិទ្ធភាពបំផុត គឺមានតែច្បាប់បោះឆ្នោតទេ។ ហើយខ្ញុំមិនជឿថា ការតាក់តែងធ្វើវិសោធនកម្មច្បាប់មានការលំបាកទេសម្រាប់ប្រទេសកម្ពុជា យើង។ បើសិនជាអ្នកដឹកនាំមានឆន្ទៈក្នុងការចង់ឲ្យស្ត្រីចូលរួមឲ្យបានច្រើន»*។

សង្គមស៊ីវិលបានទទូចអោយគណបក្សនយោបាយបញ្ឈប់ការរើសអើងស្ត្រី ដោយការចោទសួរពីសមត្ថភាពរបស់ស្ត្រីក្នុងការចូលរួមវិស័យនយោបាយ ប៉ុន្តែត្រូវងាកមកចូលរួមពង្រឹងសមត្ថភាពស្ត្រីដើម្បីអោយស្ត្រីមានសមត្ថភាពចូលរួមក្នុងវិស័យនេះទៅវិញ។

មិនខុសគ្នានេះ គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញា ស៊ីដ ហៅកាត់ថា អិនជីអូ-ស៊ីដ (NGO-CEDAW) លើកឡើងថា ការខកខានចាត់វិធានការពិសេសបណ្តោះអាសន្ន ដើម្បីលើកកម្ពស់ស្ត្រីចូលរួមក្នុងវិស័យនយោបាយ ទាំងវិធានការខាងផ្លូវច្បាប់ ទាំងជំរុញគណបក្សនយោបាយអោយចាត់អាទិភាពស្ត្រីក្នុងវិស័យនយោបាយនេះ ព្រះរាជាណាចក្រកម្ពុជា នឹងមិនអាចទទួលបានជោគជ័យទៅតាមគោលដៅដែលបានកំណត់ឡើយ។

អិនជីអូ ស៊ីដ បញ្ជាក់ថា នៅក្នុងយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ ដើម្បីឆ្ពោះទៅសម្រេចសមភាពយេនឌ័របានកំណត់គោលដៅក្នុងការបង្កើនចំនួនក្រុមប្រឹក្សាឃុំ-សង្កាត់ ជាស្ត្រីអោយបាន ២៥ភាគរយនៅក្នុងឆ្នាំ២០១៨ ។

# Government Rolls Out Ambitious Plan to Put Women in Leadership

BY JULY 21, 2017
https://www.cambodiadaily.com/author/janelle-retka

An ambitious initiative to increase the number of women in government positions by establishing quotas was announced on Thursday, including plans to replace retiring men with women, provide child care services and create mentorship programs for women.

"We all recognize that when women hold management positions, there will be progress," said Sok Sothy, director of the policy analysis and development division at the National Committee for Sub-National Democratic Development (NCDD), which created the initiative with the interior and women's affairs ministries.



"We need to have commitment…to identify the number of females to put them in place," he said.

At least 20 percent of provincial leadership positions should be held by women by the end of next year, as well as 25 percent of top jobs at the district level, the policy says.

It gives quotas for "management" roles, including the positions of provincial governor, deputy governor and administrative director, ministry officials said during a launch event at the Sokha Phnom Penh hotel on Thursday.

According to NCDD data, women held just 12.1 percent of provincial leadership roles and 21.5 percent of district management positions as of last June. Nationwide, only one province is currently governed by a woman, with Mithona Phouthorng taking the helm in Koh Kong last month.

Chhuk Monny, undersecretary of state at the Civil Service Ministry, lauded the plans, but said there would be plenty of barriers to overcome—including male ego. Women with less work experience would likely be eclipsing them in order to meet the quotas, he said.

"They can be appointed, but for males we need some time to not be jealous…. But females have the priority," he said.

Neither Women's Affairs Ministry spokesman Phon Puthborey nor Interior Ministry spokesman Khieu Sopheak could be reached for comment.

Ros Sopheap, executive director of gender equality group Gender and Development Cambodia, was skeptical about the new policy.

It was merely “lip service,” she said, because the government employed too few women to have enough female candidates applicable to fill the quotas.

“A plan is a plan and policy is policy, but we’ve never seen that the plan and policy have been achieved so far,” Ms. Sopheap said, citing a drop in the number of female commune chiefs and councilors elected in last month’s commune elections compared to the last election cycle.

She added that commune and district leaders would not be experienced enough to take on provincial-level leadership roles, she said.

“They need to find someone near this position,” but there are no female options, Ms. Sopheap said. “Where can you find the women to be appointed?”

She also questioned what would happen if provinces missed the quotas.

“If there is no achievement, what is the punishment…. What is the response back that ‘you missed this commitment?’” she said.

# រដ្ឋាភិបាលជម្រុញវិស័យសារព័ត៌មានឲ្យផ្សាយគោរពសិទ្ធិស្ត្រី

ដោយ លោក ពេជ្រ ចំរុង | ថ្ងៃព្រហស្បតិ៍ ទី២០ ខែកក្កដា ឆ្នាំ២០១៧ ម៉ោង 5:23 PM




រាជរដ្ឋាភិបាល បានចុះហត្ថលេខាអនុម័តលើក្រមប្រតិបត្តិមួយ ដែលនឹងជម្រុញបណ្តាញសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ ពីរបៀបសរសេរ និងការប្រើប្រាស់ពាក្យសម្តីសមរម្យ គោរពដល់សិទ្ធិស្ត្រី និងទប់ស្កាត់ការប្រើប្រាស់អំពើហិង្សាលើស្ត្រី។

ក្នុងពិធីចុះហត្ថលេខាលើ **«ប្រកាសរួមស្តីពីក្រមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការរាយការណ៍ព័ត៌មានអំពើហិង្សាលើស្ត្រី»** នៅថ្ងៃព្រហស្បតិ៍ នារាជធានីភ្នំពេញ រដ្ឋមន្ត្រីក្រសួងព័ត៌មាន លោក ខៀវ កាញារីទ្ធ និងរដ្ឋមន្ត្រីក្រសួងកិច្ចការនារី លោកស្រី អ៊ឹង កន្ថាផាវី បានចុះហត្ថលេខារួមគ្នា លើក្រមប្រតិបត្តិមួយនេះ ដោយថា ដើម្បីទប់ស្កាត់ការយកករណីអំពើហិង្សាលើស្ត្រី ទៅធ្វើជាការកម្សាន្ត លុបបំបាត់អំពើហិង្សាលើស្ត្រី និងអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០១៤ដល់ឆ្នាំ២០១៨។

ក្នុងពិធីចុះហត្ថលេខានេះ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី លោកស្រី អ៊ឹង កន្ថាផាវី ថ្លែងថា ទម្រាំចុះហត្ថលេខាលើក្រមប្រតិបត្តិនេះ គឺត្រូវចំណាយអស់រយៈពេលជិត៦ខែ ដោយមានការសហការពីក្រសួង និងស្ថាប័នពាក់ព័ន្ធនានា។

លោកស្រីថ្លែងបន្ថែមថា វិស័យសារព័ត៌មាន ដើរតួនាទីយ៉ាងសំខាន់ ដើម្បីជម្រុញការគោរពសិទ្ធិស្ត្រី សមភាពយេនឌ័រ ការលុបបំបាត់អំពើហិង្សាលើស្ត្រី និងការរាយការណ៍ព័ត៌មានពីករណីហិង្សាលើស្ត្រី ដោយលក្ខណៈសមរម្យ។

ថ្លែងនៅក្នុងសន្និសីទនេះដែរ រដ្ឋមន្ត្រីក្រសួងពត៌មាន លោក ខៀវ កាញារីទ្ធ បានណែនាំដល់ក្រុមអ្នកសារព័ត៌មាន ឲ្យចេះសរសេរអត្ថបទព័ត៌មាន ដែលមិនទម្លាក់កំហុសទៅលើស្ត្រី កុំបង្ហាញរូបភាពស្ត្រីរងគ្រោះជាសាធារណៈ និងត្រូវផ្សាយព័ត៌មាន ដែលជម្រុញការគោរពសមភាពយេនឌ័រ។

បើតាមរបាយការណ៍ក្រសួងកិច្ចការនារី សម្រាប់ឆ្នាំ២០១៤ ឲ្យដឹងថា ស្ត្រីភាគច្រើននៅតែទទួលរងអំពើហិង្សាទាំងផ្លូវកាយ និងផ្លូវចិត្ត ដោយច្រើនកើតទៅលើស្ត្រីពិការ ស្រីផ្ទុកមេរោគអេដស៍ ស្ត្រីស្រឡាញ់ភេទដូចគ្នា និងស្ត្រីបម្រើការនៅកន្លែងកម្សាន្តជាដើម។

បើតាមរបាយការណ៍អង្គការមូលនិធិអាស៊ី ឲ្យដឹងថា បើធៀបនឹងត្រីមាសមុន ករណីហិង្សាលើស្ត្រីមានការថយចុះតិចតួចគឺចំនួន៤ភាគរយសម្រាប់ហិង្សាលើស្ត្រី និងថយចុះ៣ភាគរយ សម្រាប់ហិង្សាលើដៃគូស្និទស្នាលជាស្ត្រី៕

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកិច្ចការនារី**
លេខ......[illegible] កកន

## សេចក្តីថ្លែងការណ៍
## ស្តីពី ស្ត្រីក្នុងការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧

ក្រសួងកិច្ចការនារី សូមធ្វើការវាយតម្លៃខ្ពស់លើដំណើការ នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ ដែលបានប្រព្រឹត្តទៅប្រកបដោយសេរី យុត្តិធម៌ អហិង្សា និងដោយតម្លាភាព។ ប្រជាពលរដ្ឋ រួមទាំងស្ត្រីគ្រប់រូប មានការស្វាគមន៍យ៉ាងកក់ក្តៅ ប្រកបដោយសេចក្តីសប្បាយរីករាយចំពោះការអនុវត្តលទ្ធិប្រជាធិបតេយ្យ រក្សាស្ថិរភាពនយោបាយ និងសុខសន្តិភាពដែលកំពុងកើតមាននៅលើទឹកដីកម្ពុជា ។

ទោះបីជា បរិមាណស្ត្រីដែលជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មានការថយចុះបន្តិចបន្តួច (១%) ប៉ុន្តែបើពិនិត្យ និងវិភាគលើគុណភាពនៃការចូលរួមរបស់ស្ត្រី ក្នុងតួនាទីធ្វើសេចក្តីសម្រេចមានភាពប្រសើរឡើង។ ជាក់ស្តែង*ស្ត្រីជាមេឃុំ ចៅសង្កាត់ មានចំនួន១២៨រូប ដោយបានកើនឡើង ចំនួន ៣៣រូប បើប្រៀបធៀបអាណត្តិមុន ។ ចំណុចវិជ្ជមាននេះ បង្ហាញឲ្យឃើញថា សង្គម និងសហគមន៍កំពុងមានការចាប់អារម្មណ៍ទៅលើគុណតម្លៃ សារៈសំខាន់ និងការដឹកនាំរបស់ស្ត្រី នៅថ្នាក់មូលដ្ឋាន ។*

បើធ្វើការឆ្លុះបញ្ចាំង នៅក្នុងចំណោមស្ត្រីដែលជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមានចំនួន១៦,៧៦% *គណបក្សប្រជាជនកម្ពុជា គឺជាគណបក្សឈានមុខ ក្នុងការដាក់បេក្ខនារី និងមានស្ត្រីដែលជាប់ឆ្នោត(២១,៣១%)ធៀបនឹងគណបក្សផ្សេងទៀតដែលមានអាសនៈនៅក្នុងក្រុមប្រឹក្សាឃុំ សង្កាត់* ។

ចំណុចទាំងអស់នេះ ជាសក្ខីភាពដែលបង្ហាញនូវទង្វើរបស់រាជរដ្ឋាភិបាល ក្នុងការគាំទ្រ និងបង្កលក្ខណៈងាយស្រួលដល់ស្ត្រី ក្នុងការឈោងយកតួនាទីជ្រើសតាំង និងតែងតាំងនៅគ្រប់កម្រិត។ ជាក់ស្តែង នាពេលថ្មីៗនេះ ស្របតាមការប្តេជ្ញាចិត្តរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលបានលើកឡើងកាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៧ ស្ត្រី ០១រូប ត្រូវបានតែងតាំងជាអភិបាលខេត្តកោះកុង ។ ការតែងតាំងនេះ ព្រមទាំងការបង្កើនជាបន្តបន្ទាប់នូវចំនួនមន្ត្រីរាជការជានារីនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ *(កើនឡើងពី៣២% ក្នុងឆ្នាំ២០០៧ ដល់៤០% ក្នុងឆ្នាំ ២០១៦ ធៀបនឹងចំនួនមន្ត្រីរាជការទូទាំងប្រទេស)* ជាកាលានុវត្តភាពថ្មីដ៏សំខាន់សម្រាប់ស្ត្រីក្នុងការបង្ហាញនូវសក្តានុពល និងគុណតម្លៃលើតួនាទីដឹកនាំ និងការធ្វើសេចក្តីសម្រេចនៅគ្រប់កម្រិត។

រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងកិច្ចការនារី នឹងបន្តខិតខំរិះរកនូវវិធីសាស្ត្រ និងមធ្យោបាយបន្ថែមទៀត ក្នុងការលើកម្ពស់ការចូលរួមរបស់ស្ត្រី ដើម្បីផ្តល់ឱកាសឱ្យស្ត្រីគ្រប់រូបរួមចំណែកក្នុងការអភិវឌ្ឍសង្គមជាតិតាមបែបប្រជាធិបតេយ្យប្រកបដោយបរិយាប័ន្ន និងចីរភាព។

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៧

ផ្លូវទ្រុងមាន់ ភូមិដំណាក់ធំ៣ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ : ០២៣ ៨៨០ ៧៣៧ / ៨៨២ ០៤៨
៨៨២ ០៣៩ / ៨៨២ ០៤៩
ទូរសារ : ០២៣ ៨៨០ ៧៣៧

**សន្និសីទសារព័ត៌មាន**

**-លទ្ធផលអង្កេត ចំនួនស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៤-**

**ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧**

**សេចក្តីថ្លែងការណ៍រួម**

យោងតាមលទ្ធផលផ្លូវការនៃការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ អណ្តត្តិទី៤ ឆ្នាំ២០១៧ ដែលប្រកាសដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំនួនស្ត្រីជាមេឃុំមានចំនួន១២៨រូប នៅក្នុងអណត្តិទី៤ ដែលមានចំនួនកើនឡើង៣៣រូប បើប្រៀបធៀបនឹងអណត្តិទី៣ ឆ្នាំ២០១២។ ការកើនឡើងនេះ គឺដោយសារប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតមើលឃើញពីភាពសកម្ម និងសក្តានុពលរបស់ស្ត្រីក្នុងការអភិវឌ្ឍភូមិ-ឃុំ។ ស្ត្រីដែលជាប់ជាក្រុមប្រឹក្សាឃុំ-សង្កាត់មានចំនួន ១៩៥០រូប នៃចំនួនក្រុមប្រឹក្សាឃុំ-សង្កាត់សរុប ១១៥៧២ រូប ដែលស្មើនឹង១៦.៧៦%។ ប៉ុន្តែគួរឱ្យសោកស្តាយ បើប្រៀបធៀបជាមួយនឹងអណត្តិមុន ចំនួនស្ត្រីមានការធ្លាក់ចុះចំនួន ១.០៣% (អណត្តិទី៣មានក្រុមប្រឹក្សាជាស្ត្រីចំនួន ២០៣៨ រូប)។ ក្នុងចំណោមឃុំចំនួន១៦៤៦ មានឃុំចំនួន៣៤៤ ដែលគ្មានក្រុមប្រឹក្សាជាស្ត្រី។

ការធ្លាក់ចុះនេះ ធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ ១. ផែនការយុទ្ធសាស្ត្រជាតិ ក៏ដូចជាគោលដៅអភិវឌ្ឍប្រកបដោយចីរភាព ដែលមិនអាចសម្រេចបាននូវគោលដៅសមភាពយេនឌ័រ ២. ប៉ះពាល់ដល់ស្ត្រីដែលកំពុង និងត្រៀមនឹងប្រឡូក នៅក្នុងឆាកនយោបាយ ជាពិសេសកម្រិតឃុំ មានការបាក់ទឹកចិត្ត ដោយសារចំនួនស្ត្រីដែលជាតំណាង មានការតែតិចទៅៗ ៣. បញ្ហារបស់ប្រជាពលរដ្ឋ ជាពិសេស ស្ត្រី និងកុមារនៅថ្នាក់មូលដ្ឋានមិនត្រូវបានគេយកចិត្តទុកដាក់ និងឆ្លើយតបដោយប្រសិទ្ធិភាព ដោយសារសម្លេងស្ត្រីជាក្រុមប្រឹក្សាឃុំ-សង្កាត់ មានចំនួនតិចតួច។

**អនុសាសន៍**

១. ស្នើវិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រង់មាត្រា៤៩ថ្មី (មាត្រា៩៨ចាស់)នៃជំពូកទី៧-និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ មាត្រា៣៧ថ្មី មាត្រា៣៨ថ្មីនៃជំពូកទី៤ និង មាត្រា១២០ថ្មីនៃជំពូក ទី៩។ ការធ្វើវិសោធនកម្មច្បាប់ទាំងនេះ គឺក្នុងគោលបំណងឱ្យមានការធានានូវបេក្ខភាពស្ត្រីត្រូវបានឈរឈ្មោះក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតរបស់គណបក្ស

នយោបាយ ដោយដាក់ឆ្លាស់រវាងស្ត្រី និងបុរសតាមលំដាប់លេខរៀងពីលើដល់ក្រោម។ ការអនុវត្តដូចនេះជាវិធានការសមស្រប និងមានប្រសិទ្ធភាពល្អប្រសើរ ក្នុងការជំរុញ ឲ្យស្ត្រី និងបុរសអាចចូលរួមក្នុងវិស័យនយោបាយបានពេញលេញទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា អនុសញ្ញាស៊ីដរស្តីពីការលុបបំបាត់រាល់ទំរង់រើសអើងប្រឆាំងនឹងស្ត្រីគេ។ ជាពិសេសមាត្រា ៤ ក៏ដូចជាស្របនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (Sustainable Development Goals) និងលិខិតបទដ្ឋានគតិយុត្តនានារបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី។

២. គណបក្សនយោបាយទាំងអស់គួររៀបចំ និងអនុវត្តគោលនយោបាយសមភាពយេនឌ័រជាលាយល័ក្ខអក្សរសម្រាប់គណបក្សរបស់ខ្លួនដែលជាការបង្ហាញអំពីការយកចិត្តទុកដាក់ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋជាម្ចាស់ឆ្នោត។

៣. គណបក្សនយោបាយគួរបង្កើត និងបង្កើននូវបរិយាកាសល្អប្រសើរ ជំរុញ លើកទឹកចិត្ត និងគាំទ្រយ៉ាងពេញលេញដល់ស្ត្រីក្នុងការចូលរួមក្នុងវិស័យនយោបាយប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។

៤. គណបក្សនយោបាយ រាជរដ្ឋាភិបាល និងគណកម្មាធិការជាតិរៀបចំការបោះឆ្នោត គួរបន្ថែមការអប់រំដល់សាធារណៈជនដើម្បីយល់ដឹងពីសារៈសំខាន់ដែលត្រូវការស្ត្រីជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនតាមរយៈការបង្កើនយន្តការដាក់លាក់ដើម្បីគាំទ្រស្ត្រីឲ្យឈរឈ្មោះបោះឆ្នោត និងជំរុញឲ្យស្ត្រីមានតួនាទីក្នុងការធ្វើសេចក្តីសម្រេច និងទទួលបានអំណាច តួនាទីពិតប្រាកដក្នុងការ អនុវត្តន៍តួនាទី និងភារកិច្ចរបស់ខ្លួន។

លេខទូរស័ព្ទសម្រាប់ទាក់ទង៖
*លោកស្រី សឺនកេត សិរីលក្ខណ៍ អ្នកសម្របសម្រួលផ្នែកអប់រំ និងយេនឌ័រ នៃអង្គការខុមហ្វ្រែល: 012 775 696*
*កញ្ញា សេង រាសី អ្នកសម្របសម្រួលគម្រោង គណកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ: 017 933 336*

Cambodian People's Party (CPP)

Cambodia National Rescue Party (CNRP)

FUNCINPEC Party (FP)

League for Democracy Party (LDP)

Khmer National United Party (KNUP)

Beehive Social Democratic Party (BSDP)

Cambodian Nationality Party (CNP)

Grassroots Democracy Party (GDP)

Cambodian Youth Party (CYP)

Cambodia Indigenous People's Democracy Party (CIPDP)

Khmer Power Party (KPP)

Republican Democracy Party (RDP)

## មុនពេលបាត់បង់ជីវិត អ្នកស្រីង៉ែត សុភាព ចង់បង្កើតសហគមន៍ជួយស្ត្រី

( **វិទ្យុស្ត្រី** FM102 ) 29 05 2017

**ជាស្ត្រីមេម៉ាយ អ្នកស្រីង៉ែត សុភាព បានចូលប្រឡូកក្នុងឆាកនយោបាយដើម្បីសម្រេចក្តីស្រមៃមួយ គឺស្វែងរកឱកាសជួយស្ត្រីក្នុងមូលដ្ឋានរបស់អ្នកស្រី។អ្នកស្រីបានឈរឈ្មោះជាបេក្ខនារីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិទី៤ ឆ្នាំ២០១៧នេះ ប្រចាំសង្កាត់រលាប ខេត្តពោធិ៍សាត់ កូតាគណបក្សសង្គ្រោះជាតិ។ ប៉ុន្តែជាអកុសល្យ អ្នកស្រីង៉ែត សុភាព បានស្លាប់បាត់បង់ជីវិតក្នុងពេលកំពុងឃោសនា កាលពីសប្តាហ៍មុន។***«បង្កើតសហគមន៍សម្រាប់ជួយស្ត្រី និងមន្ទីរពេទ្យនៅតំបន់ជនបទដាច់ស្រយាល ព្រមទាំងផ្តល់ថវិកា៥ម៉ឺនរៀលសម្រាប់ស្ត្រីក្រីក្រសម្រាលកូន»* នេះគឺគោលបំណងរបស់អ្នកស្រី ង៉ែត សុភាព ប្រសិនបើអ្នកស្រីជាប់ជាក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការបោះឆ្នោតអាណត្តិទី៤ ឆ្នាំ២០១៧នេះ។ ប៉ុន្តែជាអកុសល្យ អ្នកស្រីង៉ែត សុភាព បានទទួលមរណភាពដោយសារគ្រោះថ្នាក់ចរាចរណ៍កាលពីថ្ងៃទី២៤ ឧសភា ខណៈដែលអ្នកស្រីកំពុងដើរឃោសនារកសំលេងឆ្នោត នៅភូមិព្រៃកន្ទោត សង្កាត់រលាប ក្រុងពោធិ៍សាត់។

អ្នកស្រី ត្រូវម៉ូតូបុកពេញទំហឹងរអូសប្រហែល ៥ម៉ែត្រ នៅចំណុចផ្លូវកោងក្នុងភូមិព្រៃកន្ទោត នៅពេលដែលអ្នកស្រីកំពុងដើរតាមផ្លូវក្រោយបានបិទខិត្តប័ណ្ណគោលនយោបាយបក្សនៅតាមផ្ទះប្រជាពលរដ្ឋ។

បេក្ខនារីលេខរៀងទី៣ របស់គណបក្សសង្គ្រោះជាតិរូបនេះ បានបន្សល់ទុកនូវកូនកំព្រាចំនួនបួននាក់។ ប្តីរបស់អ្នកស្រីបានស្លាប់មុនអ្នកស្រី កាលពីមួយឆ្នាំមុន ដោយសារគ្រោះថ្នាក់ចរាចរណ៍ដូចគ្នា។

កញ្ញា សៅ យ៉ានុត កូនស្រីច្បងរបស់ស្ត្រីរងគ្រោះ បានឱ្យដឹងថា ម្តាយខ្លួនតែងតែជជែកពីពីបំណងបង្កើតសហគមន៍សម្រាប់ជួយស្ត្រី និងមន្ទីរពេទ្យនៅតំបន់ជនបទដាច់ស្រយាល ព្រមទាំងផ្តល់ថវិកា៥ម៉ឺនរៀលសម្រាប់ស្ត្រីក្រីក្រពេលសម្រាលកូននេះ ជាមួយកូនៗ ក៏ដូចជាអ្នកជិតខាង។ ក្រៅពីការប៉ងជួយស្ត្រីនៅក្នុងតំបន់របស់ខ្លួន ម្តាយរបស់នាងក៏សន្យាជួយធ្វើផ្លូវក្នុងភូមិឱ្យបានល្អផងដែរ។

អ្នកស្រី ង៉ែត សុភាព គឺជាសកម្មជនគណបក្ស សម រង្ស៊ី មុននឹងគណបក្សនេះច្របាច់បញ្ចូលគ្នាជាមួយគណបក្សសិទ្ធិមនុស្សរបស់លោកកឹម សុខា និងបង្កើតជាគណបក្សសង្គ្រោះជាតិ។ ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រកាលពីឆ្នាំ២០១៣ អ្នកស្រីគឺជាអ្នកសង្កេតការណ៍របស់គណបក្សប្រឆាំងនេះ នៅខេត្តពោធិសាត់។

ដោយប្រឡូកក្នុងឆាកនយោបាយច្រើនឆ្នាំកន្លងមក នៅទីបំផុតអ្នកស្រីបានសម្រេចចិត្តចូលប្រឡូកក្នុងឆាកនយោបាយកាន់តែសកម្មថែមទៀត និងចង់បានតួនាទីមួយដើម្បីដឹកនាំសហគមន៍ឆ្ពោះទៅរកការរីកចម្រើនសម្រាប់ស្ត្រី។

នៅពេលនៅមានជីវិតនៅឡើយ អ្នកស្រី ង៉ែត សុភាព ប្រកបរបរជាអ្នកលក់កង្កែបអាំង នៅជិតក្បែរស្ពានថ្មនៃស្ទឹងពោធិសាត់ ក្រុងពោធិសាត់។ ជាមួយមុខរបរតូចតាចនេះ ស្ត្រីអាយុ៣៧ ឆ្នាំរូបនេះបានជួបបញ្ហាប្រឈមជាច្រើនក្នុងការចិញ្ចឹមកូនៗទាំងបួននាក់ឲ្យរៀនសូត្រគ្រប់ៗគ្នា ក្រោយពីប្ដីអ្នកស្រីទទួលមរណភាព។

ការតស៊ូនេះ ទំនងជាបានក្លាយជាគំរូសម្រាប់កញ្ញា សៅ យ៉ានុត កូនស្រីច្បងរបស់អ្នកស្រី។ កញ្ញាសប្បាយចិត្ត និងមានមោទនៈភាពចំពោះការប្រឡូកក្នុងសកម្មនយោបាយរបស់ម្ដាយ។ ហើយនាងមានបំណងបន្តសកម្មភាពពីម្ដាយផងដែរ។

«*ស្រលាញ់ដូចគ្នាបង ព្រោះឱ្យតែពេលទៅហែរអីអញ្ចឹងគាត់យកពួកខ្ញុំទីហែរជាមួយ ហើយហែរពួកខ្ញុំផុសរហូត*»។

កូនទាំង៤នាក់របស់អ្នកស្រី គឺកញ្ញា សៅ យ៉ានុត អាយុ១៧ឆ្នាំ រៀននៅថ្នាក់ទី១១ កុមារី សៅ ស្រីនីត អាយុ១៥ រៀននៅថ្នាក់ទី៨ កុមារីសៅ ស្រីនេត អាយុ១៣ឆ្នាំ រៀននៅថ្នាក់៧ និងកុមារា សៅ រ៉ាយុទ្ធ អាយុ១០ ឆ្នាំរៀននៅថ្នាក់ទី២។

បច្ចុប្បន្ននេះ កូនកំព្រាទាំង៤កំពុងជួបបញ្ហាជីវភាព និងជំពាក់បំណុលធនាគារ។ បំណុលក្រោយពីម្ដាយឪពុករបស់ខ្លួនខ្ចីទិញរថយន្តមួយគ្រឿងដើម្បីស៊ីឈ្នួលដឹកអ្នកដំណើរ។

លោក ឌុក សាវ័ន្ត បេក្ខជនលេខរៀងទី២ នៅក្នុងសង្កាត់រលាប ដែលបានចេញដើរឃោសនារកសំលេងឆ្នោតជាមួយអ្នកស្រី ង៉ែត សុភាព បានរៀបរាប់ពីហេតុការណ៍នៅនោះ។ ជាសកម្មជនគណបក្សប្រឆាំងដូចគ្នា លោក សាវ័ន្ត បានប្រាប់ឱ្យដឹងថា អ្នកស្រី ង៉ែត សុភាព គឺជាមនុស្សម្នាក់ដែលមានភាពស្មោះត្រង់ និងសកម្មនឹងការងារ។ លោកបន្តថា បើទោះជាអ្នកស្រីជាស្ត្រី មេម៉ាយ មានបន្ទុកចិញ្ចឹមកូន៤នាក់ក៏ដោយ ប៉ុន្តែអ្នកស្រីបានចំណាយពេលជាច្រើនក្នុងការធ្វើការ ក៏ដូចជាការដើរឃោសនា។

លោកបន្ថែមថា អ្នកស្រី ង៉ែត សុភាព បានសង្ឃឹមយ៉ាងខ្លាំងថាខ្លួន នឹងជាប់ឆ្នោតជាក្រុមប្រឹក្សាសង្កាត់រលាប។ ហើយអ្នកស្រីង៉ែត សុភាព បានរំពឹង នៅពេលដែលខ្លួនជាប់ឆ្នោត នឹងអាចជួយខ្លួនឯងបាន៕